**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កាតព្វកិច្ចឧបសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ជួង មាសបញ្ញាវុធ**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ញឹក វុឌ្ឍី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ
# លោកឪពុក និងអ្នកម្តាយ ជាទីគោរពនៃកូន

ជាបឋម ខ្ញុំបាទឈ្មោះ **ដួង មាសបញ្ញាវុធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពប្រតិបត្តិ និងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះ៖

លោកឪពុក **ដួង មាសចំរើន** និងអ្នកម្តាយ **ឆេង អាងសោភា**

ឆ្លៀតឱកាសដ៏មានតម្លៃនេះ កូនសូមលំអោនការសម្តែងនូវការគោរពប្រតិបត្តិ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះលោកអ្នកមានគុណទាំងពីររបស់កូន ។ ពិតណាស់លោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មាន ឱ្យកូននូវសេចក្តីព្យាយាម អំណត់ក្លាហាន ព្រមទាំងធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈក្នុងការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់បរិ- ញ្ញាបត្រ ដែលជាហេតុធ្វើឱ្យកូនទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្នូរ និងភាពជោគជ័យដូចសព្វថ្ងៃនេះ។

កូននៅចងចាំមិនភ្លេចពីគុណយ៉ាងជ្រាលជ្រៅ និងរកអ្វីមកប្រៀបផ្ទឹមឱ្យស្មើពុំបាននូវគុណូបការដ៏ធំធេងរបស់អ្នកមានគុណទាំងពីរ។ កូនសូមលើកដៃទាំងគូរឡើង ដើម្បីបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកយើងនេះ សូមមេត្តាតាមជួយបីបាច់ថែរក្សាលោកអ្នកមានគុណទាំងពីរឱ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ និងមានជីវិតយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ជីវិតកូនដ៏យូរអង្វែងតទៅអនាគត។

ជាងនេះទៀត ខ្ញុំបាទជានិស្សិតក៏មិនភ្លេចផងដែរ នូវការដឹងគុណចំពោះ ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិ-ការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ និងបុគ្គលិកនៅការិយាល័យសិក្សាទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជួយជ្រោមជ្រែង និងបង្ហាត់បង្ហាញខ្ញុំបាទឱ្យមានគុណវុឌ្ឍដូចថ្ងៃនេះ។

ខ្ញុំបាទក៏មិនភ្លេចដែរ នូវការដឹងគុណដ៏ធំធេងចំពោះ ឯកឧត្តម **ហង់ ជួនណារុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី នៃក្រសួងអប់រំកាយ យុវជននិងកីឡា ដែលបានផ្តល់អាហារូបករណ៍ឥស្សរជនដល់រូបខ្ញុំបាទ ១០០% សម្រាប់កញ្ចប់សិក្សាថ្នាក់បរិញ្ញាបត្រ ៤ ឆ្នាំពេញ ជំនាញនីតិសាស្ត្រ ។

ជាពិសេសនោះ ខ្ញុំបាទសូមគោរពដឹងគុណចំពោះលោកសាស្ត្រាចារ្យជំនួយ **ញឹក វុឌ្ឍី** ដែលបានខិតខំយកចិត្តទុកដាក់ពន្យល់ ណែនាំ បង្ហាត់បង្រៀន និងផ្តល់យោបល់ល្អដល់ខ្ញុំបាទក្នុងការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

ជាទីបញ្ចប់ ខ្ញុំបាទសូមលំអោនកាយវាចាចិត្ត បួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងឡាយ សូមឱ្យអ្នកមានគុណទាំងអស់ ជួបតែពុទ្ធពរទាំងប្រាំប្រការ**គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ឆ្លងតាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមក ធ្វើឱ្យខ្ញុំបាទទទួលបានចំណេះដឹងថ្មីៗនិងល្អៗជាច្រើន។ ជាងនេះទៅទៀតនៅចុងឆ្នាំទី៤នេះផងដែរ សាកលវិទ្យាល័យក៏មានផ្តល់ឱកាសដល់រូបខ្ញុំបាទក្នុងការស្រាវជ្រាវនូវសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផងដែលវាក៏ចាត់ទុកថាជាការសម្រេចបំណងមួយរបស់ខ្ញុំបាទក្នុងការដែលបានចងក្រងនូវស្នាដៃស្រាវជ្រាវជូនដល់មិត្តនិស្សិត និងសិស្សប្អូន ដែលកំពុងសិក្សាស្រាវជ្រាវលើមុខវិជ្ជានីតិសាស្ត្រផងដែរ ព្រោះខ្ញុំបាទមានគោលបំណងក្នុងការស្រាវជ្រាវនិងចងក្រងស្នាដៃនេះ ដើម្បីទុកជាការចែករំលែកបង្កើនពុទ្ធិ ដែលធ្វើឱ្យសិក្សារឹតតែប្រសើរឡើង។

ដូច្នេះហើយបានជា ប្រធានបទនៃសារណាមួយនេះ ផ្តើមចេញពីទស្សនៈនៃការយល់ឃើញរបស់ខ្ញុំបាទទៅលើនីតិរដ្ឋប្បវេណីនៅកម្ពុជា។ ខ្ញុំបាទសង្កេតឃើញថា នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា (ស្ថិតក្នុងនីតិរដ្ឋប្បវេណី) គឺនីតិកាតព្វកិច្ចមួយប្រភេទ ដែលមានភាពសារៈសំខាន់។

តែយ៉ាងណាមិញ នីតិកាតព្វកិច្ចក្រៅកិច្ចសន្យានេះពុំសូវមានឯកសារចងក្រងបង្ហាញបង្រៀនពីវាឡើយដូចជា «កាតព្វកិច្ចឧបសន្យា»ជាដើម ។

សមស្របទៅតាមកម្មវិធីសិក្សាសាកលវិទ្យាល័យ និងមានករណីយល់ច្រឡំជារឿយៗ ចំពោះមិត្តិនិស្សិតសិក្សាផ្នែកនីតិសាស្ត្រ ទើបខ្ញុំបាទមានសេចក្តីសោមនស្សរីករាយស្រាវជ្រាវនិងចងក្រងទៅលើប្រធានបទនៃសារណានេះដែលវាជាកាតព្វកិច្ចមួយប្រភេទដែលតែងតែកើតមានឡើងជារឿយៗ យើងមិនបានចាប់អារម្មណ៍ថាយើងបំពេញលក្ខខណ្ឌនាំឱ្យមានករណីយកិច្ចនិង អានុភាពទោះមិនបានសរសេរជាលាយលក្ខណ៍អក្សរក៏ដោយ។

ប្រធានបទសារណា «កាតព្វកិច្ចឧបសន្យា» ដែលខ្ញុំបានលើកដើម្បីយកមកសរសេរក្នុងសារណាបញ្ចប់បរិញ្ញាបត្រនីតិសាស្ត្រនេះ គឺបានដកស្រង់ពីលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានដូចជា ក្រមរដ្ឋប្បវេណីបច្ចុប្បន្ន និងនិរាករណ៍ ដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ថែមទាំងបានដកស្រង់ឯកសារពាក់ព័ន្ធរបស់នីតិករ និងបុគ្គលដែលមានគុណវុឌ្ឍជាច្រើនរូបផងដែរពោលគឺ សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី សមាគមសាលាត្រាជូ ស្លាយបង្រៀនរបស់លោក គង់ តារាឆាត ជាដើម។

ក្នុងការស្រាជ្រាវនិងចងក្រងសារណានេះឡើង ខ្ញុំបាទបង្ហាញសញ្ញាណទូទៅ លក្ខខណ្ឌនិងប្រភេទនៃកាតព្វកិច្ចឧបសន្យា ព្រមទាំងករណីយកិច្ច និងអានុភាពហើយមានបញ្ចូលនូវឧទាហរណ៍និងករណីខ្លះដែរ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថាសារណា របស់ខ្ញុំបាទសម្រាប់តែនិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ពោលគឺឆ្នាំទី ២ និងឆ្នាំទី៣ ប៉ុណ្ណោះ។

ម្យ៉ាងទៀត ដោយគំនិតរបស់មនុស្សក្នុងលោកប្លែកៗពីគ្នានោះ ខ្ញុំមានសេចក្តីបារម្ភណាស់ក្រែងយោបល់របស់ខ្ញុំបាទ និងការចងក្រងមិនស្របតាមយោបល់របស់អស់មិត្តនិស្សិត ប៉ុន្តែបើមានសេចក្តីខ្លះឆ្គាំឆ្គង មិនសមហេតុផល មិនស៊ីគ្នានឹងអត្ថន័យតាមចំណុចនីមួយៗ ឬក៏ខ្វះសេចក្តីត្រង់ណាក្តី ដែលខ្ញុំបាទមើលមិនឃើញ គិតមិនដល់នោះ ខ្ញុំបាទសូមអភ័យទោសទុកជាមុន។

ខ្ញុំសូមថ្លែងអំណរគុណជាមុន ចំពោះមិត្តនិស្សិត ដែលមេត្តាជួយតម្រែតម្រង់រំលឹកខ្ញុំ ដើម្បីនឹងឱ្យខ្ញុំថែមថយសេចក្តីខ្លះ ហើយខ្ញុំបាទរង់ចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាសារណានេះឱ្យកាន់តែប្រសើរ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១


## ជំពូកទី១
## ភាតព្វកិច្ចឧបសន្យា

**ផ្នែកទី១. ការគ្រប់គ្រងដោយឈឺឆ្អាល** ........ ៣

**កថាភាគទី១. សញ្ញាណទូទៅ** ........ ៣

១. បទដ្ឋានគតិយុត្ត ........ ៣

១.១ អត្ថន័យតាមក្រមរដ្ឋប្បវេណីចាស់ ........ ៤

១.២ អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ........ ៤

២. ឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងដោយឈឺឆ្អាល ........ ៥

២.១ អត្ថន័យតាមពាក្យពេចន៍ ........ ៥

២.២ អត្ថន័យតាមសេចក្ដីផ្ដើមរដ្ឋប្បវេណី ........ ៦

**កថាភាគទី២. លក្ខខណ្ឌនិងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល** ........ ៧

១. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ........ ៧

១.១ លក្ខខណ្ឌគ្រឹះ ........ ៧

១.១.១ សមត្ថភាពខាងឆន្ទៈ ........ ៧

១.១.២ សមត្ថភាពក្នុងការធ្វើសកម្មភាព ........ ៨

១.២ លក្ខខណ្ឌទម្រង់ ........ ៨

១.២.១ ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច ........ ៨

១.២.២ កាគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ ........ ៩

១.២.៣ អ្នកគ្រប់គ្រងចាប់ផ្ដើមគ្រប់គ្រងកិច្ចការ ........ ១១

១.២.៤ ការគ្រប់គ្រងធ្វើឡើងដោយវិធីសមរម្យ និងដោយផ្អែកតាមឆន្ទៈ ........ ១២

២. ប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល ........ ១៣

២.១ ការគ្រប់គ្រងត្រូវធ្វើឡើងចំពោះបុគ្គល និងទ្រព្យ ........ ១៣

២.១.១ ចំពោះបុគ្គល ........ ១៣

២.១.២ ចំពោះទ្រព្យសម្បត្តិ ........ ១៣

២.២ ការគ្រប់គ្រងធ្វើឡើងក្នុងស្ថានភាពបន្ទាន់ ........ ១៣

២.២.១ ការការពារក្នុងស្ថានភាពចាំបាច់ ........ ១៣

២.២.១.១ សកម្មភាពឯកតោភាគី ........ ១៣

២.២.១.២ សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ ........ ១៤

២.២.២ ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត ១៤
២.២.២.១ ការគ្រប់គ្រងដោយគ្មានកំហុស ១៥
២.២.២.២ ការមិនទទួលខុសត្រូវលើសំណងនៃការខូចខាត ១៥
២.៣ ការគ្រប់គ្រងដោយឈឺឆ្អាលក្រោយពីបញ្ចប់កិច្ចសន្យា ១៦
**ផ្នែកទី២. សេចក្ដីចម្រើនដោយឥតហេតុ** ១៦
**កថាភាគទី១. សញ្ញាណទូទៅ** ១៦
១. បទដ្ឋានគតិយុត្ត ១៦
១.១ អត្ថន័យតាមក្រមរដ្ឋប្បវេណីចាស់ ១៦
១.២ អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ១៧
២. ឯកសារពាក់ព័ន្ធ ១៧
២.១ អត្ថន័យតាមវចនានុក្រមខ្មែរ ១៧
២.២ អត្ថន័យតាមសមាគមសាលាត្រាជូ ១៨
**កថាភាគទី២. លក្ខខណ្ឌ** ១៨
១. លក្ខខណ្ឌសម្ភារៈ ឬសត្យានុម័ត ១៨
១.១ ការទទួលផលប្រយោជន៍ ១៩
១.២ ការបាត់បង់ប្រយោជន៍ ១៩
១.៣ ទំនាក់ទំនងហេតុ និងផល ២០
២. លក្ខខណ្ឌផ្លូវច្បាប់ ២១

## ជំពូកទី២
## ករណីយកិច្ច

**ផ្នែកទី១. ករណីយកិច្ចរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល** ២២
**កថាភាគទី១. ករណីយកិច្ចរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល** ២២
១. ករណីយកិច្ចជូនដំណឹង ២២
១.១ សាមីខ្លួនបានយល់ព្រមឱ្យអ្នកគ្រប់គ្រងចាប់ផ្ដើមធ្វើការគ្រប់គ្រង ២២
១.២ សាមីខ្លួនធ្វើការបដិសេធមិនឱ្យចាប់ផ្ដើមការគ្រប់គ្រង ២៣
១.៣ សាមីខ្លួនផ្ដល់ការយល់ព្រមយឺតយ៉ាវ ២៣
២. ករណីយកិច្ចបន្តគ្រប់គ្រង ២៥
៣. ករណីយកិច្ចប្រគល់ ២៧
៤. ករណីយកិច្ចរាយការណ៍ ២៨
៥. ករណីយកិច្ចសងសំណងនៃការខូចខាត ២៨
៦. ករណីយកិច្ចគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួន ឬតាមវិធីសមរម្យ ២៩

**កថាភាគទី២. ករណីយកិច្ចរបស់អ្នកត្រូវគេគ្រប់គ្រង** ........ ៣០
១. ករណីយកិច្ចប្រគល់សោហ៊ុយលើការគ្រប់គ្រង ........ ៣០
២. ករណីយកិច្ចប្រគល់កម្រៃ ........ ៣០
៣. ករណីយកិច្ចគិតអត្រាការប្រាក់ចំពោះការយឺតយ៉ាវ ........ ៣០
**ផ្នែកទី២. ករណីយកិច្ចក្នុងសេចក្ដីចម្រើនដោយឥតហេតុ** ........ ៣១
១. ករណីយកិច្ចសងរបស់អ្នកទទួលប្រយោជន៍ដោយសុចរិត ........ ៣១
២. ករណីយកិច្ចសងរបស់អ្នកទទួលប្រយោជន៍ដោយទុច្ចរិត ........ ៣១

## ជំពូកទី ៣
## អានុភាព

**ផ្នែកទី១. អានុភាពក្នុងការគ្រប់គ្រងដោយឈឺឆ្អាល** ........ ៣៣
**កថាភាគទី១. អានុភាពរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល** ........ ៣៣
១. សិទ្ធិទាមទារសងសោហ៊ុយវិញ ........ ៣៣
២. សិទ្ធិទាមទារកម្រៃ ........ ៣៤
៣. សិទ្ធិមិនទទួលខុសត្រូវលើសំណងនៃការខូចខាត ........ ៣៥
**កថាភាគទី២. អានុភាពរបស់អ្នកត្រូវគេគ្រប់គ្រងដោយឈឺឆ្អាល** ........ ៣៥
១. សិទ្ធិទាមទារសំណងនៃការខូចខាតមកវិញ ........ ៣៥
២. សិទ្ធិបញ្ឈប់សកម្មភាពបន្តការគ្រប់គ្រងដោយឈឺឆ្អាល ........ ៣៥
៣. សិទ្ធិទាមទារឱ្យមានការរាយការណ៍ពីការគ្រប់គ្រង ........ ៣៦
**ផ្នែកទី២. អានុភាពក្នុងសេចក្ដីចម្រើនដោយឥតហេតុ** ........ ៣៦
១. បទបញ្ញត្តិទូទៅ ........ ៣៦
២. បញ្ញត្តិពិសេស ........ ៣៧
៣. ករណីពិសេស ........ ៣៨
៣.១ ការសងដោយគ្មានកាតព្វកិច្ច ........ ៣៨
៣.២ ការសងមុនពេលកំណត់ ........ ៣៩
៣.៣ ការសងតាវកាលិកនៃការសងកាតព្វកិច្ចអ្នកដទៃ ........ ៣៩
៣.៤ ការផ្ដល់តាវកាលិកដោយមូលហេតុខុសច្បាប់ ........ ៤១
**សេចក្ដីសន្និដ្ឋាន** ........ ៤២
**អនុសាសន៍** ........ ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មនុស្សយើងជានិច្ចកាលយកចិត្តទុកដាក់ចំពោះកិច្ចការរបស់អ្នកដទៃ ទោះបីជាគ្មានសិទ្ធិអំណាច ឬករណីយកិច្ចតាមផ្លូវច្បាប់ដើម្បីធ្វើបែបនោះក៏ដោយ។ ដូចដែលយើងដឹងស្រាប់ហើយថា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង សាមគ្គីភាពសង្គម និង កិច្ចសហប្រតិបត្តិការទៅវិញទៅមកមានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សយើង ។ ប៉ុន្តែ វាច្បាស់ណាស់ទៅហើយដែលថាការជួយគ្នាទៅវិញទៅមកនេះ គឺជា «ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ» ។

ប្រសិនបើយើងអនុវត្ត«គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន»ឱ្យជាក់លាក់ទៅលើការជួយគ្នាទៅវិញទៅមកបែបនេះ ត្រូវបានវាយតម្លៃថាខុសច្បាប់។

ជាងពីនេះទៅទៀតនោះ ក៏មាននូវករណីមួយចំនួនដែលកើតឡើងពីការភាន់ច្រឡំដែលបណ្តាលឱ្យមានការបាត់បង់ផលប្រយោជន៍របស់បុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដោយការទទួលបានផលប្រយោជន៍នោះដោយគ្មានហេតុផលច្បាស់លាស់។

ដោយសារតែហេតុផលនេះហើយ ជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនដោយសារទំនាក់ទំនងនេះកើតឡើងដោយច្បាប់ តែមិនមែនដោយឆន្ទៈរបស់ភាគី។ ទំនាក់ទំនងនេះត្រូវបានហៅថាជា ទំនាក់ទំនងនៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់ឬ កាតព្វកិច្ចឧបសន្យា។

កាតព្វកិច្ចឧបសន្យា ជាកាតព្វកិច្ចដែលកើតចេញពីអំពើដោយចេតនាត្រឹមត្រូវ និងស្ម័គ្រចិត្តរបស់បុគ្គលម្នាក់ដែលបង្កើតឱ្យមានកាតព្វកិច្ចរវាងម្ចាស់បំណុលនិងកូនបំណុលដូចជាភាគីនៃកិច្ចសន្យាដែរ។ ប៉ុន្តែក្នុងឧបសន្យាគ្មានការព្រមព្រៀងគ្នាជាមុនទេ។ គេអាចហៅថា កិច្ចសន្យាមិនពេញលេញ ព្រោះឥតមានការព្រមព្រៀងគ្នាជាមុន។ ការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្តីចម្រើនដោយឥតហេតុ គឺស្ថិតនៅក្នុងកាតព្វកិច្ចឧបសន្យា។

ហេតុនេះហើយ បានជាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្នុងគន្ថីទី៥ ជំពូកទី១៤ ចែងអំពីការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្តីចម្រើនដោយឥតហេតុ ដែលជាគោលការណ៍មួយបង្កើតឱ្យមានការចេះជួយគ្នាទៅវិញទៅមកនៅក្នុងសង្គម និងការការពារមិនឱ្យមានការកេងប្រវ័ញ្ចទាញយកប្រយោជន៍បាន។

ដោយមើលឃើញនូវសារៈសំខាន់ និងភាពចាំបាច់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋមួយចំនួនដែលទាក់ទងទៅនឹងកាតព្វកិច្ចឧបសន្យានេះហើយ ទើបមានសំណួរមួយចំនួនដែលពាក់ព័ន្ធនឹងចម្ងល់ថា តើអ្វីទៅជាសញ្ញាណទូទៅក្នុងកាតព្វកិច្ចឧបសន្យា និងមានលក្ខខណ្ឌអ្វីខ្លះ ដើម្បីចាត់ទុកជាកាតព្វកិច្ចឧបសន្យា និងប្រភេទរបស់វាមានប៉ុន្មានខ្លះ? តើករណីយកិច្ច និងអានុភាពក្នុងកាតព្វកិច្ចឧបសន្យាមានដូចម្តេចខ្លះ?

គោលបំណងនៃកិច្ចការស្រាវជ្រាវលើប្រធានបទនេះ គឺជាការរួមចំណែកមួយក្នុងការអនុវត្តច្បាប់ដែលទាក់ទងទៅនឹងកាតព្វកិច្ចកំណត់ដោយច្បាប់ ជាពិសេសដើម្បីឱ្យអ្នកអានគ្រប់គ្នាមាននូវចំណេះដឹងបន្ថែមទាក់ទងទៅនឹងប្រធានបទ នៃកិច្ចការស្រាវជ្រាវមួយនេះ គឺសម្តៅដល់កាតព្វិច្ចឧបសន្យា។

លើសពីនេះ កិច្ចការស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងបង្ហាញពីធាតុបង្កុំក្នុងកាតព្វកិច្ចឧបសន្យា ដែលមានសញ្ញាណទូទៅគតិយុត្តនិងលក្ខខណ្ឌព្រមទាំងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្តីចម្រើនដោយឥតហេតុ និងករណីយកិច្ចព្រមទាំងអានុភាពរបស់គូភាគីនៃធាតុបង្កុំទាំងពីរដែលកើតឡើងដោយការធ្វេសប្រហែសមិនគោរពតាមលក្ខខណ្ឌដែលច្បាប់បានចែង និងដើម្បីការពារនូវផលប្រយោជន៍របស់ជន

សុចរិតត្រឹមត្រូវចំពោះការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុ។

នៅក្នុងកិច្ចការស្រាវជ្រាវនេះ ខ្ញុំបាទនឹងធ្វើការបែងចែកជា៣ជំពូកៈ

- ជំពូកទី១ៈ កាតព្វកិច្ចឧបសន្យា ដែលសម្តៅទៅលើ សញ្ញាណទូទៅ លក្ខខណ្ឌនិងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល/ សេចក្តីចម្រើនដោយឥតហេតុ
- ជំពូកទី២ៈ ករណីយកិច្ច គឺសម្តៅទៅដល់កិច្ចការទាំងឡាយដែលត្រូវធ្វើ និងការជូនដំណឹងអំពីហេតុការណ៍ឱ្យគ្នាទៅវិញទៅមក
- ជំពូកទី៣ៈ អានុភាព សម្តៅទៅលើការទាមទារផលប្រយោជន៍ ឬការខូចខាតដែលខ្លួនបានចំណាយ និងបាត់បង់ប្រយោជន៍។

ដូចនេះ ខ្ញុំបាទនឹងធ្វើការលើកយកមកបង្ហាញ ក៏ដូចជាបកស្រាយលម្អិតទៅតាមជំពូកនីមួយៗនៅក្នុងប្រធានបទសារណានេះ។

# ជំពូកទី១
# ភាតព្វកិច្ចឧបសន្យា

## ផ្នែកទី១. ការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាកាតព្វកិច្ចមួយប្រភេទដែលមានប្រភពមកពីការកំណត់របស់ច្បាប់។ កាតព្វកិច្ចប្រភេទនេះ ហាក់ដូចជាមានលក្ខណៈផ្ទុយពី "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន"[1] ដែលបានគោរពនូវសេរីភាពនៃឆន្ទៈបុគ្គលឯកជន មានន័យថា កាតព្វកិច្ច ត្រូវបានបង្កើតឡើងតាមឆន្ទៈរបស់បុគ្គលឯកជនផ្ទាល់តែម្តងឬអាចនិយាយបានថា "មានឆន្ទៈទើបមានកាតព្វកិច្ច"។

ប៉ុន្តែផ្ទុយមកវិញ ការគ្រប់គ្រងដោយឈឺឆ្អាល ជាកាតព្វកិច្ចមួយដែលមិនបានបង្កើតឡើងតាមរយៈឆន្ទៈរបស់គូភាគីនោះទេ ពោលគឺភាគីណាមួយបានធ្វើកិច្ចការឡើងដើម្បីប្រយោជន៍ភាគីម្ខាងទៀតដោយច្បាប់បានតម្រូវឱ្យភាគីដែលមានប្រយោជន៍នោះ បង់នូវសោហ៊ុយ ព្រមទាំងកម្រៃជូនភាគីដែលបំពេញកិច្ចការនោះ។

មួយវិញទៀត ច្បាប់ចាប់បង្ខំឱ្យអនុវត្តដូចនេះ គឺដើម្បីលើកទឹកចិត្តដល់មនុស្សឱ្យចេះជួយយកអាសារគ្នាចេះសង្គ្រោះគ្នាទៅវិញទៅមកនៅក្នុងសង្គមនិងឱ្យស័ក្តិសមជាពុទ្ធសានិកដែលប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។

ការបញ្ញត្តិដូចនេះ គឺដើម្បីការពារផលប្រយោជន៍របស់បុគ្គលដែលបានឈឺឆ្អាលកុំឱ្យបាត់បង់ដោយសារតែជួយយកអាសារគេ ពោលគឺអ្នកនោះអាចទទួលយកមកវិញនូវសំណងនៃការចំណាយរួមទាំងកម្រៃទៀតផង។

គោលគំនិតសំខាន់មួយទៀតដែរនោះគឺថា ការពារបុគ្គលដែលជាអ្នកគ្រប់គ្រងឱ្យរួចផុតពីការទទួលខុសត្រូវនូវការកាន់កាប់ដោយបំពានទ្រព្យ ឬ គ្រប់គ្រងបុគ្គលផ្សេងដោយបំពាន។ ក្នុងករណីដែលអ្នកគ្រប់គ្រងនោះពិតជាមានចេតនាក្នុងការការពារផលប្រយោជន៍នៃទ្រព្យ ឬ អ្នកមានសិទ្ធិលើបុគ្គលប្រាកដមែន។

ម៉្យាងវិញទៀតដែរនេះ ក៏ជាការការពារដល់ជនឆ្លៀតឱកាសមួយចំនួន ដើម្បីទទួលបាននូវការកេងប្រវ័ញ្ច ឬ កេងបំបាត់នូវទ្រព្យសម្បត្តិរបស់ម្ចាស់ទ្រព្យដោយយកមូលហេតុដោយសារតែការគ្រប់គ្រងដោយឈឺឆ្អាល។

ហេតុផលទាំងនេះ ទើបមានលក្ខខណ្ឌច្បាប់បានកំណត់អំពីការគ្រប់គ្រងដោយឈឺឆ្អាលដែលបានកំណត់ចំពោះបុគ្គលមួយចំនួនហើយគ្មានការពឹងពាក់ទុកជាមុន និងគ្មានសិទ្ធិអំណាចចំពោះកិច្ចការទាំងនោះ។

ប៉ុន្តែជាមូលដ្ឋាន គឺជាការបង្កើតនូវទំនុកចិត្តលើគ្នា ដោយភាពសាមគ្គី ដោយសម្បុរសធម៌ សមធម៌ឱ្យសមជាប្រជាពលរដ្ឋល្អក្នុងសង្គមចេះជួយគ្នា ទើបមានបញ្ញត្តិច្បាប់នៃការគ្រប់គ្រងដោយឈឺឆ្អាលឡើងដើម្បីរំលែកទុក្ខលំបាក និងការលើកទឹកចិត្តបុគ្គលនានាក្នុងសកម្មភាពដែលជាអំពើល្អរបស់សង្គមជាតិ។

### កថាភាគទី១. សញ្ញាណទូទៅ

១. បទដ្ឋានគតិយុត្ត

ការគ្រប់គ្រងដោយឈឺឆ្អាល មានបញ្ញត្តិនៅក្នុង៖

- ✍ ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩២០ ចាប់ពីមាត្រា ៨២៥ ដល់ ៨២៦
- ✍ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចាប់ពីមាត្រា ៧២៩ ដល់ មាត្រា ៧៣៥

ការគ្រប់គ្រងដោយឈឺឆ្អាល អាចត្រូវបានធ្វើការបកស្រាយដូចខាងក្រោម៖

[1] មើលមាត្រា៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

១.១ អត្ថន័យតាមក្រមរដ្ឋប្បវេណីចាស់

មាត្រា ៨២៥ ចែងថា៖ ជនណាឥតគេពឹងរក ហើយទទួលគ្រប់គ្រងនូវសម្បត្តិនៃជនដទៃដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលការគ្រប់គ្រង លុះត្រាតែម្ចាស់គេមកគ្រប់គ្រងដោយខ្លួនឯងវិញ។ ជននោះត្រូវយកចិត្តទុកដាក់ចាត់ចែងការបីដូចជាឪពុកដ៏ប្រពៃនៃត្រកូល គឺថាទុកខ្លួនឯងដូចម្ចាស់របស់ពិតៗ និងយកចិត្តទុកដាក់នឹងផលប្រយោជន៍ទ្រព្យនោះផង[2]។

មាត្រា ៨២៦ បានចែងថា ៖ កម្មសិទ្ធិករនៃបេតិកភណ្ឌ ដែលគេគ្រប់គ្រងឱ្យដោយត្រឹមត្រូវនោះ ត្រូវសងទៅអ្នកដែលគ្រប់គ្រងនោះ នូវប្រាក់ដែលគេបានចេញចាយវាយក្នុងការជាចាំបាច់ឬក្នុងការមានប្រយោជន៍ទាំងប៉ុន្មានមួយទៅគេវិញទៀត ជននោះត្រូវគិតសោហ៊ុយនៃសេចក្តីលំបាកក្នុងការថែរក្សានោះឱ្យគេផងទៀត[3]។

តាមអត្ថន័យខាងលើនេះ យើងអាចធ្វើការទាញនូវសញ្ញាណនៃការគ្រប់គ្រងដោយឈឺឆ្អាលបានដូចខាងក្រោម៖

- គេមិនពឹង ធ្វើដោយចិត្តឯង
- ទ្រព្យសម្បត្តិអ្នកដទៃ
- បញ្ចប់ពេលម្ចាស់គេមកគ្រប់គ្រងវិញ
- គ្រប់គ្រងក្នុងនាមឪពុកដ៏ប្រពៃ
- ដើម្បីប្រយោជន៍អ្នកដទៃ

ការគ្រប់គ្រងដោយឈឺឆ្អាលនៅទីនេះ បានកំណត់យ៉ាងជាក់លាក់ គឺសម្តៅតែលើទ្រព្យសម្បត្តិប៉ុណ្ណោះ មិនបានអនុវត្តទៅលើបុគ្គលនោះទេ។ បន្ទាប់ពីស្វែងយល់អត្ថន័យតាមក្រមរដ្ឋប្បវេណីសង្គមចាស់ឆ្នាំ ១៩២០ យើងងាកមកស្វែងយល់ន័យតាមក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ដែលព្រះរាជាណាចក្រកម្ពុជាបានប្រើប្រាស់ និងកំពុងបន្តប្រើប្រាស់វិញ។

១.២ អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

ការគ្រប់គ្រងដោយឈឺឆ្អាល សម្តៅលើ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ[4] ។

តាមអត្ថន័យនេះ ការគ្រប់គ្រងដោយឈឺឆ្អាលមិនបានកំណត់ឱ្យច្បាស់លាស់លើអំពី ការគ្រប់គ្រងលើទ្រព្យ ឬមនុស្ស ដូចនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់នោះទេ។

ការគ្រប់គ្រងដោយឈឺឆ្អាល ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរថ្មីឆ្នាំ២០០៧ នេះគឺគ្រាន់តែបញ្ញត្តិពីការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃប៉ុណ្ណោះ ដោយមិនបានកំណត់អំពីការគ្រប់គ្រង ទ្រព្យសម្បត្តិ ឬបុគ្គលទេ។

---

[2] សមាគមស្រាវជ្រាវ និង ផ្សព្វផ្សាយច្បាប់ខ្មែរ, វាយឡើងវិញក្រៅផ្លូវការ, ក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់ឆ្នាំ ១៩២០ ( ភ្នំពេញ៖ សមាគមស្រាវជ្រាវ និង ផ្សព្វផ្សាយច្បាប់ខ្មែរ , ឆ្នាំ ២០១៥,), ទំព័រ ១៩៣ ។

[3] សមាគមស្រាវជ្រាវ និង ផ្សព្វផ្សាយច្បាប់ខ្មែរ, វាយឡើងវិញក្រៅផ្លូវការ, ក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់ឆ្នាំ ១៩២០ ( ភ្នំពេញ៖ សមាគមស្រាវជ្រាវ និង ផ្សព្វផ្សាយច្បាប់ខ្មែរ , ឆ្នាំ ២០១៥,) ទំព័រ ១៩៣

[4] មើលមាត្រា៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី ១ ក្រមរដ្ឋប្បវេណី២០០៧

ឧទាហរណ៍៖

លោក **ក** បានចេញទៅលេងសៀមរាបចំនួន ០៣ ថ្ងៃ ដោយគ្មានអ្នកណានៅចាំផ្ទះទេ។ ខណៈនោះក៏មានភ្លៀង និងខ្យល់ខ្លាំងបានធ្វើឱ្យដំបូលផ្ទះរបស់លោក **ក** ប៉ើងនិងធ្លុះធ្លាយដែលបណ្តាលឱ្យមានភ្លៀងស្រក់លិចចូលក្នុងផ្ទះ។ លោក **ខ** ដែលជាអ្នកជិតខាងនឹងលោក **ក** បានឃើញដូចនោះ ក៏បានជួលឱ្យជាងទិញស័ង្កសីដើម្បីជួសជុលផ្ទះឱ្យលោក **ក** ។

ករណីនេះ បញ្ជាក់ថា លោក **ខ** គឺ ធ្វើការគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃក្នុងអំឡុងពេលដែលលោក **ក** មិនបាននៅផ្ទះ។

គោលគំនិតនៃមាត្រានេះ គឺចង់ឱ្យបុគ្គលម្នាក់ៗចេះជួយគ្នាទៅវិញទៅមកដោយមិនប្រកាន់វណ្ណៈឬរើសអើង និងមិនឱ្យមើលនឹងភ្នែកចំពោះហេតុការណ៍ដែលបានកើតឡើង។

២. ឯកសារពាក់ព័ន្ធ

២.១ អត្ថន័យតាមពាក្យពេចន៍

ការគ្រប់គ្រងដោយឃើញ្ណាល បានពីការបន្សំគ្នារវាងពាក្យ ការគ្រប់គ្រង បូកផ្សំ(+) ពាក្យ ឈើឆ្នាល[5]។

✍ ការគ្រប់គ្រង មានអត្ថន័យដូចខាងក្រោម៖

- ការគ្រប់គ្រង អាចជាការគ្រប់គ្រងមនុស្ស និងការគ្រប់គ្រងលើទ្រព្យ។
- ការគ្រប់គ្រង អាចជាការគ្រប់គ្រងដោយផ្ទាល់ និងដោយប្រយោល។
- ការគ្រប់គ្រង នាំឱ្យមានការពិចារណាទៅលើរបៀបនៃការគ្រប់គ្រងដែលជាគោលការណ៍ការគ្រប់គ្រងត្រូវចាំបាច់នាំឱ្យមានលក្ខណៈល្អប្រសើរ ត្រឹមត្រូវ និងជាទុកចិត្តបាន។
- ការគ្រប់គ្រង នាំឱ្យមានទំនួលខុសត្រូវលើការគ្រប់គ្រងករណីមានព្យសនកម្មកើតឡើងដោយការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង។
- ការគ្រប់គ្រងលើមនុស្ស អាចជាការគ្រប់គ្រងលើបុគ្គលដែលស្ថិតក្នុងបន្ទុកគ្រួសារ និងការគ្រប់គ្រងបុគ្គលិកមន្ត្រីក្រោមឱវាទ។
- ការគ្រប់គ្រងលើទ្រព្យអាចជាការគ្រប់គ្រងទ្រព្យជាកម្មសិទ្ធិផ្ទាល់ខ្លួន និងការគ្រប់គ្រងទ្រព្យជាកម្មសិទ្ធិអ្នកដទៃ។
- ការគ្រប់គ្រងទ្រព្យដែលជាកម្មសិទ្ធិអ្នកដទៃ អាចជាការគ្រប់គ្រងតាមរយៈកិច្ចសន្យា និងគ្មានកិច្ចសន្យា។
- ការគ្រប់គ្រង បានបង្កប់នូវការទទួលបាននូវតម្លៃតបស្នង ឬផលកម្រៃដែលបានមកពីការគ្រប់គ្រង។
- ការគ្រប់គ្រង នាំឱ្យមានការចំណាយលើការគ្រប់គ្រង ដែលគួរពិចារណាលើបន្ទុកក្នុងការចំណាយ។

✍ ការឈើឆ្នាល មានអត្ថន័យដូចខាងក្រោមនេះ

- ការឈើឆ្នាល គឺជាការយកអាសារ ជួយធ្វើការដោះទុក្ខធុះគេផ្សេងៗ។
- ការឈើឆ្នាល នាំឱ្យមានការគិតដល់ថា មានកិច្ចការដែលត្រូវបំពេញ ឬបញ្ហាបានកើតឡើងដែលមិនមែនជាបញ្ហារបស់ខ្លួន។
- ការឈើឆ្នាល សម្តៅលើបុគ្គលដែលឈើឆ្នាលដោយមិនមានការទទួលបានសិទ្ធិអំណាចក្នុងការដោះស្រាយពីដំបូង ឬគ្មានការយល់ព្រមឱ្យដោះស្រាយបញ្ហាជាមុនឡើយ។

[5] មើលស្លាយសិក្សាអំពី ការគ្រប់គ្រងដោយឃើញ្ណាល របស់លោក គង់ តារាឆាត

- ការឈឺឆ្អាល នាំឱ្យមានការពិចារណាដល់ថា ការបំពេញកិច្ចទាំងឡាយ គឺដើម្បីផលប្រយោជន៍អ្នកដទៃ ដែលមិនមែនជាប្រយោជន៍របស់អ្នកឈឺឆ្អាលនោះទេ។
- ការឈឺឆ្អាល នាំឱ្យមានការដឹងគុណពីអ្នកមានបញ្ហា ឬការមិនសប្បាយចិត្តពីអ្នកមានបញ្ហា។
- ការឈឺឆ្អាល នាំឱ្យមានការបំពេញកិច្ចការណាមួយឬច្រើន។

✍ ការគ្រប់គ្រងដោយឈឺឆ្អាល នាំឱ្យមានសញ្ញាណមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងលើមនុស្ស ឬទ្រព្យដែលស្ថិតនៅក្នុងបន្ទុកឬ ជាកម្មសិទ្ធិរបស់អ្នកដទៃ។
- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងដោយអ្នកគ្រប់គ្រងដោយឈឺឆ្អាល គ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង។
- ការគ្រប់គ្រងដោយឈឺឆ្អាល នាំឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចមានការចំណាយលើការគ្រប់គ្រងដែលអ្នកគ្រប់គ្រង អាចនឹងត្រូវទទួលបានត្រលប់មកវិញ។
- អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចត្រូវទទួលបានកម្រៃដែលជួយបង្កើនតម្លៃលើទ្រព្យនោះដែលបណ្តាលមកពីការគ្រប់គ្រងរបស់ខ្លួន។
- ការគ្រប់គ្រងដោយឈឺឆ្អាល អាចនាំឱ្យអ្នកគ្រប់គ្រងទទួលខុសត្រូវនូវកំហុសរបស់ខ្លួន។

២.២ អត្ថន័យតាមសេចក្តីផ្តើមនីតិរដ្ឋប្បវេណី

យោងតាមសេចក្តីផ្តើមនីតិរដ្ឋប្បវេណី ការគ្រប់គ្រងដោយឈឺឆ្អាល គឺសម្តៅលើការអនុវត្តកិច្ចការដើម្បីអ្នកដទៃ បើទោះបីជាខ្លួនគ្មានករណីយកិច្ចតាមច្បាប់ដូចជា ករណីយកិច្ចដោយកិច្ចសន្យាឬក៏ករណីយកិច្ចដោយយោងតាមបញ្ញត្តិច្បាប់ក៏ដោយ[6]។

ឧទាហរណ៍៖

ដូចជាក្នុងអំឡុងពេលដែលអ្នកជិតខាងធ្វើដំណើរកម្សាន្តទាំងគ្រួសារទៅបរទេស មានខ្យល់ព្យុះដ៏ខ្លាំងធ្វើឱ្យដំបូលផ្ទះមួយផ្នែករបស់អ្នកជិតខាងនោះ បើទោះបីជាអ្នកជិតខាងមិនបានពឹងក៏ដោយ។

ក្នុងករណីនេះ បុគ្គលដែលបានអនុវត្តកិច្ចការដើម្បីអ្នកដទៃហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល រីឯបុគ្គលដទៃដែលទទួលផលប្រយោជន៍(ក្នុងករណីឧទាហរណ៍ខាងលើនេះ គឺអ្នកជិតខាង) ហៅថា សាមីខ្លួន។

ក្នុងឧទាហរណ៍ដែលបានលើកឡើង ប្រសិនបើខ្លួនបានទទួលនូវការស្នើសុំពីអ្នកជិតខាងឱ្យជួយគ្រប់គ្រងផ្ទះក្នុងអំឡុងពេលអវត្តមានរបស់អ្នកជិតខាង កិច្ចសន្យាអាណត្តិរវាងភាគីបានកើតឡើង ដោយសារការគ្រប់គ្រងផ្ទះពុំមែនជាសកម្មភាពគតិយុត្ត បើនិយាយឱ្យជាក់លាក់នេះគឺជាអាណត្តិមិនពេញលេញ។

ដូច្នេះ ការជួលឱ្យជាងមកធ្វើការជួសជុលដំបូលផ្ទះនេះ គឺអនុលោមទៅតាមកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យា។

ក៏ប៉ុន្តែ ក្នុងករណីដែលមិនត្រូវបានស្នើសុំដោយអ្នកជិតខាងទេ គឺគ្មានករណីយកិច្ចទៅជួសជុលដំបូលផ្ទះនោះទេ។ តែសកម្មភាពជួលជាងមកជួសជុលដំបូលផ្ទះឱ្យអ្នកជិតខាង បើទោះបីជាមិនមានការពឹងពាក់ពីអ្នកជិតខាងក៏ដោយ ។សកម្មភាពបែបនេះហើយ គឺជាការគ្រប់គ្រងដោយឈឺឆ្អាល។

[6] សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី ៥ ( ភ្នំពេញ, ឆ្នាំ ២០១១,), ចំណុច ក ទំព័រ ១១៣

ម្យ៉ាងវិញទៀត ការជួយមនុស្សដែលកំពុងលង់ទឹកក៏ដូចជាឧទាហរណ៍ទីមួយនៃការគ្រប់គ្រងដោយឈឺឆ្អាលដែរ។

ក៏ប៉ុន្តែ ក្នុងករណីដែលមានករណីយកិច្ចត្រូវជួយសង្គ្រោះតាមច្បាប់ តាមតួនាទី ភារកិច្ចរបស់ខ្លួនជាដើម។

ឧទាហរណ៍៖

កងកម្លាំងនគរបាល ឬភ្នាក់ងារពន្លត់អគ្គិភ័យ ដែលទាក់ទងទៅលើករណីយកិច្ចត្រូវជួយសង្គ្រោះតាមច្បាប់តម្រូវ តាមតួនាទីភារកិច្ចនោះ។

ការជួយសង្គ្រោះបែបនេះ គឺជាការអនុលោមតាមករណីយកិច្ចរបស់ខ្លួនពុំមែនជាការគ្រប់គ្រងដោយឈឺឆ្អាលទេ។

ក្រោយពីសិក្សាពីសញ្ញាណគតិយុត្តគតិយុត្តនៃការគ្រប់គ្រងដោយឈឺឆ្អាលវិញ។ យើងងាកមកសិក្សាពីលក្ខខណ្ឌនិងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាលវិញ ។

## កថាភាគទី២. លក្ខខណ្ឌនិងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល

### ១. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល

#### ១.១ លក្ខខណ្ឌគ្រឹះ

ដើម្បីឱ្យសកម្មភាពមួយ អាចត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលបាន លុះត្រាតែសកម្មភាពនោះបានកើតចេញពីឆន្ទៈគ្រប់គ្រង ដោយពិតប្រាកដ សុចរិត គ្មានវិការៈ ដោយសេរី និងធ្វើឡើងដោយជនដែលមានសមត្ថភាពគ្រប់គ្រាន់តាមដែលច្បាប់បានកំណត់។

##### ១.១.១ សមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈ សម្តៅដល់ការធ្វើសកម្មភាពដែលភាគីបានធ្វើក្នុងស្ថានភាពដែលខ្លួនបានយល់ដឹងនិងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន[7]។

របបស្តីពីសមត្ថភាពខាងឆន្ទៈនេះ គឺមានគោលបំណងការពារផលប្រយោជន៍ដើម្បីកុំឱ្យមានការខូចខាតដោយកិច្ចការរបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រងក្នុងការវិនិច្ឆ័យ។

ឧទាហរណ៍៖

អាចលុបចោលសកម្មភាពឬកិច្ចការដែលខ្លួនបានធ្វើហើយ ដោយខ្លួនបានអះអាងថាដោយសារតែខ្លួនបានបរិភោគស្រាច្រើនហួសហេតុដែលមានឥទ្ធិពលធ្វើឱ្យចុះខ្សោយយ៉ាងខ្លាំងពីការវិនិច្ឆ័យជាដើម ដូចជាសាមីខ្លួនស្ថិតក្នុងស្ថានភាពស្រវឹងស្រានៅពេលដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានទាក់ទងមកខ្លួនដើម្បីចាប់ផ្តើមការគ្រប់គ្រង។

ដូច្នេះ ករណីខាងលើនេះ ជនដែលអះអាងថាខ្លួនបាត់បង់សមត្ថភាពនៃឆន្ទៈអាចលុបចោលសកម្មភាពនេះបាន ។

សកម្មភាពរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលក្នុងន័យនេះតាមច្បាប់កំណត់វាគឺជាសកម្មភាពឯកតោភាគី ។

សកម្មភាពឯកតោភាគី សម្តៅលើករណីដែលកាតព្វកិច្ចកើតឡើងដោយសារឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសកម្មភាពនិងសិទ្ធិ តាមបញ្ញត្តិនៃច្បាប់។

[7] មើលមាត្រា ១៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

### ១.១.២ សមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពក្នុងការធ្វើសកម្មភាព គឺរបបសមត្ថភាពក្នុងការធ្វើសកម្មភាព និងជារបបការពារកុំឱ្យមានការសងខូចខាត ដែលកើតឡើងដោយសារកិច្ចការរបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យដោយការពារមិនឱ្យជនក្នុងប្រភេទមួយចំនួនបង្កើតនូវសកម្មភាពគតិយុត្តដែលមានសុពលភាពតាមផ្លូវច្បាប់។

ជនទាំងនោះមាន អនីតិជន ជននៅក្រោមរបបអាណាព្យាបាលទូទៅ និងជនដែលនៅក្រោមហិតូបត្ថម្ភ ហើយ ជនទាំងនេះ គឺជាជនដែលត្រូវកម្រិតសមត្ថភាពក្នុងការសកម្មភាពគតិយុត្ត។

ចំពោះជនដែលមានការពិបាកនៅក្នុងការសម្រេចសេចក្តីពេលធ្វើសកម្មភាពដោយសារការខ្វះសមត្ថភាពនៅក្នុងការវិនិច្ឆ័យគ្រប់គ្រាន់បានដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីមានពីរប្រភេទ គឺជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលនៅក្រោមហិតូបត្ថម្ភ។

ចំណែកជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពគឺជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ។

- ឧទាហរណ៍៖

សកម្មភាពដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព មានសុពលភាពពេញលេញ។ ប្រសិនបើពុំមានមូលហេតុផ្សេងៗដែលនាំឱ្យមោឃៈឬមូលហេតុដែលអាចលុបចោលសកម្មភាពនោះ។

### ១.២ លក្ខខណ្ឌទម្រង់

ដើម្បីចាត់ទុកថា សកម្មភាពឬអំពើណាមួយចូលក្នុងលក្ខខណ្ឌទម្រង់នៃការគ្រប់គ្រងដោយឈឺឆ្អាល លុះត្រាតែការគ្រប់គ្រងនោះ ចាំបាច់ត្រូវធ្វើឡើងដោយគ្មានសិទ្ធិអំណាច ដើម្បីបុគ្គលដទៃ ហើយអ្នកគ្រប់គ្រងបានចាប់ផ្តើមគ្រប់គ្រងដោយប្រើវិធីសមរម្យបំផុត ឬផ្អែកតាមឆន្ទៈរបស់បុគ្គលដែលជាសាមីខ្លួន[8]។

លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបានសិក្សាស្វែងយល់ពី៖

- ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច
- ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ
- ការចាប់ផ្តើមកិច្ចគ្រប់គ្រងហើយការគ្រប់គ្រងនោះដែរត្រូវធ្វើឡើងដោយវិធីសមរម្យថែមទាំងត្រូវផ្អែកតាមឆន្ទៈរបស់ម្ចាស់ទ្រព្យទៀតផង។

### ១.២.១ ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច

ភាពគ្មានសិទ្ធិអំណាច សម្តៅលើស្ថានភាពមួយដែលបុគ្គលដែលជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនមានសិទ្ធិ ឬមិនទទួលបាននូវសិទ្ធិអំណាចក្នុងការគ្រប់គ្រងលើមនុស្ស ឬទ្រព្យនោះ [9]។

ប្រសិនបើមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងដូចជា កិច្ចសន្យាអាណត្តិនោះនាំឱ្យការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានអនុវត្តទេ ព្រោះភាគីត្រូវអនុវត្តដោយអនុលោមតាមសិទ្ធិអំណាចនៃការគ្រប់គ្រងនោះ ហើយនោះមិនមែនជាបញ្ហានៃការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។

---

[8] មើលមាត្រា៧២៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[9] មើលមាត្រា ៧២៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

យើងអាចមើល ក្នុងករណីលែងលះរវាងប្តីប្រពន្ធដែលតុលាការសម្រេចផ្តល់សិទ្ធិអំណាចមេបាដល់ប្រពន្ធដែលជាម្តាយនៃកូនហើយតុលាការចេញដីកាសម្រេចបង្គាប់ឱ្យឪពុកបំពេញអាហារកាតព្វកិច្ចឬបង់ប្រាក់រហូតកូនក្លាយជានីតិជន។

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែមិនមែនជាអ្នកមានអំណាចមេបាលើអ្នកដែលខ្លួនគ្រប់គ្រងនោះទេ។

ផ្ទុយទៅវិញ ឪពុកដែលមិនមានអំណាចមេបាតាមដីកាសម្រេចតុលាការនោះ ពេលដែលខ្លួនបានគ្រប់គ្រងកូនរបស់ខ្លួនតាមរយៈការបង់អាហារកាតព្វកិច្ចក៏មិនអាចទាមទារសោហ៊ុយ ឬកម្រៃដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលបានដែរ។

អ្នកអាណាព្យាបាលទូទៅ ដែលជាអ្នកតំណាងតាមច្បាប់កំណត់របស់ជននៅក្រោមអាណាព្យាបាលទូទៅក៏មិនអាចអះអាងអាចថាខ្លួនធ្វើការគ្រប់គ្រង និងថែរក្សាជននៅក្រោមអាណាព្យាបាលទូទៅ គឺជាការគ្រប់គ្រងដោយឈឺឆ្អាលបានដែរដោយហេតុថាទំនាក់ទំនងនៃរបបអាណាព្យាបាលទូទៅនេះ គឺត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់តុលាការដែលមិនមែនជាស្ថានភាពដែលអ្នកអាណាព្យាបាលគ្មានសិទ្ធិ អំណាចគ្រប់គ្រងនោះទេ[10]។

ហិតូបត្ថម្ភកៈ ដែលជាអ្នកតំណាងឱ្យជននៅក្រោមហិតូបត្ថម្ភក៏មិនអាចទាមទារសោហ៊ុយនៃការគ្រប់គ្រងដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ដោយហេតុទំនាក់ទំនងនៃរបបហិតូបត្ថម្ភនេះក៏ត្រូវបានបង្កើតឡើងតាមរយៈដីកាសម្រេចតុលាការដែរ[11]។

១.២.២ ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ

ដើម្បីឱ្យសកម្មភាពមួយអាចត្រូវបានចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលបាននោះអ្នកគ្រប់គ្រងចាំបាច់ត្រូវគ្មានវិការៈក្នុងការបង្ហាញឆន្ទៈគ្រប់គ្រងកិច្ចការ ដើម្បីបុគ្គលដទៃ។

បុគ្គលដទៃ សម្តៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាញាតិរបស់ខ្លួនឯង។ យោងតាមក្រមរដ្ឋប្បវេណី បានកំណត់ពីបុគ្គលដែលត្រូវបានចាត់ទុកថាជា ញាតិ គឺសម្តៅលើញាតិលោហិតក្នុង ៦ថ្នាក់ សហព័ទ្ធ និង ញាតិពន្ធក្នុង ៣ ថ្នាក់[12]។

✍ សម្គាល់៖

- ញាតិលោហិតក្នុង ៦ ថ្នាក់ (ញាតិលោហិតខ្សែផ្ទាល់ក្នុង៦ថ្នាក់) មាន បុព្វញាតិ និងបច្ឆាញាតិ ។ បុព្វញាតិ គឺយើងត្រូវរាប់ពីសាមីខ្លួនឡើងទៅលើ៖

- បុព្វញាតិថ្នាក់ទី៦ ហៅថាជីប៉ា
- បុព្វញាតិថ្នាក់ទី៥ ហៅថាជីលា
- បុព្វញាតិថ្នាក់ទី៤ ហៅថាជីលួត
- បុព្វញាតិថ្នាក់ទី៣ ហៅថាជីទួត
- បុព្វញាតិថ្នាក់ទី២ ហៅថាជីដូន ជីតា

---

[10] មើលមាត្រា២៤ កថាខណ្ឌទី ១នៃ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[11] មើលមាត្រា២៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[12] មើលមាត្រា មាត្រា២៨ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

- បុព្វញាតិថ្នាក់ទី១ ហៅថាឪពុក ម្តាយ
- សាមីខ្លួន

- រីឯ បច្ឆាញាតិវិញ គឺយើងត្រូវពីសាមីខ្លួនចុះក្រោម៖

- សាមីខ្លួន
- បច្ឆាញាតិថ្នាក់ទី១ ហៅថាកូន
- បច្ឆាញាតិថ្នាក់ទី២ ហៅថាចៅ
- បច្ឆាញាតិថ្នាក់ទី៣ ហៅថាចៅទួត
- បច្ឆាញាតិថ្នាក់ទី៤ ហៅថាចៅលួត
- បច្ឆាញាតិថ្នាក់ទី៥ ហៅថាចៅលា
- បច្ឆាញាតិថ្នាក់ទី៦ ហៅថាចៅប៉ា

- ញាតិពន្ធក្នុង៣ថ្នាក់វិញ

- បុព្វជន
- បងប្អូនថ្លៃ
- ក្មួយប្រសារ ។

តាមខ្លឹមសារនេះ ការគ្រប់គ្រងកិច្ចការដើម្បីញាតិខ្លួនឯង ទោះបីជាលក្ខខណ្ឌទាំងឡាយនៃការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបានបំពេញក៏មិនមែនជា ការគ្រប់គ្រងដោយឈឺឆ្អាលដែរ។

ដូច្នេះ អ្នកគ្រប់គ្រងមិនអាចទាមទារឱ្យម្ចាស់ទ្រព្យ ឬសាមីខ្លួនដែលជាញាតិរបស់អ្នកគ្រប់គ្រងនោះបង់សោហ៊ុយ និងកម្រៃ ដោយសារការគ្រប់គ្រងដែរឬយ៉ាងណា?

បើដូច្នេះមែន ទោះបីមានទំនាក់ទំនងញាតិរវាងគ្នាក្តី ក៏រវាងញាតិម្នាក់ៗ នឹងមិនជួយគ្នាទៅវិញទៅមកតទៅទៀត ព្រោះការជួយបានត្រឹមតែចំណាយទ្រព្យសម្បត្តិផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

- ឧទាហរណ៍៖

បុរស **ក** មានផ្ទះមួយកន្លែងនៅខេត្តកំពង់ស្ពឺ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយ នារី **ខ** ។ ផ្ទះនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់បុរស **ក**។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមក ថ្ងៃមួយនារី **ខ** ដែលជាប្រពន្ធរបស់ឈ្មោះ **ក** បានទៅធ្វើការនៅកំពង់សោម ។ នៅពេលធ្វើដំណើរនោះ ឈ្មោះ **ខ** ក៏បានឃើញផ្ទះរបស់ឈ្មោះ **ក** ផ្ទះដំបូល ពេលនោះខ្លួនក៏ជួលជាងដើម្បីមកជួសជុលឱ្យ ។

តើករណីនេះចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលឬទេ?

តាមរយៈអត្ថន័យនៃបុគ្គលដទៃខាងលើនេះ យើងសង្កេតឃើញថា អត្ថន័យ បុគ្គលដទៃ មានភាពសមរម្យ និង អាចយកមកអនុវត្តបាននៅក្នុងបរិបទនៃការគ្រប់គ្រងដោយឈឺឆ្អាលនៅក្នុងក្រមរដ្ឋប្បវេណីបានទោះបីជាមានបញ្ហាដូចបានលើកឡើងខាងលើក៏ដោយ ។

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ ប្តីប្រពន្ធមានករណីយកិច្ចរួមរស់ជីវភាព សហការ និង សង្គ្រោះគ្នាទៅវិញទៅមក[13]។

---

[13] មើលមាត្រា ៩៦៦ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

វាមានន័យថា អាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ និងសេដ្ឋកិច្ចនៃប្ដីប្រពន្ធ ដូច្នេះ ទើបមានមាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីបានប្រកាសថា ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយសង្គ្រោះគ្នាទៅវិញទៅមក ។

រីឯមាត្រា ២៩ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសាររបស់ប្រទេសកម្ពុជាគាំទ្រថា ប្ដីប្រពន្ធត្រូវបានភាពស្មើភាពគ្នាលើគ្រប់ទស្សនៈ។

ដូច្នេះ តាមខ្លឹមសារនេះ វាជាករណីពិសេស ដែលប្ដីឬប្រពន្ធអាចធ្វើការគ្រប់គ្រងកិច្ចការ ដើម្បីសហព័ទ្ធរបស់ខ្លួនរៀងៗខ្លួនបានដោយមិនចាត់ទុកជា ការគ្រប់គ្រងដោយឈឺឆ្អាលបានឡើយ ព្រោះថាការគ្រប់គ្រងដោយឈឺឆ្អាលធ្វើឡើងដើម្បីបុគ្គលដទៃតាមច្បាប់គឺការពារនិងធ្វើឱ្យអ្នកដទៃទទួលបានផលប្រយោជន៍ដោយការគ្រប់គ្រងនេះ។

ការគ្រប់គ្រងដើម្បីជាប្រយោជន៍នៅទីនេះ មិនសម្ដៅតែចំពោះសាមីខ្លួនប៉ុណ្ណោះទេ។ គេអាចចាត់ទុកថាមានការគ្រប់គ្រងដោយឈឺឆ្អាល កាលណាអ្នកគ្រប់គ្រងមានទាំងឆន្ទៈគ្រប់គ្រងធ្វើការគ្រប់គ្រង ដើម្បីខ្លួនឯង និងដើម្បីសាមីខ្លួន ។

- ឧទាហរណ៍៖

ប្រសិនបើច្រាំងទន្លេទំនងជាត្រូវបាក់ដោយសារកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេណាម្នាក់ ចាត់វិធានការជាបន្ទាន់ ដើម្បីទប់កុំឱ្យច្រាំងបាក់ ដើម្បីការពារមិនមែនតែផ្ទះខ្លួនឯងប៉ុណ្ណោះទេ គឺដើម្បីការពារផ្ទះអ្នកជិតខាងដែរ សកម្មភាពបែបនេះនឹងត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល[14]។

### ១.២.៣ អ្នកគ្រប់គ្រងចាប់ផ្ដើមគ្រប់គ្រងកិច្ចការ

ការចាប់ផ្ដើមបំពេញកិច្ចការ សម្ដៅការចាប់ផ្ដើមបំពេញកិច្ចការគតិយុត្ត ការចាប់ផ្ដើមសកម្មភាពដទៃផ្សេងទៀង ។ សកម្មភាពគតិយុត្តនៅពេលនេះ សម្ដៅទៅលើសកម្មភាពឯកតោភាគី [15]។

រីឯសកម្មភាពដទៃផ្សេងទៀតនោះ សម្ដៅលើសកម្មភាពដែលបុគ្គលម្នាក់ចាប់ផ្ដើមជួសជុល ឬបំពេញជាដើម។

- ឧទាហរណ៍៖

លោក **ក** មានផ្ទះមួយខ្នងនៅជាប់ផ្ទះ លោក **ខ** ។ លោក **ក** បានធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ។ នៅថ្ងៃមួយមានភ្លៀង និង ខ្យល់បោកបក់យ៉ាងខ្លាំង បណ្ដាលឱ្យផ្ទះលោក **ក** បានរបើកស័ង្កសីអស់ចំនួន ៥ផ្ទាំង ។ លោក **ខ** ឃើញដូចនេះក៏បានទៅទិញស័ង្កសីយកមកប្រក់ផ្ទះជូនលោក **ក** វិញ ព្រោះខ្លួនគិតថា ប្រសិនបើមិនធ្វើដូច្នេះទេ ទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះរបស់លោក **ក** នឹងខូចខាត ឬ បាត់បង់ជាមិនខាន។សកម្មភាពដែលលោក **ក** បានទៅទិញស័ង្កសី គឺមានន័យថា លោក **ក** បានចុះកិច្ចសន្យាទិញលក់ស័ង្កសីជាមួយនិងអ្នកលក់។ រីឯ លោក **ក** បានចាប់ផ្ដើមយកមកប្រក់ស័ង្កសីនេះ គឺជាសកម្មភាពឯកតោភាគី ដែលលោក **ក** បានធ្វើឡើងដើម្បីលោក **ខ** ។

ករណីនេះ លោក **ក** ក៏អាចជួលជាង ដើម្បីមកប្រក់ស័ង្កសីជូនលោក **ខ** បានដែរ (គឺជាកិច្ចសន្យារវាងលោក

[14] មើលសេចក្ដីកំណត់ ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី៥ ,ជំពូកទី ១៤ មាត្រា ៧២៩

[15] មើលមាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

**ក** និង ជាង)។

១.២.៤ ការគ្រប់គ្រងត្រូវធ្វើឡើងដោយវិធីសមរម្យនិង ដោយផ្អែកតាមឆន្ទៈ

ដើម្បីការពារដល់សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុដោយការគ្រប់គ្រងដោយឈើឆ្កាលនោះ វីក៏ជាការធ្វើឱ្យបានត្រឹមត្រូវយុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិត និងឆ្លើយតបទៅនឹងអំពើមនុស្សធម៌ ប្រកបដោយសីលធម៌ និងសមធម៌រវាងបុគ្គលឯកជន។

ជារួម គឺអ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងឱ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងនោះ។

ចំពោះ វិធីដែលសមរម្យជាងគេ ប្រសិនបើអ្នកគ្រប់គ្រងដឹង ឬគួរតែបានដឹងអំពីឆន្ទៈរបស់សាមីខ្លួនអ្នកគ្រប់គ្រងនោះ ត្រូវគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ[16] ។

ប៉ុន្តែប្រសិនបើ អ្នកគ្រប់គ្រង មិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺត្រូវកំណត់ដោយសត្យានុម័តឬ ភាពជាក់ស្តែងដែលកើតឡើង។

- ឧទាហរណ៍៖

នៅពេលដែល **ក** បានជួយសង្គ្រោះ **ខ** ដែលបានលង់ទឹកដែលតាមពិតគឺ **ខ** ធ្វើអត្តឃាតដោយមិនបានដឹងអំពីឆន្ទៈ **ខ** នោះការជួយសង្គ្រោះបែបនេះ គឺត្រូវចាត់ទុកថាជា វិធីដែលសមស្របជាងគេ ពីព្រោះការជួយសង្គ្រោះបុគ្គលណាម្នាក់ដែលលង់ទឹក គឺស្របទៅតាមវិធីដែលសមរម្យជាងគេតាមការជាក់ស្តែង។ ប៉ុន្តែក៏មានករណីលើកលែងផងដែរ [17]។

ចំពោះការគោរពតាមឆន្ទៈ គឺប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬអាចដឹងពីឆន្ទៈរបស់សាមីខ្លួនអ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ [18]។

ប៉ុន្តែក៏នៅតែមានករណីលើកលែងផងដែរ គឺក្នុងករណីដឹងថា សាមីខ្លួនចង់ធ្វើអត្តឃាតដោយលោតទឹកដោយបានដឹងថា សាមីខ្លួនធ្វើអត្តឃាត ហើយអ្នកគ្រប់គ្រងបានជួយសង្គ្រោះគាត់ដោយយកទៅព្យាបាលនៅឯមន្ទីរពេទ្យហើយបានបង់ថ្លៃសោហ៊ុយព្យាបាលអស់ចំនួន១០០$ ប៉ុន្តែតែសាមីខ្លួនបដិសេធមិនបង់ថ្លៃសោហ៊ុយព្យាបាលទេ ដោយអះអាងថា ការជួយសង្គ្រោះគាត់ គឺផ្ទុយនឹងឆន្ទៈរបស់គាត់។

បើយើងគោរពតាមឆន្ទៈរបស់សាមីខ្លួន សាមីខ្លួនមិនត្រូវសងតម្លៃចំពោះអ្នកគ្រប់គ្រងដែលបានបង្ហាញឆន្ទៈរបស់គាត់ដែលបានបង្ហាញឱ្យសាមីខ្លួននោះទេ។

ករណីខាងនេះគឺជា បញ្ហាមួយលំបាកមួយហើយប្រហែលជា បញ្ហាខាងសីលធម៌ថែមទៀតផង។

ការបកស្រាយមួយដែលអាចមានគឺអ្នកគ្រប់គ្រងមិនអាចទាមទារសំណងទេដោយសារតែការជួយសង្គ្រោះនេះ គឺផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ។

ការបកស្រាយមួយទៀតដែលអាចមានដែរគឺ អ្នកគ្រប់គ្រងមិនត្រូវធ្វើឬបណ្តោយតាមឆន្ទៈសាមីខ្លួននោះទេពីព្រោះវាផ្ទុយនឹងសីលធម៌ល្អ [19]។

---

[16] មើលមាត្រា ៧២៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[17] មើលមាត្រា ៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[18] មើលមាត្រា ៧២៩ កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[19] មើលមាត្រា៣៥៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

២. ប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល

២.១ ការគ្រប់គ្រងត្រូវធ្វើឡើងចំពោះបុគ្គល និងទ្រព្យ

២.១.១ ចំពោះបុគ្គល

ការគ្រប់គ្រងដោយឈឺឆ្អាលចំពោះបុគ្គល គឺការផ្តោតសំខាន់ទៅលើរូបវ័ន្តបុគ្គលដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព និងផលប្រយោជន៍ទាក់ទងនឹងបុគ្គលនេះ ។

ក្នុងករណីបុគ្គលនេះ មិនអាចជួយខ្លួនឯងបាននៅពេលជួបគ្រោះថ្នាក់ ឬស្ថានភាពអាសន្ន ឬឧបទ្ទវហេតុណាមួយដោយចៃដន្យ ហើយត្រូវអ្នកដទៃជួយសង្គ្រោះក្នុងន័យចេះជួយយកអាសារមើលថៃរក្សាគ្នាដោយប្រព្រឹត្តទៅតាមគន្លងសីលធម៌របស់សង្គម។

- ឧទាហរណ៍៖

លោក **ក** មានកូនពីរនាក់ ដោយម្នាក់មានអាយុ៥ឆ្នាំ និងម្នាក់ទៀតអាយុ៧ឆ្នាំ នៅពេលចេញទៅធ្វើការគាត់ភ្លេចទុកលុយឱ្យកូនទិញចំណីអាហារញ៉ាំរយៈពេលមួយថ្ងៃ។ លោក **ខ** ជាអ្នកជិតខាងបានឃើញកូនរបស់លោក **ក** ទាំងពីរកំពុងជួបប្រទះនឹងបញ្ហាអត់ឃ្លាន ក្នុងស្ថានភាពលោក **ក** មិននៅ ហើយលោក **ខ** បានចំណាយលុយទិញចំណីអាហារឱ្យកូនលោក **ក** ញ៉ាំដើម្បីចៀសវាងការអត់អាហារស្លាប់។

២.១.២ ចំពោះទ្រព្យសម្បត្តិ

ការគ្រប់គ្រងលើទ្រព្យសម្បត្តិ សម្តៅលើពេលដែលបុគ្គលអវត្តមានពីលំនៅដ្ឋាន ឬទីសំណាក់ ឬទីកន្លែងនៃទ្រព្យ ហើយមិនអាចមានលទ្ធភាពវិលត្រឡប់មកគ្រប់គ្រងវិញបាន។

ក្នុងកាលៈទេសៈនេះ បុគ្គលដទៃមកធ្វើការគ្រប់គ្រងដើម្បីការពារនូវអត្ថប្រយោជន៍នៃទ្រព្យសម្បត្តិនេះ កុំឱ្យមានការបាត់បង់ឬខូចខាតដែលគេភាគច្រើននិយាយថាមើលនឹងភ្នែក។

វាមានន័យថា កិច្ចនេះបង្កើតនូវទំនាក់ទំនងមួយឱ្យមនុស្សចេះជួយគ្នានាគ្រាមានអាសន្នដែលការគ្រប់គ្រងត្រូវធ្វើឡើងដោយគោរពនូវគោលការណ៍ភាពសុចរិត និងភាពស្មោះត្រង់ ក្នុងការគ្រប់គ្រងទ្រព្យនោះ។

២.២ ការគ្រប់គ្រងធ្វើឡើងក្នុងស្ថានភាពបន្ទាន់

២.២.១ ការការពារក្នុងស្ថានភាពចាំបាច់

ការការពារស្ថានភាពចាំបាច់ សម្តៅលើការការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំងនឹងឧបទ្ទវហេតុដែលបានកំពុងកើតមាន ឬដែលនឹងកើតមានឡើង។

ករណីនេះ ការគ្រប់គ្រង ក្នុងស្ថានភាពបន្ទាន់ត្រូវធ្វើឡើងដោយសកម្មភាពពីរគឺ សកម្មភាពឯកតោភាគី និងការជួយសង្គ្រោះ ដើម្បីជៀសវាងគ្រោះថ្នាក់។

ម៉្យាងទៀត ក្នុងការការពារស្ថានភាពចាំបាច់ វាត្រូវតែស្តែងតាមរយៈ សកម្មភាពពីរ គឺសកម្មភាពឯកតោភាគី និងសកម្មភាពឆ្លើយតបនឹងការជួយសង្គ្រោះបន្ទាន់។

២.២.១.១ សកម្មភាពឯកតោភាគី

សកម្មភាពឯកតោភាគី គឺសម្តៅលើអ្នកគ្រប់គ្រងដែលធ្វើឡើងដោយម្នាក់ឯង នៅពេលដែលជួបប្រទះព្រឹត្តិការណ៍កើតឡើងហើយបុគ្គលជាអ្នកគ្រប់គ្រងនេះសម្រេចចិត្តជួយសង្គ្រោះដើម្បីបញ្ចៀសនូវឧបទ្ទវហេតុធ្ងន់ធ្ងរក៏ដូចជាដើម្បីការពារនូវផលប្រយោជន៍របស់សាមីខ្លួន។

វាមានន័យថា ប្រសិនបើអ្នកគ្រប់គ្រងនោះ មិនជួយក្នុងស្ថានភាពបន្ទាន់នោះទេ ជាលទ្ធផលវានឹងធ្វើឱ្យបាត់បង់ ឬ ខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ឬ អាយុជីវិតរបស់សាមីខ្លួន។

- ឧទាហរណ៍៖

ហេតុការណ៍មួយបានកើតឡើងភ្លាមៗ ចំពោះផ្ទះលោក **ក** ដោយសារអគ្គិភ័យកំពុងឆាបឆេះឡើងយ៉ាងសន្ធោសន្ធៅ។ ហើយលោក **ខ** ជាអ្នកជិតខាងនឹងគ្នាបានឃើញហេតុការណ៍នេះ ក៏ប្រញាប់ប្រញាល់ជួលអ្នកពន្លត់អគ្គិភ័យមកពន្លត់ ដោយបានចំណាយលុយរបស់ខ្លួន។

ករណីនេះ លោក **ខ** ធ្វើឡើងដោយឯកឯង ដើម្បីជួយសង្គ្រោះផ្ទះលោក **ក** ហើយរួចរាល់ពីហេតុការណ៍ ទើបលោក **ខ** បានជូនដំណឹងតាមក្រោយ។

សកម្មភាពនេះ គឺជាសកម្មភាពឯកតោភាគីរបស់លោក **ខ** បានធ្វើឡើងដោយម្នាក់ឯង ដើម្បីបញ្ចៀសនូវអគ្គិភ័យដែលលេបត្របាក់ផ្ទះលោក **ក** ព្រោះថា ប្រសិនបើលោក **ខ** ជួយមកពន្លត់ទាន់ពេលទេនោះ លទ្ធផលវាច្បាស់ជា ផ្ទះរបស់លោក **ក** ត្រូវបានអគ្គិភ័យលេបត្របាក់ពិតច្បាស់ជាមិនខាន។

### ២.២.១.២ សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់

សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ សម្តៅទៅលើដំណាក់កាលមួយក្នុងពេលមានឧបទ្ទវហេតុនោះដោយអ្នកគ្រប់គ្រងបានចាត់ចែងសម្របសម្រួលលើរាល់ការគ្រប់គ្រង ដើម្បីឆ្លើយតបនឹងស្ថានភាពប្រឈមដែលកំពុងនឹងកើតហើយធ្វើការទប់ស្កាត់នូវការរីករាលដាលនៃឧបទ្ទវហេតុនោះ និងធ្វើឱ្យមានស្ថានភាពល្អប្រសើរឡើងវិញ។

ជាទូទៅ ការឆ្លើយតបអំពីហេតុការណ៍នេះ គឺបញ្ជាក់ឱ្យសាមីខ្លួនពីភាពបន្ទាន់នៃព្រឹត្តិការណ៍ក្នុងអំឡុងពេលដែលខ្លួនមិនដឹងទាល់តែសោះ និងត្រូវបញ្ជាក់ពីចំណុចសំខាន់ចំពោះសកម្មភាពរបស់ខ្លួន ដើម្បីជៀសវាងការប្រកែកគ្នាពេលក្រោយ។

ការឆ្លើយតបនេះ មានន័យថា សាមីខ្លួន និងអ្នកគ្រប់គ្រងដោយឈឺឆ្អាលមានទំនាក់ទំនងសកម្មភាពជាមួយគ្នារហូតដល់ពេលចប់ហេតុការណ៍នេះ[20]។

### ២.២.២ ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត

ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត គឺសម្តៅទៅលើឆន្ទៈរបស់អ្នកគ្រប់គ្រងក្នុងការប្រតិបត្តិកិច្ចការដោយគ្មានចេតនាបន្លំ ឬកេងប្រវ័ញ្ច ឬកេងចំណេញក្នុងទិសដៅដើម្បីរកកម្រៃដែលកើតចេញពីការគ្រប់គ្រងដែលខ្លួនបានធ្វើឡើយ ដែលជាហេតុនាំឱ្យខូចខាតផលប្រយោជន៍របស់សាមីខ្លួន។

ត្រង់ចំណុចនេះ មានន័យថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែជាបុគ្គលសុចរិត ស្មោះត្រង់ និង មានសីលធម៌ចេះជួយគ្នាដែលអះអាងតាមរយៈសកម្មភាពធ្វើការគ្រប់គ្រងជាក់ស្តែង[21]។

- ឧទាហរណ៍៖

លោក **ខ** ជួយសង្គ្រោះលោក **ក** ពីហេតុការណ៍ផ្ទុះហ្គាសឡាន ហើយ លោក **ខ** បានជូនលោក **ក** ទៅមន្ទីរពេទ្យនិងបានចេញការចំណាយថ្លៃព្យាបាលផ្សេងៗទៀត ប៉ុន្តែ ករណីនេះ គឺលោក **ខ** មិនត្រូវឱ្យខាងមន្ទីរពេទ្យធ្វើ

[20] មើលមាត្រា៧៣០ នៃ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[21] មើលមាត្រា៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ក័យប័ត្របន្ថែមតម្លៃពីលើថ្លៃព្យាបាលពិតប្រាកដទេ។ ប្រសិនបើជាគាត់មានគំនិតទុច្ចរិតពិតមែននោះ វាមិនត្រូវបានចាត់ទុកថាជា ការគ្រប់គ្រងដោយឈឺឆ្អាលបានទេ។

ជាគោលការណ៍ ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត ត្រូវបានគេសង្កេតឃើញមានទៅលើ ស្ថានភាព ពីរយ៉ាងគឺ៖

២.២.២.១ ការគ្រប់គ្រងដោយគ្មានកំហុស

ការគ្រប់គ្រងដោយគ្មានកំហុស សម្តៅលើករណីអ្នកគ្រប់គ្រងបានដឹងអំពីគោលបំណង ឬការណែនាំរបស់សាមីខ្លួន ហើយអ្នកគ្រប់គ្រងអនុវត្ត ឬធ្វើតាមគោលបំណង ឬការណែនាំនោះ។

ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងពុំបានដឹងអំពីគោលបំណង ឬការណែនាំរបស់សាមីខ្លួនទេ អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងដោយផ្អែកលើកាលៈទេសៈ ដែលសមស្របតាមស្ថានភាពជាក់ស្តែង[22]។

- ឧទាហរណ៍៖

ផ្ទះមួយបានបែកទុយោទឹក ហើយផ្ទះនឹងជាប់សោរ បើសិនជាយើងកាត់សោរនោះ យើងនឹងមានកំហុស ដូច្នេះយើងត្រូវផ្តល់ដំណឹងនេះទៅដល់ម្ចាស់ផ្ទះ។

ប៉ុន្តែបើស្ថានភាពនេះ វាកាន់តែធ្ងន់ធ្ងរ ឈានដល់មានការឆ្លងចរន្តអគ្គីសនីដោយសារទឹកចូលប្រីភ្លើង យើងអាចកាត់សោរដើម្បីចូលទៅគ្រប់គ្រងដោយផ្អែកលើកាលៈទេសៈដែលសមស្របអាស្រ័យតាមស្ថានភាពជាក់ស្តែង[23]។

២.២.២.២ ការមិនទទួលខុសត្រូវលើសំណងនៃការខូចខាត

ការគ្រប់គ្រងដោយឈឺឆ្អាល ស្ថិតនៅក្នុងស្ថានភាពបន្ទាន់ទៅលើបុគ្គលដូចជាទ្រព្យ ឬបុគ្គល។ បុគ្គលដែលជាអ្នកគ្រប់គ្រងពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាតកើតឡើងដោយសារការគ្រប់គ្រងឡើយ។

ប៉ុន្តែចំណុចខាងលើនេះក៏បញ្ជាក់ថា វាពិតជាមិនមែនជាកំហុសរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលទេ[24]។

ជាធម្មតា ការចូលទៅគ្រប់គ្រងក្នុងស្ថានភាពណាមួយ គឺជាការសម្តែងតាមឆន្ទៈចង់ជួយគ្នាក្នុងនាមជាមនុស្សមានសមធម៌ សីលធម៌ និងស្គាល់ពីហេតុផលបានត្រឹមត្រូវចំពោះកាលៈទេសៈនីមួយៗដែលកើតឡើងដោយចៃដន្យ។

- ឧទាហរណ៍៖

ក្នុងករណីមួយមានភ្លើងឆេះផ្ទះ ហើយអ្នកគ្រប់គ្រងគាត់បានធ្វើការគ្រប់គ្រងដោយប្រុងប្រយ័ត្នចំពោះកិច្ចការនេះ។

ក្រោយពីស្ថានភាពនេះបានបញ្ចប់រួចរាល់ហើយ ក៏អ្នកគ្រប់គ្រងដោយឈឺឆ្អាលប្រគល់ការគ្រប់គ្រងនេះឱ្យទៅសាមីខ្លួនវិញ។

ក្រោយពីបានទទួលវិញសាមីខ្លួនបានប្រាប់អ្នកគ្រប់គ្រងថា មានការបាត់បង់ទ្រព្យសម្បត្តិមួយចំនួនដោយសារការគ្រប់គ្រងនេះ ប៉ុន្តែ សាមីខ្លួនមិនអាចបញ្ជាក់បានថា ជាកំហុសរបស់អ្នកគ្រប់គ្រងទេ ព្រោះវាស្ថិតក្នុង

---

[22] មើលមាត្រា៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[23] មើលមាត្រា៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[24] មើលមាត្រា៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ស្ថានភាពបន្ទាន់។

២.៣ ការគ្រប់គ្រងដោយឈឺឆ្អាលក្រោយពីបញ្ចប់កិច្ចសន្យា

ការគ្រប់គ្រងដោយឈឺឆ្អាលក្រោយពីបញ្ចប់កិច្ចសន្យា សម្តៅទៅលើស្ថានភាពមួយដែលការគ្រប់គ្រងដោយឈឺឆ្អាលបានចាប់ផ្តើមឡើង ក្រោយពីភាគីទាំងសងខាងបានបញ្ចប់កិច្ចសន្យា ហើយការគ្រប់គ្រងបានចាប់ផ្តើមដោយគ្មានការព្រមព្រៀងដែរ វាស្ថិតក្នុងស្ថានភាពដែលអ្នកគ្រប់គ្រងមិនអាចទាក់ទងទៅសាមីខ្លួនបាន។

- ឧទាហរណ៍៖

កិច្ចសន្យាទិញលក់រថយន្ត ក្រោយពីភាគីនៃកិច្ចសន្យាបានបញ្ចប់កិច្ចសន្យាដោយអ្នកទិញបានប្រគល់ប្រាក់ទៅតាមចំនួនដែលអ្នកលក់ទាមទារ ប៉ុន្តែបែរជាដល់ថ្ងៃប្រគល់រថយន្តស្រាប់តែអ្នកទិញមិនបានមកយករថយន្តហើយ អ្នកលក់ក៏បានទាក់ទងទៅតែមិនចូល។

ក្នុងស្ថានភាពនេះ អ្នកលក់បានចាប់ផ្តើមគ្រប់គ្រងមើលថែទាំរថយន្តនិងរកកន្លែងទុកដាក់ឱ្យបានសមរម្យនិងសុវត្ថិភាពរហូតដល់ពេលអ្នកទិញមកយករថយន្តវិញ។

ដូចនេះ ការគ្រប់គ្រងមើលថែរថយន្តអំឡុងពេលអវត្តមានអ្នកទិញនោះត្រូវបានចាត់ចូលជាការគ្រប់គ្រងដោយឈឺឆ្អាលបាន។

## ផ្នែកទី២. សេចក្តីចម្រើនដោយឥតហេតុ

នីតិរដ្ឋប្បវេណី ជាគោលការណ៍សំខាន់មួយសម្រាប់គ្រប់គ្រងសកម្មភាពផ្នែករដ្ឋប្បវេណីរបស់បុគ្គលគ្រប់រូបជាពិសេសផ្តល់ឱ្យគ្រប់គ្នានូវសិទ្ធិនិងករណីយកិច្ច ចំពោះមុខច្បាប់។

ក្នុងករណីយកិច្ច ចំពោះមុខច្បាប់ក្នុងករណីមានទំនាក់ទំនងគតិយុត្តណាមួយកើតឡើងក្នុងគោលបំណងការពារនូវផលប្រយោជន៍ស្របច្បាប់របស់បុគ្គលគ្រប់គ្នា។

ក្នុងករណីដែលបុគ្គលណាម្នាក់ទទួលបានផលប្រយោជន៍ហើយធ្វើឱ្យបុគ្គលម្នាក់ទៀតបាត់បង់ផលប្រយោជន៍អាចធ្វើការទាមទារផលប្រយោជន៍របស់ខ្លួនពីអ្នកទទួលផលប្រយោជន៍នោះមកវិញបានហើយអ្នកដែលទទួលបានផលប្រយោជន៍នោះ ត្រូវប្រគល់ត្រឡប់ទៅវិញនូវអ្វីដែលខ្លួនបានទទួល។

ទាក់ទងនឹងសកម្មភាពបែបនេះ គឺមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីថាជា «សេចក្តីចម្រើនដោយឥតហេតុ»[25]។

### កថាភាគទី១. សញ្ញាណទូទៅ

១. បទដ្ឋានគតិយុត្ត

១.១ អត្ថន័យតាមក្រមរដ្ឋប្បវេណីចាស់

តាមក្រមរដ្ឋប្បវេណីចាស់ គឺបានផ្តោតទៅតែការសងប្រាក់ដែលគ្មានជំពាក់តែប៉ុណ្ណោះដែលកើតឡើងដោយសារ៖

- ការភាន់ច្រឡំ

[25] គេហទំព័រសារព័ត៌មាន FRESH NEWS, *យល់ដឹងផ្នែកច្បាប់៖ សេចក្តីចម្រើនដោយឥតហេតុ* , ( ឆ្នាំ ២០២០-០៥-៣១ ) , អាចរកបាននៅ https://freshnewsasia.com/index.php/en/localnews/160968-2020-05-31-04-55-45.html ( ចូលទស្សនាថ្ងៃទី ២៣ ឧសភា ២០២៤)។

ជនណាដែលមិនបានជំពាក់គេ តែភាន់ច្រឡំថាខ្លួនជំពាក់គេហើយក៏បានសងទ្រព្យដែលខ្លួនមិនបានជំពាក់នោះទៅគេ ជននោះអាចប្ដឹងទារយកវិញបាន។

កម្មវត្ថុដែលនឹងប្ដឹងទារវិញនោះ គឺប្ដឹងឱ្យបង្វិលរបស់ដែលលើកទៅឱ្យគេខុសនោះមកវិញក្ដី និងប្ដឹងឱ្យសងថ្លៃរបស់នោះក្ដី ហើយប្ដឹងឱ្យសងតម្លៃតាវកាលិកដែលខ្លួនបានបំពេញហើយនោះក្ដី។

✍ ទទួលបានសំណងដែលគ្មានមូលហេតុ

គ្មានមូលហេតុក្នុងការទទួលបានសំណង គឺសម្ដៅទៅលើការទទួលបាននូវរបស់ឬសំណងដោយសារអហេតុកផលណាមួយ។

ឧទាហរណ៍៖

លោក **ក** បានផ្ញើលុយខុសគណនីទៅកាន់លោក **ខ** ដូចនេះ លោក **ខ** ទទួលបាននូវលុយដោយការផ្ញើលុយខុសគណនី (អហេតុកផល) ពីលោក **ក** ។

នៅទីនេះមានករណី ២ ប្រភេទគឺ៖

- ករណីទី១ សុចរិតភាព៖

- បុគ្គលណាបានសំណងនូវរបស់ពីមនុស្សដែលគេមិនបានជំពាក់ខ្លួនសោះ ដោយសត្យឥតចេតនាក្លែង ជននោះត្រូវបង្វិលរបស់ដែលគេប្រគល់ឱ្យនោះទៅគេវិញ បើរបស់នោះគង់នៅក្នុងដៃរបស់ខ្លួននៅឡើយ។
- ថាបើរបស់នោះមិននៅក្នុងដៃខ្លួនទេ បុគ្គលនោះត្រូវសងថ្លៃលក់ឱ្យគេវិញ។
- បើរបស់នោះបាត់ ឬខូចដោយកំហុសរបស់ខ្លួន បុគ្គលនោះត្រូវទទួលសងគេវិញ។

- ករណីទី២ ទុច្ចរិតភាព ៖

- បុគ្គលណាទទួលដោយចេតនាទុច្ចរិតនូវសំណងដែលខ្លួនដឹងគេមិនបានជំពាក់ខ្លួនទេ បុគ្គលនោះត្រូវបង្វិលរបស់ដែលគេប្រគល់ឱ្យនោះទៅគេវិញ។
- បើជាការទទួលប្រាក់វិញ ត្រូវសងការប្រាក់គេទៀតដោយគិតមួយឆ្នាំ ៥%
- បើជាការទទួលវត្ថុដែលបង្កើតផល បុគ្គលនោះត្រូវសងផលនោះដល់គេផង ហើយថែមសងជម្ងឺចិត្តគេទៀត។
- បើរបស់នោះបាត់ ឬខូចខាតជននោះត្រូវទទួលសងគេ ទោះបាត់ឬខូចខាតដោយករណីប្រធានស័ក្តិក៏ដោយ។

១.២ អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

តាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន សេចក្ដីចម្រើនដោយឥតហេតុ សម្ដៅលើស្ថានភាពគ្មានមូលហេតុលើផ្លូវច្បាប់ គឺករណីបុគ្គលណាដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ។

- បុគ្គលដែលបានទទួលផលប្រយោជន៍នោះហៅថា អ្នកទទួលផលប្រយោជន៍
- រីឯបុគ្គលដែលទទួលរងនូវការបាត់បង់ហៅថា អ្នកបាត់បង់ផលប្រយោជន៍។

២. ឯកសារពាក់ព័ន្ធ

២.១ អត្ថន័យតាមវចនានុក្រមខ្មែរ

នៅក្នុងវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត(ពុទ្ធសាសនបណ្ឌិត្យ) បានពន្យល់ពាក្យ «អហេតុកផល(សេចក្ដីចម្រើនដោយឥតហេតុ)» គឺជាការទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃដោយសារការទទួលផលនោះ[26]។

២.២ អត្ថន័យតាមសមាគមសាលាត្រាជូ

សេចក្ដីចម្រើនដោយឥតហេតុ គឺជាស្ថានភាពដែលកើតឡើងជាញឹកញាប់នៅក្នុងឧបសន្យា ឬនៅពេលដែលកិច្ចសន្យាមិនមានអានុភាព។

សេចក្ដីចម្រើនដោយឥតហេតុ កើតឡើងនៅពេលដែលមានអតុល្យភាពផ្អែកសត្យានុម័ត(ភាពជាក់ស្ដែងដែលបានកើតឡើង) ដូចជាការទទួលបាននិងការបាត់បង់ផលប្រយោជន៍ដោយសារថាអ្នកទទួលផលប្រយោជន៍មិនមានសិទ្ធិ ហើយអ្នកបាត់បង់ផលប្រយោជន៍មិនមានការផ្ទេរតាមឆន្ទៈរបស់ខ្លួន។

### កថាភាគទី២. លក្ខខណ្ឌ

១. លក្ខខណ្ឌសម្ភារៈឬសត្យានុម័ត

ផ្អែកតាមមាត្រា ៧៣៦ កថាខណ្ឌទី១៖ លក្ខខណ្ឌសត្យានុម័តគឺផលប្រយោជន៍ ការបាត់បង់ផលប្រយោជន៍ ទំនាក់ទំនងហេតុ និងផល រវាងការទទួលផលប្រយោជន៍ និង ការបាត់បង់ផលប្រយោជន៍[27]។

ករណីខាងក្រោមនេះ គឺត្រូវបានចាត់ទុកថាជាប្រភេទករណី ពីរយ៉ាង ដែលកើតមានញឹកញាប់ ដែលសេចក្ដីចម្រើនដោយឥតហេតុត្រូវបានយកមកអនុវត្ត។

- ករណីទី១៖

**ក** និង **ខ** បានបង្កើតកិច្ចសន្យាមួយដែល **ក** ត្រូវលក់រថយន្តទៅឱ្យ **ខ** ។ **ក** បានប្រគល់រថយន្តនោះឱ្យ **ខ** ហើយ **ខ** បានបង់ថ្លៃលក់ចំនួន ១០០០០$ ឱ្យ **ក** ។បន្ទាប់មក **ក** បានលុបកិច្ចសន្យានោះចោល ដោយសារតែ **ខ** បានឆបោក។ តើ **ក** និង **ខ** អាចទាមទារអ្វីពីគ្នាបាន?

ករណីទី១ ខាងលើនេះ គឺករណីដែលសេចក្ដីចម្រើនដោយឥតហេតុ ដែលផ្អែកលើទំនាក់ទំនងដែលអាចមើលឃើញ ដូចជាកិច្ចសន្យាដែលត្រូវបានលុបចោល។

- ករណីទី២៖

**ខ** បានរថយន្តដែលចតនៅក្នុងដីឡូត៍មួយកន្លែ ដោយគ្មានការយល់ព្រម ខណៈពេលដែលម្ចាស់រថយន្ត **ក** មិននៅ។ **ខ** បានបើករថយន្តនោះអស់រយៈពេល១ខែ ហើយបានទុករថយន្តនោះវិញ មុនពេលដែល **ក** បានដឹងហេតុការណ៍នោះ។ រថយន្តនោះមិនខូចខាតទេ ហើយសាំងក៏មិនត្រូវបានប្រើដែរ **ខ** ព្រោះគាត់បានប្រើសាំងដែលបានទិញដោយខ្លួនឯង។ តើ **ក** អាចទាមទារពី **ខ** បានដែរឬទេ?

ករណីទី២ ខាងលើនេះ គឺសេចក្ដីចម្រើនដោយឥតហេតុត្រូវបានយកមកអនុវត្តដោយផ្អែកលើការរំលោភសិទ្ធិរបស់អ្នកដទៃ ដូចជាកម្មសិទ្ធជាក់ស្ដែង។

[26] គេហទំព័រសារ PHKASLA PARTNER, *ពន្យល់ពាក្យខ្មែរ«អហេតុកផល( សេចក្ដីចម្រើនដោយឥតហេតុ»*, (ឆ្នាំ ២០២៤-០៤-០៨), អាចរកបាននៅ https://search.app/vLfDEga6M5vEpYJ69 (ចូលទស្សនាថ្ងៃទី ២៣ ឧសភា ២០២៤)។

[27] មើលមាត្រា៧៣៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

សូមកត់សម្គាល់ថាករណីទាំងពីរនេះ គឺគ្រាន់តែជាករណីមួយចំនួននៅក្នុងចំណោមករណីដែលកើតមានញឹកញាប់ជាច្រើន ហើយសេចក្តីចម្រើនដោយឥតហេតុ អាចយកមកអនុវត្តនៅក្នុងន័យទូលាយជាងនេះ។

១.១ ការទទួលផលប្រយោជន៍

ភាគីម្ខាងដែលទទួលបានផលប្រយោជន៍ គឺបានមកពីភាគម្ខាងទៀតដែលបាត់នូវផលប្រយោជន៍។ ផលប្រយោជន៍ដែលទទួលបាន ក៏ដូចជាផលប្រយោជន៍ដែលបាត់បង់ អាចជាផលប្រយោជន៍រូបី និង ផលប្រយោជន៍អរូបី ។

ផលប្រយោជន៍រូបី នៅក្នុងករណីនៃសេចក្តីចម្រើនដោយឥតហេតុ គឺធម្មតាមានដូចជាប្រាក់ ឬ ទំនិញ ប៉ុន្តែទ្រព្យសម្បត្តិដែលមិនអាចមើលឃើញ ដូចជា ផលប្រយោជន៍ក្នុងការប្រើប្រាស់ ការចាត់ចែង គឺត្រូវបានបញ្ចូលនៅក្នុងផលប្រយោជន៍អរូបីផងដែរ[28]។

- នៅក្នុងករណីទី១៖

វាជាផលប្រយោជន៍រូបី ផលប្រយោជន៍ដែល **ក** ទទួលបាន គឺ លុយចំនួន ១០០០០$ពី **ខ** ហើយ ផលប្រយោជន៍ដែល **ខ** ទទួលបាន គឺ រថយន្តពី **ក** ។

- នៅក្នុងករណីទី២៖

វាជាផលប្រយោជន៍អរូបីដែល **ខ** ទទួលបាន គឺ ការប្រើប្រាស់រថយន្តរបស់ **ក** អស់រយៈពេល ១ខែ។

តម្លៃនៃផលប្រយោជន៍បែបនេះ ជានិច្ចកាលមិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែដើម្បីដឹងថា តើផលប្រយោជន៍ដែលទទួលបានមានទំហំប៉ុណ្ណានោះត្រូវយោងទៅលើថ្លៃឈ្នួលបង់ប្រចាំខែ ចំពោះរថយន្តដែលមានប្រភេទដូចគ្នា ថាតើមានចំនួនប៉ុន្មានក្នុង ១ខែ?

១.២ ការបាត់បង់ផលប្រយោជន៍

ទំហំផលប្រយោជន៍បាត់បង់ ត្រូវសមាមាត្រទៅនឹងទំហំផលប្រយោជន៍ដែលទទួលបាន។ នេះវាជា គោលការណ៍នៃការសងត្រឡប់មកវិញនូវផលប្រយោជន៍ ដែលបានទទួលត្រឹមកម្រិតនៅក្នុងទំហំនៃការបាត់បង់ប្រយោជន៍។

ជាទូទៅ ការបាត់បង់នូវផលប្រយោជន៍ គឺឆ្លើយតបទៅនឹងទស្សនៈនៃផលប្រយោជន៍នៅក្នុងករណីភាគច្រើនបំផុត[29]។

- នៅក្នុងករណីទី១៖

វាមានលក្ខណៈងាយស្រួលក្នុងការដឹងថាតើអ្វីជាការបាត់បង់គឺដោយសារថា វាគឺជាវត្ថុរូបីយ៍ដូចគ្នាពីទស្ស-

---

28 សមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តធម៌នៃប្រទេសជប៉ុន(ICD),« *ក្រមរដ្ឋប្បវេណី ភាគទី៤ ស្តីពីមូលដ្ឋាននៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់*» , បោះពុម្ពលើកទី ១ ខែមីនា ឆ្នាំ២០១២ , កថាខណ្ឌ ២-១ ទំព័រ ៨

29 សមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តធម៌នៃប្រទេសជប៉ុន(ICD),« *ក្រមរដ្ឋប្បវេណី ភាគទី៤ ស្តីពីមូលដ្ឋាននៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់*» , បោះពុម្ពលើកទី ១ ខែមីនា ឆ្នាំ២០១២ , កថាខណ្ឌ ២-២ ទំព័រ ១០

នៈផ្សេងគ្នា ដូចជា សិទ្ធិទាមទារ និង កាតព្វកិច្ច ។

ការបាត់បង់ប្រយោជន៍ និង ការទទួលបាននូវផលប្រយោជន៍ឆ្លើយតបគ្នាយ៉ាងច្បាស់ គឺ **ក** បាត់បង់រថយន្ត ហើយ **ខ** បាត់បង់លុយ ។

ផលប្រយោជន៍របស់ **ខ** ទទួលបាន គឺការបាត់បង់របស់ **ក** ហើយផលប្រយោជន៍របស់ **ក** គឺបាត់បង់របស់ **ខ** ប៉ុន្តែ វាមិនមែនតែងតែជារឿងធម្មតានោះទេ ដូចនៅក្នុងករណីទី ២។

ជាពិសេស បញ្ហាអាចត្រូវបានបង្ហាញដូចជា តើអ្វីដែលជាការបាត់បង់ក្នុងករណីបើសិនជា បុគ្គលណាមួយប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកដទៃខណៈពេលដែលម្ចាស់សិទ្ធិមិនមានឆន្ទៈក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទាល់តែសោះ ទាក់ទងនឹងការបាត់បង់នេះ មានទស្សនៈពីរ មានវិវាទនឹងគ្នា ។

- ទស្សនៈទី ១ យល់ឃើញថា **ក** មិនបាត់បង់ផលប្រយោជន៍ ដោយសារ **ក** ទុករថយន្តមិនប្រើប្រាស់ ហើយ រថយន្តមិនខូចក៏មិនត្រូវបានប្រើ ។
- ចំពោះទស្សនៈទី ២ យល់ឃើញថា **ក** បាត់បង់នូវផលប្រយោជន៍ដោយសារ **ក** អាចប្រើប្រាស់រថយន្តនៅពេលណាមួយក្នុងអំឡុងពេលដែលគាត់ទុករថយន្តចោលនោះនិងការបាត់បង់ដែលកើតឡើងដោយសារការសឹករិចរិលលើរថយន្ត។

### ១.៣ ទំនាក់ទំនងហេតុ និង ផល

លក្ខខណ្ឌនេះ មិនខុសគ្នាទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដើម្បីអាចទាមទារសំណងការខូចខាតដោយសារ អំពើអនីត្យានុកូល គឺទំនាក់ទំនងហេតុនិងផលរវាងព្យសនកម្មនិងអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍ ។

ចំពោះសេចក្តីចម្រើនដោយឥតហេតុ ដើម្បីទទួលស្គាល់នូវសិទ្ធិក្នុងការទាមទារយកមកវិញនូវផលប្រយោជន៍ដែលបានបាត់បង់ បញ្ហាស្ថិតនៅត្រង់ថា៖

- តើមានអ្នកទទួលបាននូវផលប្រយោជន៍កើតមានឡើងដែរឬទេ?
- តើមានអ្នកដែលបានបាត់បង់ផលប្រយោជន៍ដោយសារតែការទទួលបាននូវផលប្រយោជន៍ដោយបុគ្គលដែលបានទទួលបានផលប្រយោជន៍នោះដែរឬយ៉ាងណា?

ជាទូទៅ ទំនាក់ទំនងហាតុ និងផល ត្រូវបានទទួលស្គាល់ករណីប្រសិនបើបានបង្ហាញថាមាន អ្នកទទួលបាននូវផលប្រយោជន៍ដោយសារការបាត់បង់ផលប្រយោជន៍ពីអ្នកបាត់ប្រយោជន៍ ដោយគ្មានផលប្រយោជន៍។

ទំនាក់ទំនងហេតុ និង ផល នៅក្នុងសេចក្តីចម្រើនដោយឥតហេតុ ករណីភាគច្រើនមិនសូវចោទជាបញ្ហាធំដុំនោះទេដោយសារតែការបាត់បង់ផលប្រយោជន៍ នៅក្នុងករណីភាគច្រើនត្រូវបានភ្ជាប់ជាមួយនឹងការទទួលបានផលប្រយោជន៍ស្ទើរតែមិនអាចជៀសរួច ។

- នៅក្នុងករណីទី១៖

**ក** បានលុបកិច្ចសន្យាដោយសារ **ខ** បានឆបោក ក្រោយពេលប្រគល់វត្ថុ និង ការបង់ថ្លៃលក់ ។ ករណីនេះ បើសិនជា មិនប្រគល់រថយន្តនោះទេ **ខ** ក៏មិនទទួលបានផលប្រយោជន៍ជារថយន្ត ។ ដូចគ្នាដែរ បើសិនជា **ខ** មិនបង់លុយឱ្យ **ក** ក៏ **ក** មិនទទួលបានផលប្រយោជន៍ជាលុយផងដែរ ។

ហេតុដូច្នេះ ទំនាក់ទំនងហេតុ និង ផល ត្រូវបានគេទទួលស្គាល់រវាងផលប្រយោជន៍របស់ និង ការបាត់បង់

របស់ **ខ** ព្រមទាំង ការបាត់បង់របស់ **ក** និង ការទទួលផលប្រយោជន៍របស់ **ខ**។

- នៅក្នុងករណីទី២៖

**ខ** បានយករថយន្តដែល **ក** ចតនៅក្នុងដីឡូត៍មួយកន្លែង ប្រើប្រាស់អស់រយៈពេល ១ខែ ។ ប៉ុន្តែករណីបើសិនជា **ខ** មិនយករថយន្តរបស់លោក **ក** ប្រើប្រាស់ ក៏ លោក **ក** មិនបាត់ផលប្រយោជន៍ពីការប្រើប្រាស់រថយន្ត ហើយ **ខ** ក៏មិនទទួលបានផលប្រយោជន៍ជាការប្រើប្រាស់រថយន្តដែរ។

ហេតុដូច្នេះ ទំនាក់ទំនងហេតុ និង ផល ក្នុងករណីខាងលើត្រូវបានចាត់ទុកថា បានភ្ជាប់គ្នាពិតប្រាកដមែនហើយ។

២. លក្ខខណ្ឌផ្លូវច្បាប់

លក្ខខណ្ឌផ្លូវច្បាប់ បានសម្តៅដល់ គ្មានមូលហេតុលើផ្លូវច្បាប់មានន័យថា គ្មានមូលហេតុត្រឹមត្រូវសម្រាប់រក្សាផលប្រយោជន៍[30] វាជារឿងមិនសមហេតុផលដែលអនុញ្ញាតឱ្យបុគ្គលដែលមិនមានមូលហេតុគតិយុត្តក្នុងការទទួលបាននូវផលប្រយោជន៍អាចរក្សាទុកនូវផលប្រយោជន៍ដែលបានទទួលពីភាគីម្ខាងទៀតដែលបាត់ផលប្រយោជន៍ដោយមិនត្រឹមត្រូវ[31]។

នៅក្នុងករណីទី១ ខាងលើ **ក** បានលុបកិច្ចសន្យាដោយសារ **ខ** ឆបោក ។

ដូនេះ ករណីនេះ **ក** គ្មានមូលហេតុគតិយុត្ត ក្នុងការរក្សាទុកនូវប្រាក់ ១០០០០$ដែល **ខ** បានបង់ហើយ **ខ** ក៏មិនមានមូលហេតុរក្សាទុកនូវ រថយន្តដែល **ក** បានប្រគល់នោះដែរ ។

ដូច្នោះ **ក** មានករណីយកិច្ចសងលុយចំនួន ១០០០០$ឱ្យ **ខ** វិញ ហើយ **ខ** ត្រូវប្រគល់រថយន្តឱ្យ **ក** ។

នៅក្នុងករណីទី២ បើ  បានយករថយន្តដែល **ក** ចតនៅក្នុងដីឡូត៍មួយកន្លែង ប្រើប្រាស់អស់រយៈពេល ១ខែ ។ គ្មានបុគ្គលណាមួយប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ខណៈពេលដែលម្ចាស់សិទ្ធិ មិនមានឆន្ទៈឱ្យប្រើ ឬ ចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទាល់តែសោះ ។

ដូចនេះ មានន័យថា **ខ** ខ្វះនូវមូលហេតុគតិយុត្តក្នុងការទទួលបាននូវផលប្រយោជន៍ ជាការប្រើប្រាស់រថយន្តរបស់ **ខ** ។

ជាលទ្ធផល **ក** ត្រូវសងថ្លៃជា ការប្រើប្រាស់រថយន្តក្នុងរយៈពេល ១ខែ ឱ្យទៅ **ខ** ។ក្រៅពីសញ្ញាណទូទៅ និងលក្ខខណ្ឌផ្សេងៗទៀតមក កាតព្វកិច្ចឧបសន្យា ក៏មានបង្កប់នូវករណីយកិច្ចមកជាមួយផងដែរ។

---

30 មើលកថាខណ្ឌទី១ មាត្រា៧៣៦ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

31 សមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តធម៌នៃប្រទេសជប៉ុន(ICD),« *ក្រមរដ្ឋប្បវេណី ភាគទី៤ ស្តីពីមូលដ្ឋាននៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់*» , បោះពុម្ពលើកទី ១ ខែមីនា ឆ្នាំ២០១២ , កថាខណ្ឌ ២-៤ ទំព័រ ១០

# ជំពូកទី២
# ករណីយកិច្ច

## ផ្នែកទី១. ករណីយកិច្ចរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

### កថាភាគទី១. ករណីយកិច្ចរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ថ្វីត្បិតតែ អ្នកគ្រប់គ្រងដោយឈឺឆ្អាល បានចាប់ផ្តើមបំពេញកិច្ចការដើម្បីប្រយោជន៍បុគ្គលដែលត្រូវបានគេគ្រប់គ្រង (សាមីខ្លួន) ក៏ពិតមែន ក៏ប៉ុន្តែដើម្បីការពារដល់ផលប្រយោជន៍របស់សាមីខ្លួនដែលម្ចាស់ទ្រព្យសម្បត្តិ ឬមានសិទ្ធិបុគ្គលដែលត្រូវបានគ្រប់គ្រង[32] ។

តាមគោលការណ៍ច្បាប់ ក៏បានតម្រូវឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាលបំពេញនូវករណីយកិច្ចមួយចំនួនដូចខាងក្រោម៖

១. ករណីយកិច្ចជូនដំណឹង

ជាគោលការណ៍ អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួនដោយគ្មានការយឺតយ៉ាវ។

វាមានន័យថានៅពេលណាដែលការគ្រប់គ្រប់ដោយការឈឺឆ្អាលចាប់ផ្តើម សាមីខ្លួនច្រើនតែមិនដឹងអំពីការគ្រប់គ្រប់ដោយការឈឺឆ្អាលនោះទេ។

ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលនេះ គឺជាការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង ឬបុគ្គលផ្សេងទៀតក៏ដោយក៏វានៅតែជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃដែរ។

ដើម្បីកុំឱ្យមានបាតុភាពអកម្មកើតឡើងដោយយថាហេតុចាំបាច់ត្រូវតម្រូវឱ្យអ្នកគ្រប់គ្រងដោយការឈឺឆ្អាលជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួនដោយគ្មានការយឺតយ៉ាវ [33]។

✍ តាមន័យនេះ ការជូនដំណឹង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- ការជូនដំណឹងត្រូវធ្វើនៅក្រោយពេលចាប់ផ្តើមគ្រប់គ្រង៖ មានន័យថាអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានចាប់ផ្តើមបំពេញកិច្ចការគតិយុត្តក្នុងនាមសាមីខ្លួន រួចរាល់ហើយទើបបានធ្វើការជូនដំណឹង។
- ក្នុងករណីដែលការជូនដំណឹងត្រូវបានធ្វើឡើងនៅមុនពេលចាប់ផ្តើមធ្វើការគ្រប់គ្រងនោះ អាចមានស្ថានភាព ៣ យ៉ាង ដែលអាចនឹងកើតមានឡើង រួមមាន៖

១.១ សាមីខ្លួនបានយល់ព្រមឱ្យអ្នកគ្រប់គ្រងនោះចាប់ផ្តើមធ្វើការគ្រប់គ្រង

ករណីនេះ តើអាចចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលបានដែរឬទេ?

ឧទាហរណ៍៖

លោក **ក** ជាអ្នកជិតខាងរបស់លោក **ខ** បានឃើញថា ដំបូលផ្ទះរបស់លោក **ខ** បានខូចខាតដោយសារខ្យល់បក់ ខណៈដែលលោក **ខ** មិននៅផ្ទះ។ ភ្លាមនោះ លោក **ក** ក៏បានទូរស័ព្ទទៅលោក **ខ** ដើម្បីឱ្យលោក **ខ** បានដឹង។ លោក **ខ** បានស្នើសុំឱ្យលោក **ក** ជួយប្រក់ដំបូលនិងថែរក្សាផ្ទះរបស់ខ្លួនផង ហើយរាល់ការចំណាយលើសោហ៊ុយផ្សេងៗ លោក **ខ** បានស្នើសុំឱ្យលោក **ក** ចេញឱ្យខ្លួនសិននៅពេលដែលខ្លួនត្រលប់មកវិញ លោក **ខ** នឹង

---

[32] មើលមាត្រា៧២៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[33] មើលមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា

ចេញសងទាំងអស់ ហើយលោក **ក** ក៏យល់ព្រមជួយ។ ករណីនេះ លោក **ក** បានចាប់ផ្តើមជួសជុលដំបូលផ្ទះរបស់លោក **ខ** តាមរយៈការព្រមព្រៀងរវាងលោក **ក** និង លោក **ខ** ។

បើយើងធ្វើការពិនិត្យដោយយកចិត្តទុកដាក់ទៅការចាប់ផ្តើមគ្រប់គ្រងបែបនេះ គឺកើតចេញពីកិច្ចសន្យាដែលសំណើររបស់លោក **ខ** និង ស្ទីការរបស់លោក **ក** គឺមានភាពត្រូវគ្នា។

ម្យ៉ាងវិញទៀត ការគ្រងគ្រងរបៀបនេះ គឺជាលោក **ក** មានសិទ្ធិគ្រង់គ្រងដោយរយៈកិច្ចសន្យា ដែលមានលក្ខណៈផ្ទុយពីលក្ខខណ្ឌនៃការគ្រង់គ្រងដោយឈឺឆ្អាលគ្រង់ថាដើម្បីចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលចាំបាច់អ្នកគ្រង់គ្រងគ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង[34]។

ដូច្នេះ ករណីនេះ មិនត្រូវបានចាត់ទុកថាជា ការគ្រប់គ្រងដោយឈឺឆ្អាលទេ។

### ១.២ សាមីខ្លួនបានធ្វើការបដិសេធមិនឱ្យចាប់ផ្តើមការគ្រប់គ្រង

សាមីខ្លួនបានធ្វើការបដិសេធមិនឱ្យចាប់ផ្តើមការគ្រប់គ្រង សម្តៅទៅលើស្ថានភាពមួយដែលនៅមុនពេលការគ្រប់គ្រងត្រូវបានចាប់ផ្តើម អ្នកដែលនឹងត្រូវគ្រប់គ្រងត្រូវបានជូនដំណឹងជាមុនទៅសាមីខ្លួន អំពីការចាប់ផ្តើមគ្រប់គ្រងនៅពេលនោះសាមីខ្លួនបានធ្វើការបដិសេធអំពីការចាប់ផ្តើមការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង។

ស្ថានភាពបែបនេះ អ្នកគ្រប់គ្រង មិនអាចចាប់ផ្តើមគ្រប់គ្រងតាមសម្តីរបស់សាមីខ្លួនឬ ចាប់ផ្តើមធ្វើការគ្រប់គ្រងដោយពិនិត្យមើលលើស្ថានភាពគ្រោះថ្នាក់ ប្រសិនបើគ្មានការគ្រប់គ្រង ។

ករណីដែលអ្នកគ្រប់គ្រង មិនចាប់ផ្តើមធ្វើការគ្រប់គ្រងទេនោះវានឹងគ្មានបញ្ហាដែលត្រូវពិចារណាតទៅទៀតទេ ដោយហេតុថាគ្មានការចាប់ផ្តើមសកម្មភាពគតិយុត្តណាមួយឡើយ ពោលវាគ្រាន់តែជាការជូនដំណឹងធម្មតានោះទេ។

ប៉ុន្តែក្នុងករណី សាមីខ្លួនបានធ្វើការបដិសេធមិនឱ្យអ្នកគ្រប់គ្រងចាប់ផ្តើមធ្វើការគ្រប់គ្រងហើយអ្នកគ្រប់គ្រងនៅតែចាប់ផ្តើមធ្វើការគ្រប់គ្រងដោយចិត្តឯងនោះដោយអ្នកគ្រប់គ្រងយល់ឃើញថាស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរនឹងអាចកើតមានឡើងដល់សាមីខ្លួន ករណីដែលគ្មានវត្តមាននៃការគ្រប់គ្រងដោយឈឺឆ្អាលទេ។

សួរថាតើ សកម្មភាពបែបនេះចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលឬទេ?

ក្នុងករណីនេះ មិនចូលក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ដោយខ្វះធាតុនៃការយល់ព្រម និងម្យ៉ាងនេះជាការបំពានដល់សេរីភាពចាត់ចែងទ្រព្យរបស់សាមីខ្លួន ។

បន្ថែមពីនោះ បញ្ញត្តិក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា ការគ្រប់គ្រងត្រូវបញ្ចប់ដោយកាលណាវាផ្ទុយទៅនឹងឆន្ទៈរបស់សាមីខ្លួន[35]។

### ១.៣ សាមីខ្លួនផ្តល់ការយល់ព្រមយឺតយ៉ាវ

សម្តៅលើស្ថានភាពមួយ ដែលអ្នកគ្រប់គ្រង បានជូនដំណឹងអំពីស្ថានភាព ឬហេតុការណ៍គ្រោះថ្នាក់ដល់សាមីខ្លួនរួចហើយ ប៉ុន្តែសាមីខ្លួនមិនទាន់បានផ្តល់ការយល់ព្រមឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាលចាប់ផ្តើមធ្វើការគ្រប់គ្រងទេពោលគឺសាមីខ្លួនមានការយឺតយ៉ាវក្នុងការផ្តល់ការយល់ព្រមអំពីការចាប់ផ្តើមការគ្រប់គ្រង។

ស្ថានភាពបែបអ្នកគ្រប់គ្រងនៅតែចាប់ផ្តើមធ្វើការគ្រប់គ្រងសួរថា សកម្មភាពបែបនេះចាត់ទុកថាជាការ

---

[34] មើលមាត្រា៧២៩ កថាខណ្ឌទី ១នៃក្រមរដ្ឋប្បវេណីកម្ពុជា

[35] មើលមាត្រា៧៣២ នៃក្រមរដ្ឋប្បវេណីកម្ពុជា

គ្រប់គ្រងដោយឈឺឆ្អាលឬទេ?

បើយោងតាមខ្លឹមសារនៃមាត្រា ៧៣១ នៃក្រមរដ្ឋប្បវេណី កម្មវត្ថុដែលត្រូវជូនដំណឹងនោះគឺ «ការបានចាប់ផ្តើមការគ្រប់គ្រងឈឺឆ្អាល» ។

«ការបានចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាល» មកពីការផ្សំបញ្ចូលគ្នារវាង «ការបាន» និង «ចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាល»។ «ការបាន» សម្តៅលើស្ថានភាពបញ្ជាក់ពីអតីតកាល មានន័យថា សកម្មភាពណាមួយបានកន្លងហួសទៅហើយ។

ដូច្នេះ ការជូនដំណឹងអំពី«ការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាល» គឺសម្តៅលើការជូនដំណឹងអំពីការចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាលដែលបានបំពេញរួចហើយ។ អ្នកទទួលការជូនដំណឹងគឺមានតែសាមីខ្លួនតែប៉ុណ្ណោះ ។

ដូចនេះ តើសាមីខ្លួន មានន័យយ៉ាងដូចម្តេច?

- សាមីខ្លួននេះ អាចត្រូវបានធ្វើការបកស្រាយ ដូចខាងក្រោម៖

• ចំពោះការគ្រប់គ្រងលើទ្រព្យ៖ សាមីខ្លួន នេះសម្តៅលើបុគ្គលដែលមានសិទ្ធិលើទ្រព្យ ពោលគឺមានសិទ្ធិប្រត្យក្ស លើទ្រព្យដែលជាកម្មវត្ថុនៃការគ្រប់គ្រងដោយឈឺឆ្អាលនោះ ដូចជា កម្មសិទ្ធិករនៃទ្រព្យ អ្នកកាន់កាប់ទ្រព្យផលុបភោគី .....។ល។

• ចំពោះការគ្រប់គ្រងលើមនុស្ស៖ សាមីខ្លួននេះ សម្តៅលើបុគ្គល ដែលមានសិទ្ធិលើបុគ្គលនោះ តាមរយៈអ្នកតំណាងតាមច្បាប់កំណត់ និង ហិតូបត្ថម្ភកៈ។

សរុបមក សាមីខ្លួន មានន័យថាសម្តៅដល់ បុគ្គលដែលទទួលផលប្រយោជន៍ ឬ បុគ្គលដែលទ្រព្យរបស់ខ្លួនត្រូវបានគេគ្រប់គ្រង។

ក្នុងករណី អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនបានស្គាល់សាមីខ្លួនទេនោះអ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនចាំបាច់ធ្វើការជូនដំណឹងនេះទេ ពោលគឺនៅតែបន្តការគ្រប់គ្រងតទៅទៀត។

- ការជូនដំណឹងត្រូវធ្វើឡើងដោយគ្មានការយឺតយ៉ាវ៖ «គ្មានការយឺតយ៉ាវ» អាចត្រូវបានវិនិច្ឆ័យយ៉ាងដូចម្តេច?

✍ ការយឺតយ៉ាវ ឬ គ្មានការយឺតយ៉ាវ អាចត្រូវធ្វើការវិនិច្ឆ័យតាមលក្ខណៈនៃការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល។

✍ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ គឺជាកិច្ចការតែមួយផងអ្នកគ្រប់គ្រងហាក់ដូចជាមិនចាំបាច់ធ្វើការជូនដំណឹងទេ ។

ប៉ុន្តែ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវមានករណីយកិច្ចរាយការណ៍នៅចុងបញ្ចប់ អ្នកគ្រប់គ្រងត្រូវតែជូនដំណឹងទៅសាមីខ្លួន ទោះបីជាកិច្ចការគ្រប់គ្រងជាកិច្ចការតែមួយដងក៏ដោយ។

ដើម្បីបញ្ជាក់ពីគ្មានភាពយឺតយ៉ាវនៃការជូនដំណឹងនេះ អ្នកគ្រប់គ្រងត្រូវធ្វើការជូនដំណឹងទៅសាមីខ្លួនតាមគ្រប់មធ្យោបាយតាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងការជូនដំណឹងទៅសាមីខ្លួននេះ លើកលែងតែសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះមិនចាំបាច់ឡើយ[36] ។

[36] មើលមាត្រា៧៣១ នៃ ក្រមរដ្ឋប្បវេណីកម្ពុជា

២. ករណីយកិច្ចបន្តការគ្រប់គ្រង

ជាគោលការណ៍ អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន [37]។

- ឧទាហរណ៍៖

លោក **ក** ដែលកំពុងជួសជុល និងថែរក្សាផ្ទះឱ្យលោក **ខ** នោះតាមរយៈការគ្រប់គ្រងដោយឈឺឆ្អាលនោះ ។ នៅពេលដែលលោក **ខ** មិនបានមកដល់ ឬ មិនអាចគ្រប់គ្រងបន្តបាន នោះលោក **ក** នៅតែមានករណីយកិច្ចបន្តការគ្រប់គ្រងដើម្បីប្រយោជន៍របស់លោក **ខ** ដដែល។

តាមន័យនេះ អ្នកគ្រប់គ្រង នៅតែបន្តការគ្រប់គ្រងកម្មវត្ថុនៃការគ្រប់គ្រងដោយឈឺឆ្អាលដដែល រហូតដល់ពេលការគ្រប់គ្រងត្រូវបានបញ្ចប់។

✍ ការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបានបញ្ចប់ដូចខាងក្រោម៖

- សាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួននោះអាចធ្វើការគ្រប់គ្រងបាន។ មានន័យថា ទោះបីជាសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួន បានដឹង ឬ បានមកដល់ក៏ដោយ ក៏អ្នកគ្រប់គ្រងដោយឈឺឆ្អាល នៅតែបន្តការគ្រប់គ្រងដដែល លុះត្រាតែជនទាំងនោះ អាចធ្វើការគ្រប់គ្រងបាន ។

- ឧទាហរណ៍ទី១៖

(ការជួសជុលផ្ទះរបស់លោក **ខ** ដោយលោក **ក** ខាងលើ) នៅពេលដែលលោក **ខ** ដែលជាសាមីខ្លួនបានមកដល់ផ្ទះរបស់ខ្លួន ហើយឃើញលោក **ក** ជួសជុលផ្ទះឱ្យខ្លួនបែបនេះ ខ្លួនសប្បាយចិត្តជាខ្លាំងជាមួយនឹងលោក **ក** ដែលបានជួយយកអាសារគាត់។ ពេលនោះលោក **ខ** ក៏បានចូលមករស់នៅ និងចេញសោហ៊ុយជូនលោក **ក** ។ តើលោក **ខ** អាចគ្រប់គ្រងបានឬទៅ?

- ឧទាហរណ៍ទី២៖

(ផ្ទុយនឹងឧទាហរណ៍ខាងលើ) នៅពេលដែលលោក **ខ** ឃើញដូចនោះ ខ្លួនបានការមិនសប្បាយចិត្តជាមួយនឹងលោក **ក** ដែលបានជួសជុលផ្ទះរបស់ខ្លួន ដោយគ្មានការប្រុងប្រយ័ត្ន និង ខ្លួនមិនពេញចិត្ត។ ពេលនោះ លោក **ខ** ក៏បានបង្ហាញឆន្ទះទៅកាន់លោក **ក** ថា ខ្លួនមិនចូលនៅទេ ប្រសិនលោក **ក** មិនជួសជុសឱ្យស្អាតជាងនេះ។ ករណីនេះ តើលោក **ខ** អាចគ្រប់គ្រងបានឬទៅ?

- ឧទាហរណ៍ទី៣៖

(ការជួសជុលផ្ទះរបស់លោក **ខ** ដោយលោក **ក** ខាងលើ) ខណៈពេលដែលលោក **ក** កំពុងជួសជុលស្រាប់តែលោក **ខ** បានមកដល់។ ប៉ុន្តែលោក **ក** មិនទាន់បានជួសជុលរួចរាល់នោះទេ ហើយផ្ទះនោះក៏មិនអាចចូលមកស្នាក់នៅបានដែរ ដែលជាហេតុធ្វើឱ្យលោក **ខ** និងគ្រួសារស្នាក់នៅផ្ទះរបស់លោក **ក** ជាបណ្តោះអាសន្ន។ ករណីនេះ តើលោក **ខ** អាចគ្រប់គ្រងបានឬទៅ?

- ឧទាហរណ៍ទី៤៖

(ការជួសជុលផ្ទះរបស់លោក **ខ** ដោយលោក **ក** ខាងលើ) លោក **ខ** ក្លាយជាជនដែលវិបត្តិស្មារតី ដែលខ្លួន

[37] មើលមាត្រា៧៣២ នៃក្រមរដ្ឋប្បវេណីកម្ពុជា

មិនអាចធ្វើការគ្រប់គ្រងបានទេ ។

នីតិវិធីនៃការជ្រើសរើសអ្នកអាណាព្យាបាលទូទៅ ឬ ហិតូបម្កកៈ អាស្រ័យទៅតាមស្ថានភាពនៃលោក **ខ** ត្រូវបានចាប់ផ្តើមតាមផ្លូវតុលាការ។ អំឡុងពេលនោះ លោក **ក** នៅតែបន្តការគ្រប់គ្រងដដែល។ ក្រោយពីការជ្រើសរើស អ្នកអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈ របស់លោក **ខ** រួចមក អ្នកអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈ របស់លោក **ខ** បានធ្វើការគ្រប់គ្រងផ្ទះរបស់លោក **ខ** ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយឈឺឆ្អាលរបស់លោក **ក** ។

សួរថា តើអាណាព្យាបាលទូទៅរបស់លោក **ខ** អាចគ្រប់គ្រងបានឬទៅ? ក្នុងករណីលោក **ខ** ស្ថិតនៅក្នុងស្ថានភាពហិតូបត្ថម្ភកៈវិញ ដែលលោក **ខ** មិនអាចគ្រប់គ្រងបាន សួរថាតើ ហិតូបត្ថម្ភកៈ អាចគ្រប់គ្រងជំនួសលោក **ខ** បានដែរឬទេ ខណៈដែលច្បាប់បានចែងត្រឹមតែ អ្នកតំណាងដែលច្បាប់បានកំណត់ (ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់នោះទេ)?

- ឧទាហរណ៍ទី៥៖

ករណីដែលលោក **ខ** ទទួលមរណភាពនាំឱ្យសន្តតិជនលោក **ខ** នឹងធ្វើការគ្រប់គ្រងបន្តពីលោក **ក** ។ សួរថា សន្តតិជនរបស់លោក **ខ** អាចធ្វើការគ្រប់គ្រងបាននៅពេលណា? ចុះករណីដែលសន្តតិជនរបស់លោក **ខ** ជាជនបរទេស សួរថា តើសន្តតិជនរបស់លោក **ខ** នោះអាចគ្រប់គ្រងបាននៅពេលណា? ប្រសិនបើករណីដែលលោក **ខ** គ្មានសន្តតិជនវិញ ហើយយើងដឹងបានថា អ្នកដែលទទួលសន្តតិកម្មពីលោក **ខ** ចុងក្រោយគេគឺ រដ្ឋ។ សួរថា អំឡុងពេលនៃនីតិវិធីនៃសន្តតិកម្មតាមផ្លូវតុលាការនោះ តើលោក **ក** នៅតែបន្តការគ្របគ្រងដដែលឬយ៉ាងណា?

- ការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ៖ មានន័យថា សាមីខ្លួនគ្មានឆន្ទៈឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាលបន្តការគ្រប់គ្រងកិច្ចការរបស់ខ្លួនបន្តទៀតបានទេ។

ករណីនេះ សាមីខ្លួនអាចមានបំណងចង់គ្រប់គ្រងដោយខ្លួនឯងវិញ ឬអាចមានបំណងចង់ឱ្យតតិយជន ធ្វើការគ្រប់គ្រងជំនួសឱ្យអ្នកគ្រប់គ្រងក្នុងពេលមានវត្តមានសាមីខ្លួន។

- ការបន្តការគ្រប់គ្រងនោះ នឹងអាចធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ៖ មានន័យថា អាចប៉ាន់ប្រមាណទុកជាមុនថា ប្រសិនបើអ្នកគ្រប់គ្រងនៅតែបន្តការគ្រប់គ្រងតទៅទៀតនោះ ប្រាកដជានឹងមានការបាត់បង់នូវទ្រព្យសម្បត្តិឬ ខូចប្រយោជន៍របស់សាមីខ្លួន ដែលបង្កឡើងដោយអ្នកគ្រប់គ្រងជាមិនខាន។

ករណីនេះ ការគ្រប់គ្រងដោយឈឺឆ្អាលរបស់អ្នកគ្រប់គ្រងត្រូវបានបញ្ចប់។

គួរគូសបញ្ជាក់ថា បុគ្គលដែលទទួលប្រយោជន៍(សាមីខ្លួន)នៅទីនេះ បញ្ញត្តិក្រមរដ្ឋប្បវេណីបានកំណត់ត្រឹមតែបុគ្គលបីប្រភេទប៉ុណ្ណោះគឺ សាមីខ្លួន សន្តតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួន។

ផ្ទុយទៅវិញបាត់ពាក្យថា សហព័ទ្ធរបស់សាមីខ្លួន ឬញាតិរបស់សាមីខ្លួន ដូចនេះតើគេអាចដឹងសន្និដ្ឋានថា ការបន្តឬបញ្ចប់ការគ្រប់គ្រងមានអានុភាពត្រឹមកម្រិតបុគ្គលបីប្រភេទដែលអាចឱ្យអ្នកគ្រប់គ្រងបន្តគ្រប់គ្រង ឬបញ្ចប់ការគ្រប់គ្រង។

ហេតុនេះបើធ្វើការបកស្រាយបែបនេះ គឺវាផ្ទុយទៅនឹងបញ្ញត្តិស្តីពីករណីសហការរួមរបស់សហព័ទ្ធក្នុងជីវភាពរស់ប្រចាំថ្ងៃ (ចំពោះទំនាក់ទំនងសាមីខ្លួន និងសហព័ទ្ធរបស់សាមីខ្លួន)។

ចំពោះករណី ទំនាក់ទំនងញាតិរបស់សហព័ទ្ធវិញ ការដែលមិនបានចែងដូចនេះហាក់ដូចជាផ្ទុយទៅ

គោលគំនិតនៃការឈឺឆ្អាលជួយគ្នាក្នុងសង្គមហើយដែលក្នុងសង្គមខ្មែរទំនាក់ទំនងញាតិគឺជាបញ្ហាសំខាន់ដែលគេអាចដឹងជាទូទៅថាញាតិរបស់សាមីខ្លួនអាចមានលទ្ធភាពជួយគ្រប់គ្រងកិច្ចការនោះបាន។

ជាគំនិតរបស់ខ្ញុំបាទ មាត្រា ៧៣២ គួរចែងថា «អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកដែលមានទំនាក់ទំនងតាមផ្លូវច្បាប់របស់ខ្លួន....» ទើបគ្របដណ្តប់ចំពោះទំនាក់ទំនងខ្លឹមសារដែលមានក្នុងមាត្រានេះ ម្យ៉ាងដើម្បីអាចកំណត់ពីទំហំនៃបុគ្គលដែលពាក់ព័ន្ធតាមច្បាប់កំណត់មានសិទ្ធិទទួលនូវកិច្ចការគ្រប់គ្រងបន្តពីអ្នកគ្រប់គ្រង។

៣. ករណីយកិច្ចប្រគល់

នៅពេលដែលការគ្រប់គ្រងត្រូវបានបញ្ចប់ អ្នកគ្រង់គ្រងដោយឈឺឆ្អាលត្រូវប្រគល់ប្រាក់ និង ទ្រព្យផ្សេងទៀតដែលទទួលបានតាមការគ្រប់គ្រងរបស់ខ្លួនទៅឱ្យសាមីខ្លួន។ អ្នកគ្រប់គ្រងក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅសាមីខ្លួនវិញដែរ។ សិទ្ធិដែលអ្នកគ្រប់គ្រងបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួនដើម្បីសាមីខ្លួននោះ ត្រូវផ្ទេរទៅឱ្យសាមីខ្លួនវិញ[38]។

តាមខ្លឹមសារនេះ មានន័យថានៅពេលដែលការគ្រប់គ្រងត្រូវបានបញ្ចប់ អ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវប្រគល់ទៅឱ្យសាមីខ្លួនវិញនូវប្រាក់ និង ទ្រព្យផ្សេងទៀតដែលបានមកពីការគ្រប់គ្រង។

- ឧទាហរណ៍៖

នៅអំឡុងពេលនៃការគ្រប់គ្រង អ្នកគ្រប់គ្រងបានទទួលនូវប្រាក់ និង ទ្រព្យមួយចំនួន តាមរយៈការគ្រប់គ្រងនូវកិច្ចការនោះ។

ករណីនេះ អ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវប្រគល់ប្រាក់ និង ទ្រព្យដែលខ្លួនបានទទួលទៅឱ្យសាមីខ្លួនវិញនៅពេលបញ្ចប់ការគ្រប់គ្រង[39]។

✍ ផល (ផលស៊ីវិល និង ផលធម្មជាតិ) ដែលអ្នកគ្រប់គ្រងបានទទួលតាមរយៈការគ្រប់គ្រងកិច្ចការនោះ អ្នកគ្រប់គ្រងត្រូវប្រគល់ផលនោះ ទៅឱ្យសាមីខ្លួននៅពេលបញ្ចប់ការគ្រប់គ្រង។

- ផលស៊ីវិល សម្តៅលើ[40]៖
  - ប្រាក់ដែលបានមកពីវត្ថុ ឬពីប្រាក់ ដូចជា ការប្រាក់ ឬឈ្នួលផ្ទះជាដើម
  - ប្រាក់ឬវត្ថុផ្សេងៗ ដែលបានទទួលជាថ្នូរចំពោះការប្រើវត្ថុណាមួយ
  - ក្នុងច្បាប់ទ្រព្យសម្បត្តិកម្ពុជា គឺប្រាក់ចំណូលដែលបានថ្លៃឈ្នួលផ្ទះ និងចុងការដែលសិទ្ធិវន្ត(អ្នកមានសិទ្ធិលើវត្ថុណាមួយ) ត្រូវទទួលបាន។
- ផលធម្មជាតិ[41] សម្តៅលើ
  - វត្ថុដើលកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្ម តាមវិធីប្រើធម្មតា
  - ផលិតផល ដែលកើតអំពីដីធ្លី ឬកូនសត្វស្រុក ដែលកើតពីមេបាវាមក

---

[38] មើលមាត្រា៧៣៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា២០០៧

[39] មើលមាត្រា៦៤២ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[40] វចនានុក្រមតម្រាច្បាប់

[41] វចនានុក្រមតម្រាច្បាប់

- ផលដែលកើតចេញពីដី ឬកូនសត្វដែលកើតពីមេរបស់វា

✍ សិទ្ធិដែលបានលទ្ធកម្មដើម្បីសាមីខ្លួនក៏ត្រូវប្រគល់ទៅឱ្យសាមីខ្លួនវិញដែរនៅពេលបញ្ចប់ការគ្រប់គ្រង។ លទ្ធកម្មនៅទីនេះ សម្តៅទៅលើ ការទទួលបាន។

៤. ករណីយកិច្ចរាយការណ៍

ករណីមានការទាមទាររបស់សាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវរាយការណ៍អំពីស្ថានភាពនៃការគ្រប់គ្រងកិច្ចការ ទោះបីជាយ៉ាងណាក៏ដោយ ឬត្រូវរាយការណ៍អំពីភាពនៃការគ្រប់គ្រងកិច្ចការ ទោះបីជានៅពេលក៏ដោយឬត្រូវរាយការណ៍អំពីហេតុការណ៍ដោយគ្មានការយឺតយ៉ាវនៅក្រោយពេលបញ្ចប់ការគ្រប់គ្រង[42]។

នៅក្នុងស្ថានភាពមួយដែល សាមីខ្លួនមានការបារម្ភអំពីការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដូចជា សាមីខ្លួនមានការបារម្ភថា អ្នកគ្រប់គ្រងបានគ្រប់គ្រងដោយមានចេតនាទុច្ចរិត ឬមានការធ្វេសប្រហែស ឬបណ្តាលឱ្យមានព្យសនកម្មណាមួយបានកើតឡើង។ ទើបសាមីខ្លួនអាចស្នើឱ្យអ្នកគ្រប់គ្រងធ្វើការរាយការណ៍អំពីហេតុការណ៍នៃការគ្រប់គ្រងឱ្យមកខ្លួន។

ករណីនេះ អ្នកគ្រប់គ្រង មានករណីយកិច្ចដូចខាងក្រោមៈ

✍ ត្រូវរាយការណ៍អំពីស្ថានភាពនៃការគ្រប់គ្រងកិច្ចការ ឬ អំពីភាពនៃការគ្រប់គ្រងកិច្ចការ ឬ អំពីហេតុការណ៍ ។

✍ ត្រូវរាយការណ៍គ្រប់ពេលវេលាមានន័យថា អ្នកគ្រប់គ្រងត្រូវរាយការណ៍ភ្លាមនៅពេលដែលមានការទាមទារពីសាមីខ្លួន។

✍ ត្រូវរាយការណ៍ដោយគ្មានការយឺតយ៉ាវ។

៥. ករណីយកិច្ចសងសំណងនៃការខូចខាត

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាលដើម្បីបុគ្គលណាមួយ ហើយបានធ្វើឱ្យមានការខូចខាតដល់បុគ្គលនោះ។

ករណីនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតដល់សាមីខ្លួន [43]។

ការបញ្ញត្តិនូវមាត្រាខាងលើនេះ វាហាក់ដូចជាធ្វើឱ្យមាននូវការប៉ះទង្គិចផ្លូវចិត្តរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលគួរសមដែរ ដោយហេតុអ្នកគ្រប់គ្រងឈឺឆ្អាលបានចំណាយកម្លាំងចិត្ត កម្លាំងកាយ រួមទាំងថវិកាផ្ទាល់ខ្លួនធ្វើសកម្មភាពមួយចំនួនដោយរងនូវការប្រឈមការចោទប្តឹងនានាពីសាមីខ្លួន(ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានធ្វើការគ្រប់គ្រងដោយមិនត្រឹមត្រូវទេអាចនឹងការចោតប្រកាន់ពីបទព្រហ្មទណ្ឌ)ប៉ុន្តែគឺធ្វើដើម្បីប្រយោជន៍សាមីខ្លួនតែប៉ុណ្ណោះ ពោលគឺធ្វើតាមមនសិការ និងការទទួលខុសត្រូវក្នុងនាមជាអ្នកជិតខាងនឹងគ្នា។

នៅពេលដែលមានការខូចប្រយោជន៍ណាមួយរបស់សាមីខ្លួនដែលកើតឡើងដោយសារការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលនោះបែរជាតម្រូវឱ្យអ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវសងនូវការខូតខាតនោះទៅសាមីខ្លួនទៅវិញ[44] ។

---

[42] មើលមាត្រា៧៣៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[43] មើលមាត្រា៧៣៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[44] មើលមាត្រា៧៣៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

បើធ្វើការពិចារណាជាដំបូង វាហាក់ដូចជាមិនបានលើកទឹកចិត្តឱ្យមនុស្សចេះជួយគ្នាទៅវិញទៅមកទេនៅក្នុងសង្គម ដែលផ្ទុយពីគោលគំនិតនៃការគ្រប់គ្រងដោយឈឺឆ្អាល ដែលបានលើកឡើងខាងលើ។

ក្នុងករណីដែលគ្មានបញ្ញត្តិនេះទេ វានឹងអាចធ្វើឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាលធ្វើការគ្រប់គ្រងដោយខ្ជីខ្ជាមិនយកចិត្តទុកដាក់ ពោលគឺធ្វើឱ្យរួចតែពីដៃដោយហេតុទោះបីជាខ្លួនធ្វើការគ្រប់គ្រងតាមវិធីណាក៏ដោយលទ្ធផលបែបណាក៏ដោយក៏អ្នកគ្រប់គ្រងគ្មានករណីយកិច្ចត្រូវសងនូវការខូចខាតចំពោះទង្វើខ្លួនឯងដែរ។

ការបញ្ញត្តិនូវការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលចំពោះការខូចខាតបែបនេះ គឺជាការលើកទឹកចិត្តឱ្យអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រងដោយសណ្ដានចិត្តបរិសុទ្ធ ដោយមិនខ្លាចរងនូវការទទួលខុសត្រូវណាមួយឡើយ ដើម្បីប្រយោជន៍សាមីខ្លួន។

បញ្ញត្តិនេះ ក៏ជាអាចជួយឱ្យអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រងដោយប្រុងប្រយ័ត្ននិងទំនួលខុសត្រូវខ្ពស់ ពោលគឺអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងកិច្ចការរបស់សាមីខ្លួន ដូចជាការគ្រប់គ្រងកិច្ចរបស់ខ្លួន។

✍ ត្រង់ចំណុចនេះក៏អាចនឹងមានបញ្ហាចោទឡើងមួយដែរថាៈ

ចុះបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងកិច្ចការរបស់សាមីខ្លួន តាមទម្លាប់ដែលខ្លួនបានធ្វើការគ្រប់គ្រងកិច្ចការរបស់ខ្លួនទៅហើយ បែរជាសាមីខ្លួនលើកឡើងវិញថា ការគ្រប់គ្រងនេះ មិនល្អ មិនប្រុងប្រយ័ត្ន និង មិនយកចិត្តទុកដាក់ទៅវិញ ពោលគឺធ្វើឱ្យតែរួចពីដៃ សួរថាករណីនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាល មានករណីយកិច្ចសងការខូចខាតណាមួយឬទេ?

ជាពិសេសទៅទៀតនោះ ការបញ្ញត្តិនូវមាត្រានេះ គឺបង្ការនូវការយកការគ្រប់គ្រងដោយឈឺឆ្អាល មកធ្វើជាការកេងចំណេញ ឬការទទួលបានផលប្រយោជន៍ណាមួយ។

ករណីនេះ អាចជាចេតនារបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលដែលខ្លួនមានបំណងទទួលបាននូវប្រយោជន៍អ្វីមួយពីសាមីខ្លួន ហើយខ្លួនបានក្លែងធ្វើជាការគ្រប់គ្រង ។

៦. ករណីយកិច្ចគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាម៉ីខ្លួន ឬតាមវិធីសមរម្យ

ករណីដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ ។

ករណីដែលមិនបានដឹងទេ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រងដោយព្យាយាម ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេដើម្បីប្រយោជន៍របស់សាមីខ្លួន[45] ផ្អែកតាមលក្ខណៈនៃកិច្ចការមានន័យថា ការគ្រប់គ្រងកិច្ចការដោយមានការយកចិត្តទុកដាក់ខ្ពស់ដែលអ្នកប្រកបដោយវិចារណញ្ញាណនឹងធ្វើក្នុងស្ថានភាពជាក់លាក់មួយ។

ការគ្រប់គ្រងដោយផ្ទុយពីឆន្ទៈរបស់សាមីខ្លួនត្រូវបញ្ឈប់ការគ្រប់គ្រងជាបន្ទាន់លើកលែងតែក្នុងស្ថានភាពពិសេសដែលការរង់ចាំនឹងបង្កនូវការខូចខាតដល់ផលប្រយោជន៍របស់សាមីខ្លួន។ ក្រៅពីករណីយកិច្ចរបស់អ្នកគ្រប់គ្រង ក៏អ្នកដែលត្រូវបានគេគ្រប់គ្រងមានករណីយកិច្ចដូចគ្នាផងដែរ។

[45] មើលមាត្រា៧២៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា

## កថាភាគទី២. ករណីយកិច្ចរបស់អ្នកត្រូវបានគេគ្រប់គ្រង

១. ករណីយកិច្ចប្រគល់សោហ៊ុយលើការគ្រប់គ្រង

ក្នុងករណីដែលអ្នកគ្រប់គ្រងបានបំពេញសកម្មភាពជាប្រយោជន៍ដល់ម្ចាស់ទ្រព្យក្នុងការចំណាយលើសម្ភារៈផ្សេងៗ ក្នុងគោលបំណងការពារផលប្រយោជន៍របស់សាមីខ្លួន។

សរបញ្ជាក់ថា ភាពមានទំនាក់ទំនងជួយគ្នាទៅវិញទៅមកដើម្បីស្ថាបនាឬក៏ជួយផ្ដត់ផ្គង់គ្នាក្នុងគ្រាអាសន្ន។

ហេតុដូច្នេះ ទើបច្បាប់បានកំណត់ឱ្យមានករណីយកិច្ចលើម្ចាស់ទ្រព្យត្រូវប្រគល់សងនូវរាល់ការចំណាយទៅឱ្យអ្នកគ្រប់គ្រងវិញ តាមភាពជាក់ស្តែងដែលបានកើតឡើង[46]។

✚ ឧទាហរណ៍៖

**ក** ឃើញស្ថានភាពផ្ទះធ្លុះដំបូលស័ង្កសី ដោយ **ខ** ជាម្ចាស់ផ្ទះមិននៅផ្ទះ។ **ក** សុំយោបល់ពី **ខ** ថាខ្លួនជួយជួសជុលដំបូលផ្ទះឱ្យហើយ **ខ** ក៏យល់ព្រមតាមសំណើរបស់ **ក** ក្នុងគោលបំណងការពារទ្រព្យសម្បត្តិរបស់ខ្លួន កុំឱ្យខូចខាតដោយសារទឹកភ្លៀង ទើប **ក** ទិញស័ង្កសីថ្មីមកប្រក់ចំនួន ៥ សន្លឹក ដូចមានបញ្ជាក់ក្នុងវិក័យបត្រស្រាប់។ ប៉ុន្តែក្នុងករណីនេះ គេមិនគិតថ្លៃសេវា ឬវិជ្ជាជីវៈផ្សេងៗបញ្ចូលគ្នាដូចកម្រៃទេ។

២. ករណីយកិច្ចប្រគល់កម្រៃ

ចំពោះបញ្ហានេះ សាមីខ្លួនមានករណីយកិច្ចត្រូវប្រគល់កម្រៃដល់អ្នកគ្រប់គ្រង នៅពេលដែលខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះដែរ រួមទាំងវិជ្ជាជីវៈ ឬអាជីវកម្មរបស់អ្នកគ្រប់គ្រងចំពោះកិច្ចការនោះ។

ចំណុចនេះមានន័យថា បន្ទាប់ពីអ្នកគ្រប់គ្រងបានជួសជុលជំនួសខ្លួនហើយនោះអ្នកគ្រប់គ្រងមិនត្រឹមតែទទួលត្រឡប់មកវិញនូវរាល់ការចំណាយរបស់ខ្លួនប៉ុណ្ណោះទេហើយគាត់ក៏អាចទទួលនូវការលើកទឹកចិត្តពីបេសកកម្មនេះបានដែរ[47]។

៣. ករណីយកិច្ចគិតអត្រាការប្រាក់ចំពោះការយឺតយ៉ាវ

ប្រសិនបើម្ចាស់ទ្រព្យ គាត់បានដឹងអំពីការចំណាយឬការបង្កើនតម្លៃនៃទ្រព្យរបស់ខ្លួនហើយ នៅពេលដែលអ្នកគ្រប់គ្រងមានការទាមទារនូវការចំណាយនោះត្រឡប់មកវិញប៉ុន្តែម្ចាស់ទ្រព្យមានការយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ចរបស់ខ្លួនមិនបានហើយធ្វើឱ្យមានការពន្យាពេលនៃការប្រគល់សងនេះតាមការកំណត់ហើយ។

បញ្ញត្តិនៃក្រមរដ្ឋប្បវេណីបានកំណត់អំពីការយឺតយ៉ាវដោយគិតអត្រាការប្រាក់តាមច្បាប់កំណត់ ប្រសិនបើគ្មានការព្រមព្រៀងគ្នាពីការប្រាក់ទេគឺក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកជួយខ្លួនដោយឥតប្រយោជន៍។

✚ ឧទាហរណ៍៖

លោក **ក** បានដឹងអំពីការគ្រប់គ្រង និងការចំណាយផ្សេងៗពីលោក **ខ** ហើយបានយល់ព្រមទទួលស្គាល់ចំពោះ ការសងនូវការចំណាយផ្សេងៗដែលបានធ្វើឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឈឺឆ្អាល។ ប៉ុន្តែលោក **ក** រវល់ទៅប្រទេសក្រៅមួយរយៈពេលធំ។ ចំណែកលោក **ខ** ដែលបានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីជួយសង្គ្រោះផ្ទះរបស់លោក **ក** គឺខាតបង់ប្រាក់និងពេលវេលាផ្ទាល់ខ្លួនឯង។

---

[46] មើលមាត្រា៧៣៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[47] មើលមាត្រា៧៣៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា

ដូចនេះ លោក ខ អាចទាមទារឱ្យលោក ខ គិតការប្រាក់ចំពោះការសងមកយឺតយ៉ាវមកខ្លួន ក្នុងសកម្មភាពចំណាយលើការគ្រប់គ្រងនោះ។

ម្យ៉ាងទៀត បើគូភាគីមិនបានគិតអត្រាការប្រាក់ដោយខ្លួនឯងទេ គឺគូភាគីជ្រើសរើសអត្រាការប្រាក់តាមច្បាប់កំណត់បាន។

ដូចនេះ វាមានន័យថា ការលើកទឹកចិត្តដល់ជនដែលជួយឈឺឆ្អាលការពារផលប្រយោជន៍ដែលមិនមែនជាផលប្រយោជន៍របស់ខ្លួន។

## ផ្នែកទី២. ករណីយកិច្ចក្នុងសេចក្តីចម្រើនដោយឥតហេតុ

១. ករណីយកិច្ចសងរបស់អ្នកទទួលប្រយោជន៍ដោយសុចរិត

ចំពោះកាតព្វកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬកម្លាំងពលកម្មរបស់អ្នកដទៃបើទោះជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ ក៏អ្នកទទួលផលប្រយោជន៍ត្រូវមានកាតព្វកិច្ចសងផលប្រយោជន៍ទាំងនោះទៅអ្នកបាត់បង់ផលប្រយោជន៍វិញ។

តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងគោលការណ៍ច្បាប់ក៏មានការយោគយល់ដែរចំពោះអ្នកទទួលផលប្រយោជន៍ដែលទទួលរងនូវការខូចខាតនៅពេលដែលត្រូវបង្គាប់ឱ្យសងទៅវិញនូវផលប្រយោជន៍ដែលគាត់ទទួលបានក្រោយពេលបរិភោគផលប្រយោជន៍នោះរួចហើយគាត់ត្រូវសងទៅវិញត្រឹមតែផលប្រយោជន៍ដែលមានតែប៉ុណ្ណោះ ប្រសិនបើគាត់សុចរិត។

យើងក៏និយាយម្យ៉ាងទៀតថា ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍បានដឹងថាផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្តទេ បុគ្គលនោះអាចត្រូវបាននិយាយថា បានដឹងថាផលប្រយោជន៍នោះជារបស់បុគ្គលដទៃ។

ហេតុដូច្នេះ កថាខណ្ឌទី១ ចែងថា នៅក្នុងករណីបែបនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលខ្លួនបានដឹងពីការណ៍នោះជាមួយគ្នានឹងការប្រាក់ដែលបានមកពីផលប្រយោជន៍នោះ។

ទោះបីជាបុគ្គលដែលបានទទួលផលប្រយោជន៍នោះមិនបានដឹងអំពីការណ៍នោះពីដំបូង(សុចរិត)ក៏ដោយ ប្រសិនបើបុគ្គលនោះក្លាយទៅជាទុច្ចរិតវិញ ក៏មាត្រា ៧៣៩ ត្រូវយកមកអនុវត្តដែរ។

២. ករណីយកិច្ចសងរបស់អ្នកទទួលប្រយោជន៍ដោយទុច្ចរិត

ប្រសិនបើអ្នកទទួលផលប្រយោជន៍នោះទុច្ចរិត ព្រមទាំងបានដឹងថាខ្លួនបានទទួលផលប្រយោជន៍ដែលគ្មានមូលហេតុគតិយុត្តពីអ្នកដទៃ ហើយធ្វើឱ្យខូចខាតផលប្រយោជន៍របស់អ្នកដទៃទៀតនោះ អ្នកទទួលផលប្រយោជន៍ត្រូវសងនូវសំណងនៃការខូចខាត រួមទាំងការប្រាក់នៃផលប្រយោជន៍នោះទៅអ្នកខូចខាត ឬបាត់បង់ផលប្រយោជន៍វិញ។

- ឧទាហរណ៍៖

ប្រសិនបើកិច្ចសន្យាបានលុបចោលដោយសារការឆបោក។គេអាចនិយាយបានថាជនឆបោកនោះ បានដឹងថា ផលប្រយោជន៍ដែលខ្លួនទទួលបាននឹងគ្មានមូលហេតុគតិយុត្តដោយសារការលុបចោលនាអនាគត។

ក្នុងករណីនេះ ជនឆបោកអាចត្រូវបានចាត់ទុកថាបានដឹងថា ខ្លួនគ្មានមូលហេតុគតិយុត្តក្នុងការទទួល

ប្រយោជន៍ទេ។

កថាខណ្ឌទី២ នៃមាត្រា ៧៣៧ បានបញ្ជាក់ច្បាស់លាស់អំពីបញ្ហានេះ ហើយការចាត់ចែងបែបនេះគួរធ្វើឡើងមិនគ្រាន់តែក្នុងករណីដែលបុគ្គលដែលបានទទួលផលប្រយោជន៍មានចេតនាប៉ុណ្ណោះទេព្រមទាំងករណីដែលបុគ្គលនោះមានកំហុសដែរ។

ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវយកមកអនុវត្ត មិនមែនតែចំពោះករណីដែលបុគ្គលបានទទួលប្រយោជន៍ដោយចេតនាប៉ុណ្ណោះទេ ព្រមទាំងចំពោះករណីដែលបុគ្គលបានផលប្រយោជន៍ដោយមានកំហុសផងដែរ។

ប្រសិនបើបុគ្គលដែលបង្កឱ្យមានការបាត់បង់ផលប្រយោជន៍ក៏ទទួលរងនូវការខូចខាតដែរ។ បុគ្គលដែលបានទទួលផលប្រយោជន៍ដែលបានដឹង ឬគួរអាចដឹងបានថាផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្តត្រូវសងការខូចខាតនោះ។

# ជំពូកទី៣
# អានុភាព

អានុភាពក្នុងកាតព្វកិច្ចឧបសន្យាបានសម្តៅទៅលើអានុភាពក្នុងការគ្រប់គ្រងដោយឈឺឆ្អាល និងអានុភាពក្នុងសេចក្តីចម្រើនដោយឥតហេតុ។

## ផ្នែកទី១. អានុភាពក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

អានុភាពក្នុងការគ្រប់គ្រងដោយឈឺឆ្អាល គឺលើកឡើងនូវសិទ្ធិទាមទាររបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល និងសាមីខ្លួន។

### កថាភាគទី១. អានុភាពរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១. សិទ្ធិទាមទារឱ្យសងសោហ៊ុយវិញ

អត្ថប្រយោជន៍ក្នុងការទទួលស្គាល់ការបង្កើតសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាល មាននៅត្រង់ចំណុចថា ប្រសិនបើសកម្មភាពគ្រប់គ្រងត្រូវបានចាត់ទុកថាជាស្របច្បាប់ ករណីយកិច្ចមួយចំនួននឹងកើតឡើងចំពោះសាមីខ្លួន ដោយសារតែសកម្មភាពស្របច្បាប់របស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល។

ក្នុងចំណោមករណីយកិច្ចដែលកើតឡើងចំពោះសាមីខ្លួន ករណីយកិច្ចមួយដែលទទួលស្គាល់ដោយមិនមានមន្ទិល គឺករណីយកិច្ចសងនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង។ បើនិយាយពីទស្សនៈនៃអ្នកគ្រប់គ្រងវិញ វាគឺជាសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយ។

ប្រសិនបើអ្នកគ្រប់គ្រងបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាទ្រព្យ ឬចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

តាមខ្លឹមសារនៃ មាត្រា ៧៣៤ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារឱ្យសាមីខ្លួនសងនូវសោហ៊ុយដែលខ្លួនបានចំណាយនៅក្នុងអំឡុងពេលនៃការគ្រប់គ្រងនោះវិញបានលុះត្រាតែសោហ៊ុយចំណាយនោះគឺជាចាំបាច់៖

តើភាពចាំបាច់នៃការចំណាយនោះអាចបានត្រូវវិនិច្ឆ័យដោយរបៀបណា?

ឧទាហរណ៍៖

បើក្នុងករណីដែលអ្នកគ្រប់គ្រង បានចំណាយលើការទិញស័ង្កសី និងការជួសជុលជាងមកជួសជុលវិញ៖

- តើជាការចំណាយលើការចាំបាច់ដែរទេ ?
- ឬអ្នកគ្រប់គ្រងបានទិញសម្ភារៈផ្សេងទៀតដើម្បីបំពាក់ស័ង្កសីនោះ ដើម្បីការពារប្រយោជន៍ ទ្រព្យកុំឱ្យបែកបាក់ ឬផ្ទុះធ្លាយជាដើម សួរថា នេះជាការចំណាយចាំបាច់ឬ?
- ឬម្យ៉ាងវិញទៀត អ្នកគ្រប់គ្រង ជួលជាងដែលមានតម្លៃខ្ពស់ជាតម្លៃដែលសាមីខ្លួនធ្លាប់ជួល សួរថា តើនេះជាការចំណាយចាំបាច់ដែរឬទេ?

ប្រសិនបើសាមីខ្លួនមិនមានបញ្ហា ឬមិនយកចិត្តទុកលើការចំណាយនោះទេ វាមិនចាំបាច់ឱ្យអ្នកគ្រប់គ្រងធ្វើការពិចារណានោះទេ ព្រោះថា អ្នកគ្រប់គ្រងអាចនឹងទទួលបានមកវិញ។

ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើសាមីខ្លួន បានជាមនុស្សដែលមានបញ្ហាឬ គិតគូរយ៉ាងល្អិតល្អន់លើការចំណាយវិញ នោះអ្នកគ្រប់គ្រងចាំបាច់ត្រូវធ្វើការថ្លឹងថ្លែង។

តាមខ្លឹមសារនៃមាត្រានេះ ភាពចាំបាច់នៅទីនេះគឺភាពថ្លឹងថ្លែងរបស់អ្នកគ្រប់គ្រងដោយគាត់បានពិចារណាថា អ្វីដែលគួរចំណាយ ឬមិនគួរចំណាយ ព្រោះវាមានភាពទាក់ទងនឹងការទទួលបានមកវិញនូវការចំណាយរបស់ខ្លួនពីសាមីខ្លួន។

ហេតុដូច្នេះហើយ បានជាច្បាប់តម្រូវឱ្យអ្នកគ្រប់គ្រងធ្វើការថ្លឹងថ្លែងជាងការចំណាយលើការគ្រប់គ្រងលើទ្រព្យផ្ទាល់ខ្លួន។

✍ ការចំណាយសម្រាប់គ្រប់គ្រងនិង ថែរក្សាទ្រព្យឬចំណាយបង្កើនតម្លៃ៖ ក្រៅពីពិចារណាលើភាពចាំបាច់នៃការចំណាយហើយនោះ អ្នកគ្រប់គ្រងអាចយកចំណាយចាំបាច់នោះមកចំណាយតែលើទ្រព្យតែប៉ុណ្ណោះ មិនបានបញ្ញត្តិអំពីការចំណាយចាំបាច់ក្នុងការថែរក្សាបុគ្គលទេ។ មិនមែនឱ្យតែមានការចំណាយលើទ្រព្យនេះ អ្នកគ្រប់គ្រងអាចធ្វើការទាមទារពីសាមីខ្លួនបានទាំងអស់នោះទេ ពោលគឺត្រូវមានគោលបំណងនៃការចំណាយច្បាស់លាស់ជាក់ស្តែងនៅក្នុងក្រមរដ្ឋប្បវេណីត្រង់មាត្រាដដែលនេះ គឺគោលបំណងនៃការចំណាយលើទ្រព្យរួមមាន៖ ការគ្រប់គ្រង និងថែរក្សាទ្រព្យ ការបង្កើនតម្លៃ តែប៉ុណ្ណោះ។

ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការចំណាយផ្សេងពីគោលបំណងទាំងពីរនេះ នោះអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសាមីខ្លួន សងសោហ៊ុយវិញទេ។

✚ ឧទាហរណ៍៖

អ្នកគ្រប់គ្រង បានផ្តល់ប្រាក់លើកទឹកចិត្តដល់ជាងជួសជុលបន្ថែមលើថ្លៃឈ្នួល សួរថាតើ ប្រាក់លើកទឹកចិត្ត ចំណាយក្នុងគោលបំណងអ្វីហើយសាមីខ្លួនត្រូវមានករណីយកិច្ចសងសោហ៊ុយនេះទេ?

✍ ការចំណាយដើម្បីសាមីខ្លួន៖ មានន័យថា រាល់ការចំណាយទាំងប៉ុន្មានត្រូវធ្វើក្នុងគោលបំណងដើម្បីប្រយោជន៍របស់សាមីខ្លួនតែប៉ុណ្ណោះ ទើបអ្នកគ្រប់គ្រង អាចទាមទារឱ្យសាមីខ្លួន សងសោហ៊ុយចំណាយបាន។

ប្រសិនបើការចំណាយនោះ ផ្ទុយពីឆន្ទៈរបស់សាមីខ្លួនវិញ អ្នកគ្រប់គ្រងអាចទាមទារឱ្យសាមីខ្លួនសងត្រឹមតែជាផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង[48]។

២. សិទ្ធិទាមទារកម្រៃ

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះ រួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រងចំពោះកិច្ចការដែលនៅតែធ្វើបន្តក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន[49]។

ចំណុចខាងលើនេះ មានន័យថា បន្ទាប់ពីបានសម្រេចចិត្តក្នុងការជួសជុលជំនួសម្ចាស់ទ្រព្យហើយនោះ បុគ្គលដែលជាអ្នកបានធ្វើការជួសជុលនោះមិនត្រឹមតែបានទទួលត្រឡប់មកវិញនូវរាល់ការចំណាយរបស់ខ្លួនប៉ុណ្ណោះទេ តែគាត់ថែមទាំងទទួលបានផងដែរនូវការលើកទឹកចិត្ត ឬក៏សោហ៊ុយសម្រាប់បេសកកម្មនោះ។វាហាក់បីដូចជាមានភាពអយុត្តិធម៌ចំពោះសាមីខ្លួនដែលត្រូវអនុវត្តកាតព្វកិច្ចផ្តល់នូវកម្រៃប្រសិនបើគាត់ដឹងថាការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងបានដាក់បញ្ចូលទៅក្នុងវិជ្ជាជីវៈឬអាជីវកម្មរបស់អ្នកគ្រប់គ្រង។

[48] មើលមាត្រា ៧៣៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[49] មើលមាត្រា៧៣៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា

៣. សិទ្ធិមិនទទួលខុសត្រូវលើសំណងនៃការខូចខាត

ការគ្រប់គ្រងដោយឈឺឆ្អាលស្ថិតនៅក្នុងស្ថានភាពបន្ទាន់ទៅលើបុគ្គល ដូចជាទ្រព្យ ឬបុគ្គល ។បុគ្គលដែលជាអ្នកគ្រប់គ្រងពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាតកើតឡើងដោយសារការគ្រប់គ្រងឡើយ។ ប៉ុន្តែចំណុចនេះក៏ត្រូវបញ្ជាក់ថា វាមិនមែនជាកំហុសរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលទេ[50]។

ជាធម្មតាការចូលទៅគ្រប់គ្រងក្នុងស្ថានភាពណាមួយ គឺជាការសម្តែងតាមឆន្ទៈចង់ជួយគ្នាក្នុងនាមជាមនុស្សមានសមធម៌ សីលធម៌ និងស្គាល់ពីហេតុផលបានត្រឹមត្រូវចំពោះកាលៈទេសៈនីមួយៗ ដែលកើតឡើងដោយចៃដន្យ។

- ឧទាហរណ៍៖

ក្នុងករណីមួយមានភ្លើងឆេះផ្ទះ ហើយអ្នកគ្រប់គ្រងគាត់បានធ្វើការគ្រប់គ្រងដោយប្រុងប្រយ័ត្នរួចរាល់ចំពោះកិច្ចការនេះ។ ក្រោយពីស្ថានភាពនេះបានបញ្ចប់រួចរាល់ហើយ ក៏អ្នកគ្រប់គ្រងដោយឈឺឆ្អាលប្រគល់ការគ្រប់គ្រងនេះឱ្យទៅសាមីខ្លួនវិញ។

ក្រោយពីបានទទួលការគ្រប់គ្រងវិញសាមីខ្លួនបានប្រាប់អ្នកគ្រប់គ្រងថា មានការបាត់បង់ទ្រព្យសម្បត្តិមួយចំនួនដោយសារការគ្រប់គ្រងនេះ ប៉ុន្តែសាមីខ្លួនមិនអាចបញ្ជាក់ថា ជាកំហុសរបស់អ្នកគ្រប់គ្រងទេ។

**កថាភាគទី២. អានុភាពរបស់អ្នកត្រូវគេគ្រប់គ្រប់ដោយឈឺឆ្អាល**

១. សិទ្ធិទាមទារសំណងនៃការខូចខាតមកវិញ

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានធ្វើការគ្រប់គ្រងដោយឈឺឆ្អាលនោះ គឺដើម្បីតែម្ចាស់ទ្រព្យ ហើយបានធ្វើឱ្យខូចខាតដល់ម្ចាស់សិទ្ធិទ្រព្យនោះក្នុងគោលដៅឆ្លៀតឱកាសទុច្ចរិតចង់កេងប្រវ័ញ្ចផលប្រយោជន៍ដោយចេតនាដែលឃើញគេកំពុងជួបការលំបាកហើយរួចទៅថែមបន្ទុកដ៏ធ្ងន់ធ្ងរពេលមានអាសន្ន ឬចេតនាបំផ្លិតបំផ្លាញ ឬមិនប្រុងប្រយ័ត្ន ខ្ជីខ្ជា និងមិនយកចិត្តទុកដាក់ដែលធ្វើឱ្យមានការខូចខាតថែមទៀតបែបនេះ គឺច្បាប់តម្រូវអ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតមកដល់ខ្លួនបានវិញ [51]។

២. សិទ្ធិទាមទារឱ្យបញ្ឈប់សកម្មភាពបន្តការគ្រប់គ្រងដោយឈឺឆ្អាល

ជាគោលការណ៍អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានអនុញ្ញាតបញ្ឈប់ការគ្រប់គ្រងដោយការសម្រេចចិត្តរបស់ខ្លួនឯងតែម្ខាងនោះទេ។

ប៉ុន្តែប្រសិនបើច្បាស់លាស់ថា ការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់ខ្លួន ឬធ្វើឱ្យខូចផលប្រយោជន៍របស់ខ្លួននោះ ការបន្តការគ្រប់គ្រងមិនអនុញ្ញាតដោយយោងតាមស្មារតីនៃគោលគំនិតដើមនៃការគ្រប់គ្រងដោយឈឺឆ្អាលដូចមានចែងក្នុង កថាខណ្ឌទី២ និងទី៣ នៃមាត្រា៧២៩ នៃក្រមរដ្ឋប្បវេណី[52]។

ដូច្នេះអ្នកគ្រប់គ្រងត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ទោះបីជាសាមីខ្លួនជាអាទិ៍ មិនទាន់បានប្រុងប្រៀបដើម្បីការគ្រប់គ្រងក៏ដោយ។

50 មើលមាត្រា៧៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា

51 មើលមាត្រា៧៣៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

52 មើលមាត្រា៧២៩ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) នៃក្រមរដ្ឋប្បវេណីកម្ពុជា

៣. សិទ្ធិទាមទារឱ្យមានការរាយការណ៍ពីការគ្រប់គ្រង

ក្នុងករណីនេះ សាមីខ្លួនមានសិទ្ធិទាមទារឱ្យអ្នកគ្រប់គ្រងដោយឃើញាល រាយការណ៍អំពីស្ថានភាពនៃការគ្រប់គ្រងកិច្ចការទោះបីនៅពេលណាក៏ដោយ ក៏ត្រូវរាយការណ៍អំពីហេតុការណ៍ដោយគ្មានការយឺតយ៉ាវនៅក្រោយពេលបញ្ចប់ការគ្រប់គ្រង។

ក្នុងស្ថានភាពដែលខ្លួនមានការបារម្ភអំពីការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង[53] ក៏ដូចជា ខ្លួនមានការបារម្ភថាអ្នកគ្រប់គ្រងបានគ្រប់គ្រងដោយចេតនាទុច្ចរិត ឬមានធ្វេសប្រហែស ឬបណ្តាលឱ្យមានព្យសនកម្មណាមួយបានកើតឡើង ទើបខ្លួនអាចស្នើឱ្យគ្រប់គ្រងធ្វើការរាយការណ៍អំពីហេតុការណ៍នៃការគ្រប់គ្រងឱ្យមកខ្លួនតាមភាពជាក់ស្តែងគ្រប់កាលៈទេសៈតាំងពីចាប់ផ្តើមរហូតដល់ចប់សព្វគ្រប់។

## ផ្នែកទី២. អានុភាពក្នុងសេចក្តីចម្រើនដោយឥតហេតុ

ករណីយកិច្ចរបស់សេចក្តីចម្រើនដោយឥតហេតុសម្តៅដល់ ការលើកឡើងនូវកាតព្វកិច្ចក្នុងការសងផលប្រយោជន៍ ប៉ុន្តែទំហំនៃការសងគឺខុសគ្នាយោងទៅតាមស្ថានភាពជាអត្តនោម័តរបស់បុគ្គលម្នាក់ៗដែលទទួលផលប្រយោជន៍។

១. បទបញ្ញត្តិទូទៅ

ជាគោលការណ៍ទូទៅ ទំហំនៃការសង គឺត្រូវកម្រិតត្រឹមទំហំដែលផលប្រយោជន៍មាន ។ មូលហេតុដែលនាំឱ្យមានកម្រិតទំហំនៃការសងដោយសារថាជាញឹកញាប់ បុគ្គលដែលបានទទួលផលប្រយោជន៍តែងតែទាញប្រយោជន៍ពីផលប្រយោជន៍នោះ ។

ហេតុនេះ ឃើញថា មានភាពអយុត្តិធម៌ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍ទាំងអស់នៅពេលដែលបុគ្គលនោះប្រើប្រាស់ផលប្រយោជន៍នោះអស់ដោយមិនបានដឹងដោយគ្មានកំហុសអំពីភាពគ្មានមូលហេតុលើផ្លូវច្បាប់ [54]។

បញ្ហាបន្ទាប់មកទៀត គឺរបៀបកំណត់ថាតើផលប្រយោជន៍នោះមានឬអត់? ចំពោះបញ្ហាថាតើផលប្រយោជន៍មានឬគ្មាន គឺអាស្រ័យទៅលើការវិនិច្ឆ័យរបស់តុលាការ។

ប៉ុន្តែជាឧទាហរណ៍ទាក់ទងនឹងផលប្រយោជន៍ជាប្រាក់វិញ ទោះបីជាផលប្រយោជន៍ដើមដែលទទួលបានត្រូវបាត់បង់ ឬ ប្រើក៏ដោយ ការបាត់បង់នេះ ជួនកាលអាចបណ្តាលឱ្យមនុស្សទទួលផលប្រយោជន៍ថ្មី។

ហេតុនេះ ផលប្រយោជន៍ត្រូវបានចាត់ទុកថាបានផ្ទេរ ហើយនៅតែមានដដែលនៅក្នុងករណីបែបហ្នឹង។

- ឧទាហរណ៍៖

១- **ក** និង **ខ** បានបង្កើតកិច្ចសន្យាមួយដែល **ក** ត្រូវលក់គ្រឿងអលង្ការទៅឱ្យ **ខ** ។ **ក** បានប្រគល់ គ្រឿងអលង្ការ ហើយ **ខ** បានបង់ថ្លៃលក់ចំនួន ១០ ០០០$។ បន្ទាប់មក **ក** បានលុបកិច្ចសន្យានោះចោលដោយសារតែមានសមត្ថភាពរបស់គាត់ត្រូវបានកម្រិត (ជននៅក្រោមអាណាព្យាបាលទូទៅ) រហូតមកទល់នឹងពេល លុបកិច្ចសន្យា **ក** បានទិញភាគហ៊ុនចំនួន ១០ ០០០ $ តើផលប្រយោជន៍មានដែរឬអត់?

២- នៅក្នុងករណីទី ១៖

---

53 មើលមាត្រា៧៣១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

54 មើលមាត្រា៧៣៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

**ក** បានបង់ការជួលរបស់គាត់ចំនួន ១០០$ ពីការបង់រហូតដល់ពេលលុបចោលកិច្ចសន្យាដែលមានន័យថា គាត់អាចសង្គ្រោះនូវទ្រព្យសម្បត្តិដើមរបស់គាត់បាន តើផលប្រយោជន៍មានឬអត់?

៣- នៅក្នុងករណីទី ១៖

**ក** បានធ្វើពិធីជប់លៀងមួយដែលចំណាយប្រាក់យ៉ាងខ្ជះខ្ជាយ ( គាត់មិនធ្វើពិធីជប់លៀងទេ បើសិនជាគាត់មិនបានទទួលនូវការបង់ប្រាក់) ។ តើផលប្រយោជន៍មានដែរឬអត់?

**ដំណោះស្រាយ៖**

- ឧទាហរណ៍ ១៖

នៅក្នុងករណីនេះ បានបាត់បង់នូវផលប្រយោជន៍ដើមដែលជាប្រាក់ ប៉ុន្តែគេបានចាត់ទុកថាបានប្តូរទៅជាភាគហ៊ុន។

ហេតុដូច្នេះ បានគេអាចចាត់ទុកថាមាននៅសល់ ។

- ឧទាហរណ៍ទី២៖

**ក** បានធ្វើឱ្យបាត់បង់ផលប្រយោជន៍ដោយសារ **ក** បង់ថ្លៃជួលក៏ដោយអាចសង្គ្រោះទ្រព្យសម្បត្តិដើមរបស់គាត់បាន។ ហេតុនេះផលប្រយោជន៍ ត្រូវបានចាត់ទុកថា នៅតែមាន។

- ឧទាហរណ៍ទី៣៖

នៅក្នុងករណីនេះ ផលប្រយោជន៍ អាចត្រូវបានចាត់ទុកថា បានបាត់បង់ ដោយសារផលប្រយោជន៍ត្រូវបានចំណាយ ហើយបាត់បង់ទាំងអស់ ។

២. បញ្ញត្តិពិសេស

ក្នុងករណីបុគ្គលដែលបានទទួលផលប្រយោជន៍ បានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថា កិច្ចនោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅ ពេលបានដឹងពីការប្រាក់ គិតចាប់ពីពេលបានដឹងរហូតដល់ពេលសង[55] ។

ជាទូទៅ មានការកម្រិតនូវទំហំនៃករណីយកិច្ចសង គឺដើម្បីការពារបុគ្គលដែលបានទទួលផលប្រយោជន៍ដោយមិនបានដឹងចំពោះ បុគ្គលដែលបានទទួលផលប្រយោជន៍បានដឹងថា ផលប្រយោជន៍ដែលខ្លួនទទួលបានដោយគ្មានមូលហេតុលើផ្លូវច្បាប់នោះអាចនិយាយបានថា ជននោះដឹងថា ផលប្រយោជន៍នោះជារបស់អ្នកដទៃ គឺមិនមានភាពចាំបាច់ដើម្បីការពារនោះទេ ។

ដូច្នេះ ទំហំនៃករណីយកិច្ចសង គឺមិនត្រូវបានកម្រិតឡើយ ហើយជននោះត្រូវសងផលប្រយោជន៍ទាំងអស់ដោយភ្ជាប់មកជាមួយនឹងការប្រាក់ចាប់ពីពេលដែលបានដឹងថាខ្លួនគ្មានមូលហេតុលើផ្លូវច្បាប់ចំពោះផលប្រយោជន៍ដែលខ្លួនបានទទួល ។

បុគ្គលដែលបានទទួលផលប្រយោជន៍មានចេតនា ឬកំហុសចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់មកជាមួយនឹងការប្រាក់ [56]។

---

[55] មើលមាត្រា៧៣៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[56] មើលមាត្រា៧៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជា

- ឧទាហរណ៍ទី១៖

ជនដែលបានដឹងថា កិច្ចសន្យាបានមោឃៈរួចហើយជននោះត្រូវសងជាទំហំនៃផលប្រយោជន៍ទាំងអស់ដែល ទទួលតាមរយៈកិច្ចសន្យានេះ ។

- ឧទាហរណ៍ទី២៖

កិច្ចសន្យាមួយត្រូវបានរំលាយ ឬមោឃភាពដោយមូលហេតុកំហុសដោយចេតនា ឬអចេតនារបស់ភាគីណាមួយ ជននោះត្រូវសងផលប្រយោជន៍ខ្លួនទទួលបានទាំងអស់ ។

- ឧទាហរណ៍ទី៣៖

**ក** ឆបោក **ខ** ក្នុងការធ្វើកិច្ចសន្យាណាមួយ។ **ខ** សុំរំលាយកិច្ចសន្យាធ្វើឱ្យកិច្ចសន្យានោះបាត់ ត្រូវទទួលខុសត្រូវចំពោះមោឃភាពនៃកិច្ចសន្យានោះគឺ ត្រូវសងផលប្រយោជន៍បង់អានុភាព ហេតុនេះដែលខ្លួនទទួលបានទាំងអស់ ។

៣.ករណីពិសេស

៣.១. ការសងដោយគ្មានកាតព្វកិច្ច

ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានកាតព្វកិច្ចបានសងកាតព្វកិច្ចនោះ បុគ្គលនោះអាចត្រូវបានចាត់ទុកថាបានរងនូវការបាត់បង់ប្រយោជន៍។

ផ្ទុយទៅវិញ ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានសិទ្ធិលើបំណុលបានទទួលការសងចំពោះសិទ្ធិលើបំណុលនោះ បុគ្គលនោះអាចត្រូវចាត់ទុកថា បានទទួលផលប្រយោជន៍ ដោយគ្មានមូលហេតុគតិយុត្ត។

ជាគោលការណ៍ ករណីបែបនេះបង្កើតឱ្យមាននូវសេចក្ដីចម្រើនដោយឥតហាតុហើយបុគ្គលដែលបានទទួលរងនូវការបាត់បង់ផលប្រយោជន៍ អាចទាមទារឱ្យសងវិញនូវតាវកាលិកដែលត្រូវបានផ្ដល់ជាការសង។

ប៉ុន្តែ ប្រសិនបើបុគ្គលម្នាក់សងកាតព្វកិច្ចដោយដឹងអំពីនត្ថិភាពនៃកាតព្វកិច្ចនោះ សកម្មភាពរបស់បុគ្គលនោះ គឺជាសកម្មភាពមិនសមហេតុផល ក្នុងន័យសេដ្ឋកិច្ចទីផ្សារ ហើយមិនចាំបាច់ត្រូវបានការពារដោយច្បាប់ទេ។

✍ តាវកាលិក សម្គាល់ទៅលើ៖

- វត្ថុ ឬសកម្មភាព ដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។ ឧទាហរណ៍៖ តាវកាលិករបស់អ្នកទិញគឺ បង់ថ្លៃទៅឱ្យអ្នកលក់ ឯតាវកាលិករបស់អ្នកលក់ គឺប្រគល់វត្ថុទៅឱ្យអ្នកទិញ។
- វត្ថុជាទីតាំងនៃកាតព្វកិច្ចណាមួយ។ ឧទាហរណ៍៖ ស្រូវដែលជនម្នាក់ខ្ចីពីជនម្នាក់ទៀតហៅថា តាវកាលិកនៃការខ្ចី។

- ឧទាហរណ៍

**ក** បានសង **ខ** ចំនួន ១០០០$ ដោយ **ក** យល់ច្រឡំថា ខ្លួនជាកូនបំណុលរបស់ **ខ** ពិនិត្យទៅលើលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា ៧៣៦ ទង្វើរបស់ **ក** បង្កើតឱ្យមានសេចក្ដីចម្រើនដោយឥតហាតុថា:

- **ខ** បានទទួលផលប្រយោជន៍គឺប្រាក់ចំនួន ១០០០$
- **ក** បានបាត់បង់ប្រាក់ ១០០០$
- **ខ** បានទទួលប្រាក់ពី **ក** ដោយគ្មានមូលហេតុលើផ្លូវច្បាប់ពីព្រោះ **ក** មិនមែនកូនបំណុល
- **ខ** បានទទួលផលប្រយោជន៍ដោយសារការបាត់បង់របស់ **ក**

ហេតុនេះ **ក** ហាក់បីដូចជាអាចទាមទារឱ្យសងតាវកាលិកនៃការសងពី **ខ** មកវិញបាន។ តែមាត្រា ៧៣៨ កថាខណ្ឌទី ២ បានកំណត់ករណីលើកលែង។

ដូចឧទាហរណ៍ខាងលើ បើ **ក** បានដឹងថាខ្លួនមិនមែនជាកូនបំណុលហើយនៅតែប្រគល់ប្រាក់ ១០០០$ ទៅ **ខ** ទៀត។

ដូចនេះគឺ **ក** មិនអាចទាមទារ **ខ** ឱ្យសងត្រឡប់មកវិញបានឡើយ។

កត់សំគាល់ថា មាត្រា ៧៤០ ក៏អាចអនុវត្តបានផងដែរ ករណីបើមានដូចមាត្រា ៧៣៨ វាក្យខណ្ឌទី១[57] បើសិនជាបុគ្គលនោះ បានសងកាតព្វកិច្ចអ្នកដទៃដោយយល់ច្រឡំថាជាកាតព្វកិច្ចរបស់ខ្លួនអាចទាមទារឱ្យត្រឡប់មកវិញ តែវាត្រូវកម្រិតដោយមាត្រា ៧៤០ គឺថា ទោះបីជាបានសងដោយយល់ច្រឡំក្តីនោះ មានករណីលើកលែងដែលអ្នកសងមិនអាចទាមទារឱ្យប្រគល់មកវិញបានទេ។

### ៣.២. ការសងមុនពេលកំណត់

ទោះបីជាកូនបំណុលមិនចាំបាច់សងកាតព្វកិច្ចរហូតដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏កូនបំណុលអាចសងកាតព្វកិច្ចដោយបោះបង់ផលប្រយោជន៍នៃការកំណត់ពេលបានដែរ។

ហេតុដូច្នេះ ជាគោលការណ៍ បើទោះបីជាកូនបំណុលសងកាតព្វកិច្ចមុនពេលក៏ដោយ ក៏កូនបំណុលមិនត្រូវបានអនុញ្ញាតឱ្យទាមទារការសងតាវកាលិកឡើយ។

ប៉ុន្តែ ក្នុងករណីដែលកូនបំណុលសងកាតព្វកិច្ចដោយមិនបានដឹងថា ពេលកំណត់មិនទាន់មកដល់នៅឡើយ នោះកូនបំណុលបានបោះបង់ផលប្រយោជន៍នៃការកំណត់ពេលដោយមិនដឹងខ្លួន ហើយម្ចាស់បំណុលទទួលផលប្រយោជន៍ទៅតាមការបោះបង់ផលប្រយោជន៍នៃការកំណត់នោះ។

ហេតុដូច្នោះ ក្នុងករណីដែលកូនបំណុលបានសងកាតព្វកិច្ច ដោយមិនបានដឹងថា កាតព្វកិច្ចមិនទាន់ដល់ពេលកំណត់សងនៅឡើយ កូនបំណុលអាចទាមទារឱ្យសងផលប្រយោជន៍ដែលម្ចាស់បំណុលអាចប្រើប្រាស់តាវកាលិកដែលខ្លួនបានទទួលមុនពេលកំណត់សងរហូតដល់ពេលកំណត់សង(ផលប្រយោជន៍ក្នុងចន្លោះពេល) ពីម្ចាស់បំណុលបាន។

- ឧទាហរណ៍៖

**ក** ខ្ចីលុយពី **ខ** ចំនួន ១០០០$ កំណត់ថ្ងៃសង ០១,០៤,២០១១។ **ក** សងប្រាក់ **ខ** ចំនួន ១០០០$ នៅថ្ងៃទី ០១,០៣,២០១១។ ក្រមរដ្ឋប្បវេណី មាត្រា ៧៣៩ ជាគោលការណ៍ **ក** មិនអាចទាមទារឱ្យ **ខ** ប្រគល់ប្រាក់ដែលបានសងមក **ក** បានឡើយ។

តែករណីថា **ក** ជឿជាក់ដោយយល់ច្រឡំថាដល់ពេលកំណត់សង ក្រោយពេលសងទើបបានដឹង **ក** អាចទាមទារឱ្យ **ខ** សងផលប្រយោជន៍ដែលទទួលបានចន្លោះពេលមួយខែដែល **ខ** អាចប្រើប្រាស់ប្រាក់ ១០០០$ (ដូចជាការប្រាក់)។

### ៣.៣. ការសងតាវកាលិកនៃការសងកាតព្វកិច្ចអ្នកដទៃ

ឋានៈរបស់បុគ្គលដែលសងកាតព្វកិច្ចរបស់អ្នកដទៃ ដោយភាន់ច្រឡំថាជាកាតព្វកិច្ចមានភាពស្រដៀងគ្នា

[57] មើលមាត្រា ៧៣៨ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

នឹងឋានៈរបស់បុគ្គលដែលគ្មានកាតព្វកិច្ច តែសងកាតព្វកិច្ចដោយភាន់ច្រឡំថាខ្លួនមានកាតព្វកិច្ច[58]។

ហេតុដូច្នេះ បុគ្គលដែលបានសងកាតព្វកិច្ចអាចទាមទារឱ្យសងនូវតាវកាលិកដែលបានផ្តល់ជាការសង។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលដែលទទួលនូវការសងមិនបានដឹងថា ការផ្តល់តាវកាលិកនោះធ្វើឡើងដោយការភាន់ច្រឡំរបស់អ្នកសង ។

ជាញឹកញាប់ណាស់ ម្ចាស់បំណុលដែលជឿជាក់ថា ខ្លួនបានទទួលការសងដែលមានសុពលភាព ហើយបំផ្លាញចោលនូវលិខិតដែលបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើបំណុល ដូចជាប័ណ្ណបំណុលជាអាទិ៍ ឬបោះបង់ប្រាតិភោគចោល។

ក្នុងករណីនេះ ប្រសិនបើការទាមទារឱ្យសងវិញនូវកាតព្វកិច្ចរបស់អ្នកសងត្រូវបានអនុញ្ញាតនោះ ម្ចាស់បំណុលនឹងត្រូវទទួលលទ្ធផលដែលមិនសមហេតុផល។

លទ្ធផលដែលមិនសមហេតុផលនោះដូចជាមានការលំបាកក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ចជាដើម។ វាដោយសារមានការលំបាកក្នុងការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬសិទ្ធិលើបំណុលមិនអាចត្រូវបានរក្សាការពារដោយប្រាតិភោគបានជាអាទិ៍។

ហេតុដូច្នេះ បុគ្គលណាដែលសងកាតព្វកិច្ចបណ្តាលមកពីការភាន់ច្រឡំមិនអាចទាមទារឱ្យសងនូវតាវកាលិកនៃការសងនោះ។

ក្នុងករណីដែលបំពេញលក្ខខណ្ឌ[59] ដូចតទៅ (**ក**) ម្ចាស់បំណុលមិនបានដឹង ការសងត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ និង(**ខ**) ករណីដែលម្ចាស់បំណុលបំផ្លាញលិខិតលាយលក្ខណអក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬបោះបង់ប្រាតិភោគចោល។

ម្យ៉ាងទៀត ក៏គួរអនុញ្ញាតឱ្យយកមកអនុវត្តផងដែរចំពោះករណីដែលម្ចាស់បំណុលដែលបានជឿជាក់ថាការសងដោយការភាន់ច្រឡំ គឺជាការសងដែលមានសុពលភាពទុកឱ្យសិទ្ធិលើបំណុលរលត់ដោយអាជ្ញាយុកាល។

ក្នុងករណីដែលបុគ្គលដែលបានសងដោយភាន់ច្រឡំមិនអាចទាមទារឱ្យសងនូវតាវកាលិកនៃការសងនោះពីម្ចាស់បំណុលអាចក្តាប់ទុកនូវតាវកាលិកនោះបានហើយករណីនេះត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលមានការសងដោយមានសុពលភាព។

វាមានន័យថា ករណីនេះត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលមានការសងដោយមានសុពលភាព ឬមានន័យថា ករណីនេះត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលបុគ្គលបានសងកាតព្វកិច្ចរបស់អ្នកដទៃក្នុងនាមជាតតិយជន [60]។

ហេតុដូច្នេះ វាជាការពិតណាស់ហើយដែលអ្នកសងអាចអនុវត្តសិទ្ធិទាមទារសំណងចំពោះកូនបំណុលដែលបានរួចផុតពីកាតព្វកិច្ចនោះ។

- ឧទាហរណ៍៖

**ក** បានសងប្រាក់១០០$ ទៅ **គ** ។ ដោយ **ក** ច្រឡំថាប្រាក់ដែល **ខ** ជំពាក់គ ១០០$ ថាខ្លួនជាអ្នកជំពាក់។

[58] មើលវាក្យខណ្ឌទី១ នៃមាត្រា ៧៣៨ ក្រមរដ្ឋប្បវេណី

[59] វាក្យខណ្ឌទី២ នៃកថាខណ្ឌទី១ មាត្រា៧៤០ នៃក្រមរដ្ឋប្បវេណី

[60] កថាខណ្ឌទី១ មាត្រា ៤៣៤ នៃក្រមរដ្ឋប្បវេណី

ជាគោលការណ៍ទូទៅ **ក** អាចទាមទារ **គ** ប្រគល់ប្រាក់មកឱ្យខ្លួនវិញបានដោយសារការពិនិត្យទៅលើលក្ខខណ្ឌនៃការបង្កើតសេចក្តីចម្រើនដោយឥតហេតុ៖

- **គ** បានទទួលប្រយោជន៍ ១០០$
- **ក** បាត់បង់ប្រយោជន៍ ១០០$
- មានមូលហេតុលើផ្លូវច្បាប់ដោយ **ក** មិនមានកាតព្វកិច្ចចំពោះ **គ** គឺគ្មានមូលហេតុលើផ្លូវច្បាប់ដែល **គ** ទុកប្រាក់ ១០០ $នេះ
- **គ** ទទួលប្រយោជន៍ដោយសារការបាត់បង់របស់ **ក**

តែករណីថា **គ** បំផ្លាញភស្តុតាងជាឯកសារ ឬបោះបង់ចោលប្រាតិភោគដោយជឿជាក់ថា ការសងរបស់ **ក** ជាការសងដោយមានសុពលភាព **ក** មិនអាចទាមទារឱ្យ **គ** ប្រគល់ប្រាក់មកឱ្យខ្លួនវិញបានឡើយ។

យោងមាត្រា ៧៤០ កថាខណ្ឌទី២ ចំពោះករណីនេះទោះជា **ក** មិនអាចទាមទារឱ្យ **គ** ប្រគល់ប្រាក់មកវិញបានក៏ពិតមែន **ក** អាចអនុវត្តសិទ្ធិទាមទារបំណុលពី **ខ** វិញបាន។

### ៣.៤.ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

ក្នុងករណីដែលការទាមទារឱ្យប្រគល់ផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ល្អ ឬច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងរបៀបនេះមិនត្រូវបានអនុញ្ញាតឱ្យទេ[61]។

ភាពចាំបាច់ក្នុងការបដិសេធ នូវការទាមទារឱ្យសងតាវកាលិកវិញដែលបានផ្តល់ក្នុងគោលបំណងធ្វើសកម្មភាពប្រឆាំងនឹងសង្គមដើម្បីទប់ស្កាត់នូវសកម្មភាពផ្សេងៗដែលប្រឆាំងនឹងសង្គមដោយការធ្វើសកម្មភាពនោះទុកជាមោឃៈ ដើម្បីឱ្យអ្នកដែលបានធ្វើសកម្មភាពផ្តល់តាវកាលិកក៏មិនមានលទ្ធភាពប្រមូលនូវសោហ៊ុយចំណាយនោះបាន។

នេះគឺជាការឆ្លុះបញ្ចាំងនូវទស្សនៈនៃគោលការណ៍ស្អាតស្អំ គឺភាពសុចរិត និងស្មោះត្រង់ដែលទប់ស្កាត់តុលាការមិនឱ្យផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកទាមទារទុច្ចរិត។

ប៉ុន្តែករណីខ្លះ បើជាតាវកាលិកណាមួយដែលត្រូវបានផ្តល់មានគោលបំណងប្រឆាំងនឹងសង្គមក៏ដោយតែជាក់ស្តែងអ្នកទទួលតាវកាលិកនោះ ប្រឆាំងនឹងសង្គមច្រើនជាងអ្នកទាមទារឱ្យសងតាវកាលិកនោះទៅទៀត។

ហេតុនេះ ការបដិសេធនូវការទាមទារឱ្យសងតាវកាលិកនឹងជំរុញឱ្យមានសកម្មភាពប្រឆាំងនឹងសង្គមទៅវិញទេ។

ហេតុដូចនេះបាននិយាយថាការទទួលស្គាល់ឬមិនទទួលស្គាល់នូវការទាមទារឱ្យសងមិនមែនអាស្រ័យថាតើមូលហេតុនៃសេចក្តីចម្រើនដោយឥតហេតុប្រឆាំងនឹងសង្គមដែរឬអត់នោះទេ គឺអាស្រ័យទៅលើបញ្ហាថា តើការទាមទារឱ្យសងនោះប្រឆាំងនឹងសង្គមដែរឬទេ ហើយនេះ មិនមែនជាបញ្ហាធម្មតានោះទេ។

- ឧទាហរណ៍៖

១- **ក** និង **ខ** បានបង្កើតកិច្ចសន្យាដែលមានខ្លឹមសារថា **ក** ត្រូវសម្លាប់ **គ** ដើម្បីបានប្រាក់ធានារ៉ាប់រងហើយ **ខ** ឱ្យរង្វាន់ ១០០០$ ទៅឱ្យ **ក** ហើយ ខ បានឱ្យ ១០០០ $ជាមុនរួចហើយ។ មុនពេល **ក** សម្លាប់ **គ** នោះ **ខ** បាន

[61] មើលមាត្រា ៧៤១ ក្រមរដ្ឋប្បវេណី

ដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់ប្រាក់ ១០០០$ វិញដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ពីព្រោះកិច្ចសន្យាសម្លាប់មនុស្សបែបនេះ គឺជាកិច្ចសន្យាដែលគ្មានសុពលភាព [62]។

២-នៅក្នុងករណីទី១ តើវាយ៉ាងម៉េចទៅវិញ ប្រសិនបើកិច្ចសន្យាបែបនេះ ត្រូវធ្វើឡើងដោយការគំរាមកំហែងរបស់ **ក** ហើយ **ខ** ត្រូវបានគេបង្ខំឱ្យបង់ប្រាក់?

- ចំពោះករណីទី១៖

កិច្ចសន្យារវាង **ក** និង **ខ** ត្រូវបានមោឃភាពដោយសារខុសច្បាប់។ ចំពោះការទាមទាររបស់ **ខ** បញ្ហានៅត្រង់ថា តើការទាមទាររបស់ **ខ** នេះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទំលាប់ល្អដែរឬអត់?

- ទី១ តាមទស្សនៈនៃគោលការណ៍ស្អាតស្អំ **ខ** ដែលបានទាមទារ គឺជាជនទុច្ចរិត។ ហេតុនេះ **ខ** មិនអាចទាមទារឱ្យ **ក** ប្រគល់ប្រាក់ ១០០០$ នោះវិញបានទេ។
- ទី២ តាមទស្សនៈនៃការទទួលស្គាល់ការទាមទារ គឺថា **ក** ដែលជាអ្នកបានទទួលតាវកាលិកក៏ជាជនទុច្ចរិតផងដែរហេតុនេះ បើ **ខ** មិនអាចទាមទារឱ្យ **ក** ប្រគល់ប្រាក់មកវិញបានទេនោះអាចជំរុញឱ្យ **ក** ធ្វើសកម្មភាពប្រឆាំងនឹងសង្គមបន្ថែមទៀត។

ពោលគឺ ក្នុងករណីដែល **ក** មិនចាំបាច់សងប្រាក់ត្រឡប់វិញ **ក** អាចទទួលបានប្រាក់ ដោយមិនបានធ្វើអ្វីមួយដោយប្រាក់គេថា គាត់អាចសម្លាប់មនុស្សដែលគាត់ចង់សម្លាប់ដោយបង់លុយឱ្យគាត់ ១០០០$ តែគាត់មិនបានធ្វើអ្វីសោះ។

ហេតុនេះប្រសិនបើ **ខ** មិនអាចទាមទារឱ្យ **ក** ប្រគល់ប្រាក់មកវិញទេ។ នោះជំរុញឱ្យ **ក** ធ្វើរបៀបណានេះបន្តទៀតដោយ **ក** អាចទទួលប្រាក់បានដោយមិនចាំបាច់ទទួលខុសត្រូវអ្វីទាំងអស់។ ហើយករណីនេះ គឺជាការជំរុញឱ្យមានសកម្មភាពប្រឆាំងនឹងសង្គមផងដែរ។

ដូចដែលបានឃើញ នេះមិនមែនជាបញ្ហាធម្មតានោះទេ ហើយខ្ញុំសូមបង្ហាញនូវដំណោះស្រាយមួយដែលអាចធ្វើបាន។

នៅក្នុងករណីនេះ ទោះបីជាការទាមទារត្រូវបានអនុញ្ញាតឱ្យធ្វើ ឬមិនធ្វើឱ្យក៏ដោយ នៅតែមានបញ្ហាដដែល ប៉ុន្តែបញ្ហាក្រោយនេះ (**ក** អាចទទួលបានប្រាក់ដោយមិនបានធ្វើអ្វីសោះ) អាចត្រូវបានដោះស្រាយតាមរយៈនីតិវិធីព្រហ្មទណ្ឌ( **ក** អាចត្រូវបានគេដាក់ទោសដោយបទឧក្រិដ្ឋ) ។

ហេតុដូច្នេះ ពាក់ព័ន្ធនឹងបញ្ហារដ្ឋប្បវេណី គោលការណ៍នៃភាពស្អាតស្អំសំខាន់ជាងនៅទីនេះ។

- ចំពោះករណីទី២៖

ទោះបីជាកិច្ចសន្យានេះ កើតឡើងដោយសារការគំរាមកំហែងរបស់ **ក** ក៏ដោយ គឺថាកិច្ចសន្យាមិនមានសុពលភាពទេ ព្រោះកម្មវត្ថុនៃកិច្ចសន្យាគឺឱ្យ **ក** សម្លាប់ **គ** ។

សំណួរថា **ខ** អាចទាមទារឱ្យ **ក** ប្រគល់ប្រាក់មកវិញបានឬទេ?

ស្ថានភាព គឺដូចគ្នាទៅនឹងករណីទី១ ប៉ុន្តែ នៅក្នុងករណីនេះ **ខ** ត្រូវបានគេតិទៀនតិចជាងករណីទី១។

ហេតុដូច្នេះ ការទាមទារខាងលើនេះទំនងជាត្រូវបានគេអនុញ្ញាតឱ្យធ្វើតាមទសន្សៈនៃគោលការណ៍នៃភាពស្អាតស្អំ។

---

[62] មើលកថាខណ្ឌទី១ មាត្រា១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

# សេចក្តីសន្និដ្ឋាន

ប្រធានបទនៃការស្រាវជ្រាវ បានឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចដែលបានកំណត់ដោយច្បាប់ឬកាតព្វកិច្ចឧបសន្យា បានឆ្លុះបញ្ចាំងពីការទំនាក់ទំនងនៃការចេះជួយយកអាសារ ទុក្ខធុរៈគ្នារបស់ពលរដ្ឋក្នុងសង្គមតាមរយៈការចូលទៅគ្រប់គ្រងដោយឈឺឆ្អាលរបស់បុគ្គលម្នាក់ទៅកាន់បុគ្គលម្នាក់ទៀតដែលទទួលបានប្រយោជន៍ពីការគ្រប់គ្រងដោយឈឺឆ្អាលនោះ ថែមទាំងបានបង្ហាញឱ្យឃើញពីទំនាក់ទំនងនាពេលដែលបុគ្គលម្នាក់បានផលប្រយោជន៍ដោយសារការបាត់បង់របស់បុគ្គលណាម្នាក់ទៀតដោយគ្មានមូលហេតុលើផ្លូវច្បាប់ ឬនាពេលកិច្ចសន្យានោះពុំមានអានុភាព ឬត្រូវបានបាត់បង់អានុភាព ។

ការចែងបញ្ញត្តិដូចនេះ មិនមែនជាសញ្ញាណមួយថ្មីនាបច្ចុប្បន្ននោះទេ សញ្ញាណមានតាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ ជាក់ស្តែងមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ដែលបញ្ញត្តិនោះចែងតែពីការគ្រប់គ្រងចំពោះតែទ្រព្យសម្បត្តិតែប៉ុណ្ណោះចំពោះការគ្រប់គ្រងដោយឈឺឆ្អាល។ រីឯសេចក្តីចម្រើនដោយឥតហេតុវិញ បានចែងតែក្នុងករណីភាន់ច្រឡំរបស់ជនដែលមិនជំពាក់និងចេតនារបស់ជនដែលបានសំណងដោយការភាន់ច្រឡំ។ តែបន្តរហូតមកដល់ពេលនេះ សញ្ញាណនៃការគ្រប់គ្រងដោយឈឺឆ្អាលបានគ្រប់ដណ្តប់ទៅលើទាំងទ្រព្យសម្បត្តិ និង ចំពោះបុគ្គល បើទោះបីជាមិនបានចែងច្បាស់ពីបុគ្គលក៏ដោយ តែពាក្យថាដើម្បីកិច្ចការ និងប្រយោជន៍អ្នកដទៃ (សាមីខ្លួន) គឺរាប់បញ្ចូលទាំងអស់អ្វីជាប្រយោជន៍ និងដើម្បីកិច្ចការអ្នកដទៃ រីឯ សញ្ញាណនៃសេចក្តីចម្រើនដោយឥតហេតុ បានគ្រប់ដណ្តប់ទៅលើបុគ្គលអ្នកទទួលបានតាវកាលិក និងថែមទាំងតតិយជនក្រៅពីកូនបំណុល ការសងមុនកាលកំណត់។

កាតព្វកិច្ចឧបសន្យាដែលបានកំណត់ដោយច្បាប់បានបដិសេធចោលចំពោះអំពើណាដែលមានបុគ្គលម្នាក់ខាតបង់ប្រយោជន៍ និងបុគ្គលម្នាក់ទៀតទទួលផលប្រយោជន៍ដោយគ្មានមូលហេតុតាមផ្លូវច្បាប់ក៏ដោយ បូករួមជានឹងលក្ខខណ្ឌនៃឧបសន្យាទាំងនោះ វាជាការបំពានទៅលើកម្មសិទ្ធិរបស់បុគ្គលដទៃដូចជា ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល។ ច្បាប់បានបដិសេធចោលចំពោះអំពើនៃការចូលទៅកាន់កាប់គ្រប់គ្រងទ្រព្យអ្នកដទៃដោយបំណង សុចរិត ឈឺឆ្អាល និងការពារប្រយោជន៍អ្នកដទៃ បូករួមនឹងលក្ខខណ្ឌនៃអំពើនៃការគ្រប់គ្រងដោយឈឺឆ្អាលបានបំពេញនោះ ថាជាការបំពានរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលទៅលើកម្មសិទ្ធិរបស់សាមីខ្លួន។

ដូចនេះ នៅពេលបុគ្គលដទៃចូលទៅគ្រប់គ្រងកិច្ចការ ដើម្បីប្រយោជន៍អ្នកដទៃនេះ អ្នកគ្រប់គ្រងមានសិទ្ធិទទួលបាននូវសោហ៊ុយនិងកម្រៃពីសាមីខ្លួន។ តែក៏មានការពារចំពោះម្ចាស់ទ្រព្យ ឬសាមីខ្លួន កាលណាការគ្រប់គ្រងធ្វើហួសពីព្រំដែនករណីយកិច្ចគ្រប់គ្រង និង ឬ ដោយអំពើទុច្ចរិត។ ចំពោះសេចក្តីចម្រើនដោយឥតហេតុវិញ ច្បាប់ការពារដល់បុគ្គលដែលបានបាត់បង់ប្រយោជន៍ ទោះបីគ្មានមូលហេតុផ្លូវច្បាប់ ឬក្នុងករណីយកិច្ចសន្យាភាគីនោះបានបាត់បង់អានុភាពក្តីដែលច្បាប់បានបង្ខំឱ្យអ្នកដែលទទួលបានផលប្រយោជន៍នោះសងតាវកាលិកមក អាចបូករួមជាមួយនឹងការប្រាក់ក្នុងករណីផ្សេងៗដែលមានបញ្ញត្តិ ដែលគេហៅថា អានុភាព។

គួរបញ្ជាក់ផងដែរថា សញ្ញាណការគ្រប់គ្រងដោយឈឺឆ្អាលមានការប្រែប្រួល កាលណាលក្ខខណ្ឌនៃការជូនដំណឹងទៅដល់សាមីខ្លួន ។ វាមានន័យថា បញ្ញត្តិស្តីពីអាណត្តិ និងការគ្រប់គ្រងដោយឈឺឆ្អាលបានស្ថិតនៅលាយចំរុះគ្នាចំពោះសកម្មភាពរបស់អ្នកគ្រប់គ្រង។ ក៏ដូចគ្នាទៅ សេចក្តីចម្រើនដោយឥតហេតុផងដែរ វាមានភាពប្រែប្រួលទៅតាមចេតនារបស់អ្នកទទួលបានផលប្រយោជន៍នោះ។

# អនុសាសន៍

ក្រោយពីបានសរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សានេះរួចមកសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនមិនទាន់មានការយល់ដឹងអំពីអត្ថន័យនៃកាតព្វកិច្ចឧបសន្យានៅឡើយ។ ដោយពួកគាត់ភ័យខ្លាចប៉ះពាល់ ឬ បំពានទៅលើសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលដទៃ។ ប៉ុន្តែពួកគាត់មិនបានដឹងពីខ្លឹមសារនៃច្បាប់ដែលតម្រូវឱ្យមនុស្សចេះជួយគ្នាប្រកបដោយសាមគ្គីភាព សុចរិតភាព ស្មោះត្រង់ និងឆ្លើយតបទៅនឹងអំពើប្រកបដោយមនុស្សធម៌ សីលធម៌ និងសមធម៌ ដោយមិនមានភាពកេងប្រវ័ញ្ច ឬការទទួលបានផលប្រយោជន៍ដោយធ្វើឱ្យភាគីម្ខាងទៀតបាត់បង់ប្រយោជន៍។

ជាញឹកញាប់ បញ្ហាភាគច្រើនកើតឡើងហើយបុគ្គលម្នាក់យករួចខ្លួន ដោយគិតថានៅពេលដែលជួយហើយតែងតែមានទំនាស់នឹងគ្នាដោយមិនទទួលប្រយោជន៍អ្វីពីក្រោយពីការជួយសង្គ្រោះរួចមក។ ជាពិសេស វាពិបាកទាមទារសំណងដែលខ្លួនបានចំណាយលើការគ្រប់គ្រងដោយឈឺឆ្អាល។

មួយវិញទៀត នៅពេលដែលមានវិវាទកើតឡើង រវាងអ្នកគ្រប់គ្រង និងសាមីខ្លួន ហើយមិនដឹងថា តើត្រូវប្ដឹងទៅសមត្ថកិច្ចមួយណាទេ។

រីឯ ការដែលភាន់ច្រឡំដែលបង្កឱ្យមានការបាត់បង់ប្រយោជន៍វិញ យើងក៏អាចទាមទារមកវិញដោយសំអាងលើភាន់ច្រឡំ ហើយចំណែកអ្នកដែលទទួលបានផលប្រយោជន៍ដោយសារការបាត់បង់ប្រយោជន៍របស់អ្នកដទៃនោះ ក៏អាចរួចផុតឬមិនរួចផុតពីការចោទប្រកាន់ ដោយសំអាងលើចេតនាទុច្ចរិត ឬសុចរិត។

ដោយសារកង្វះខាតមួយចំនួននេះហើយ ទើបខ្ញុំសូមចូលរួមនូវការផ្ដល់ជាយោបល់មួយចំនួនក្នុងគោលដៅដើម្បីធ្វើការកែតម្រូវចំណុចទាំងនោះឱ្យកាន់តែប្រសើរដូចជា រាជរដ្ឋាភិបាលត្រូវតែផ្ដល់ការផ្សាយជាសាធារណៈច្បាប់ ដើម្បីឱ្យប្រជាពលរដ្ឋបានជ្រួលជ្រាបកាន់តែច្បាស់អំពីខ្លឹមសារនៃកាតព្វកិច្ចឧបសន្យាឱ្យបានទូលំទូលាយ និងផ្ដល់ភាពងាយស្រួលដល់ពួកគាត់ជាសំអាង ហើយក៏ជាចំណេះដឹងបន្ថែមសម្រាប់ពួកគាត់យកទៅប្រើប្រាស់នៅពេលណាដែលពួកគាត់ជួបប្រទះនូវបញ្ហាទាំងនោះ។

ការចូលរួមចំណែកឈឺឆ្អាលក្នុងសង្គមជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យប្រជាពលរដ្ឋចេះជួយគ្នា យកអាសាគ្នា ក្នុងគោលបំណងការពារនូវទ្រព្យសម្បត្តិ ឬបុគ្គល កំពុងជួបទុក្ខលំបាកដែលត្រូវ ការជំនួយចាំបាច់ដើម្បីជួយឱ្យរួចផុតពីឧបទ្រវហេតុណាមួយ។ ចំណែកឯ ការចូលរួមទប់ស្កាត់ការទទួលបានផលប្រយោជន៍ដោយសារការបាត់បង់ផលប្រយោជន៍របស់អ្នកដទៃ ក៏បានឆ្លុះពីភាពមិនអាត្មានិយម ចេះយោគយល់ និងអធ្យាស្រ័យ មិនចង់បានរបស់អ្នកដទៃដោយគ្មានហេតុផលណាមួយក្តី។

កាតព្វកិច្ចឧបសន្យាបានបញ្ជាក់ពីសាមគ្គីភាពសង្គមដែលមានប្រជាពលរដ្ឋប្រព្រឹត្តតែអំពើល្អ ចេះជួយទុក្ខធុរៈ ជនរួមសង្គម និងមានសុវត្ថិភាពក្នុងការរួមរស់នៅជាមួយគ្នា ជាពិសេសបទបញ្ញត្តិស្តីពីការ គ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុបានលើកទឹកចិត្តដល់បុគ្គលគ្រប់រូបដែលបានជួយគ្នាក្នុងគ្រាលំបាកបែបនេះ។

# **បញ្ជីឯកសារយោង**


## I. **លិខិតបទដ្ឋានគតិយុត្ត**

១-ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី។

២-ក្រមរដ្ឋប្បវេណីសង្គមចាស់ឆ្នាំ១៩២០

៣-ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## II. **បញ្ជីឯកសារផ្សេងៗ**

១-វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត,បោះពុម្ពផ្សាយឆ្នាំ ១៩៦៧, ទំព័រ២៨៨

២-សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៣ គន្ថីទី៥ , ទំព័រ១៦៣ -១៧១ រៀបចំដោយគណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីឆ្នាំ២០២០។

៣-សៀវភៅណែនាំសិក្សាច្បាប់រដ្ឋប្បវេណី(ករណីប្រទេសជប៉ុន) និពន្ធដោយ អ៊ីកិដា ម៉ាសាអូ, ប្រែសម្រួលដោយ គង់ ទេលី , សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា សាកលវិទ្យាល័យជាតិគ្រប់គ្រង, ទំព័រ ១៤៩-១៥៤

៤-សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី០៥ ,ភ្នំពេញ,២០១២,ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ, ទំព័រ ១០៧-១២២

៥-មេរៀនរបស់គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ កេង សុម៉ារិទ្ធិ

៦-មេរៀនរបស់គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គង់ តារាឆាត

## III. **គេហទំព័រ**

១-គេហទំព័រសារព័ត៌មាន FRESH NEWS, *យល់ដឹងផ្នែកច្បាប់៖ សេចក្តីចម្រើនដោយឥតហេតុ* , ( ឆ្នាំ ២០២០-០៥-), អាចរកបាននៅ https://freshnewsasia.com/index.php/en/localnews/160968-2020-05-31-04-55-45.html

២-ហទំព័រសារ PHKASLA PARTNER, *ពន្យល់ពាក្យខ្មែរ«អហេតុកផល( សេចក្តីចម្រើនដោយឥតហេតុ», (ឆ្នាំ ២០២៤-០៤-០៨),* អាចរកបាននៅ https://search.app/vLfDEga6M5vEpYJ69

៣-គេហទំព័រសារព័ត៌មាន FRESH NEWS, *យល់ដឹងផ្នែកច្បាប់៖ សេចក្តីចម្រើនដោយឥតហេតុ* , ( ឆ្នាំ ២០២០-០៥-៣១),អាចរកបាននៅhttps://freshnewsasia.com/index.php/en/localnews/160968-2020-05-31-04-55-45.html

# គន្ថីទី ១

## បទប្បញ្ញត្តិទូទៅ

## ជំពូកគោល

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

**មាត្រា ២.-** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.-** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

**មាត្រា ៤.-** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

**មាត្រា ៥.-** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

## ជំពូកទី ១៤

## ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.–** ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលផងទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

**មាត្រា ៧៣០.–** ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

**មាត្រា ៧៣១.–** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

**មាត្រា ៧៣២.–** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

**មាត្រា ៧៣៣.–** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

**មាត្រា ៧៣៤.–** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

**មាត្រា ៧៣៥.–** សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវ-



កម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

## ជំពូកទី ១៥
## សេចក្តីចម្រើនដោយឥតហេតុ

**មាត្រា ៧៣៦.–** លក្ខខ័ណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ

១-ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន ។

២-នៅក្នុងករណីដែលបានទទួលការផ្តល់ពាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់ពាវកាលិកនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលខ្លួនទទួលបានដោយសារការផ្តល់ពាវកាលិកនោះ ឱ្យទៅអ្នកដទៃដែលបានផ្តល់ពាវកាលិកនោះវិញ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

**មាត្រា ៧៣៧.–** ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយគំនិតទុច្ចរិត

១-បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានកំណត់នៅក្នុងមាត្រា ៧៣៦ (លក្ខខ័ណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ) ខាងលើនេះ ក្នុងករណីដែលបានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលដែលបានដឹង រហូតដល់ពេលសង ។

២-បើបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ

មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-បើបុគ្គលដែលត្រូវបានបាត់បង់ផលប្រយោជន៍ ទទួលការខូចខាត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតនោះ ។

**មាត្រា ៧៣៨.-** ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន អាចទាមទារឱ្យសងពាវកាលិកនៃការសងនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលដឹងថា គ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងពាវកាលិកនៃការសងនោះ មកវិញបានឡើយ ។

**មាត្រា ៧៣៩.-** ការសងនៅមុនកំណត់ពេល

ក្នុងករណីដែលបានផ្តល់ពាវកាលិកនៃការសង ចំពោះកាតព្វកិច្ចដែលមិនទាន់ដល់កំណត់ពេលសងនៅឡើយ កូនបំណុលពុំអាចទាមទារឱ្យសងពាវកាលិកដែលត្រូវបានផ្តល់នោះ មកវិញបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលបានសង ដោយពុំបានដឹងអំពីកំណត់ពេលសងដែលមិនទាន់មកដល់នៅឡើយ ម្ចាស់បំណុលមានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលបានទទួលដោយសារការសងនៅមុនកំណត់ពេលនោះ ។

**មាត្រា ៧៤០.-** ការសងកាតព្វកិច្ចរបស់អ្នកដទៃ

១-ក្នុងករណីដែលបុគ្គលក្រៅពីកូនបំណុល បានផ្តល់ពាវកាលិកនៃការសង ដោយភាន់ច្រឡំអំពីកាតព្វកិច្ចរបស់អ្នកដទៃថាជាកាតព្វកិច្ចរបស់ខ្លួន អាចទាមទារឱ្យសងពាវកាលិកនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលពុំបានដឹងថា ការផ្តល់ពាវកាលិកនោះ បណ្តាលមកពីការភាន់ច្រឡំរបស់បុគ្គលដែលបានផ្តល់ពាវកាលិកនៃការសងនោះទេ ហើយបានបំផ្លាញលិខិតលាយលក្ខណ៍អក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធលើបំណុល ឬបានបោះបង់ប្រាតិភោគចោល ដោយបានជឿជាក់ថាជាការសងដែលមានសុពលភាព

បុគ្គលដែលបានផ្តល់ពាវកាលិកនោះ មិនអាចទាមទារឱ្យសងពាវកាលិកនោះ មកវិញបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណងរបស់បុគ្គលដែលបានផ្តល់ពាវកាលិកនៃការសង ចំពោះកូនបំណុលឡើយ ។

**មាត្រា ៧៤១.-** ការផ្តល់ពាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥ (សេចក្តីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

## ជំពូកទី ១៤ ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.-**ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្ដើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

(កំណត់)

(1) ក្នុងជីវភាពប្រចាំថ្ងៃ មនុស្សយើងជានិច្ចកាលយកចិត្តទុកដាក់ចំពោះកិច្ចការរបស់អ្នកដទៃ ទោះបីជាគ្មានសិទ្ធិអំណាច ឬ ករណីយកិច្ចតាមផ្លូវច្បាប់ដើម្បីធ្វើបែបនោះក៏ដោយ ។ ដូចដែលយើងដឹងស្រាប់ហើយថា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង សាមគ្គីភាពសង្គម និង កិច្ចសហប្រតិបត្តិការទៅវិញទៅមក មានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សយើង ។ ប៉ុន្តែ វាច្បាស់ណាស់ទៅហើយដែលថា ការជួយគ្នាទៅវិញទៅមកនេះ គឺជា "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" ។ ប្រសិនបើយើងអនុវត្តគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនឱ្យដាច់ណាត់ទៅ ការជួយគ្នាទៅវិញទៅមកបែបនេះ ត្រូវបានវាយតម្លៃថា ខុសច្បាប់ ។ ដោយសារតែហេតុផលនេះហើយ ជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ជំពូកនេះដាក់បញ្ចូលនូវបញ្ញត្តិដែលធ្វើឱ្យ "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" មិនខុសច្បាប់ ប្រសិនបើការជ្រៀតជ្រែកនោះបានបំពេញនូវល័ក្ខខ័ណ្ឌមួយចំនួន និង បញ្ញត្តិដទៃផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរវាងអ្នកគ្រប់គ្រងដោយឈឺឆ្អាល និង សាមីខ្លួន ។ ដោយសារទំនាក់ទំនងនេះកើតឡើងដោយច្បាប់ តែមិនមែនដោយឆន្ទៈរបស់ភាគី ទំនាក់ទំនងនេះត្រូវបានហៅថាជា "ទំនាក់ទំនងនៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់" ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះកំណត់និយមន័យថា "ការជ្រៀតជ្រែកចូលក្នុងកិច្ចការអ្នកដទៃ" តាមរយៈការជួយគ្នាទៅវិញទៅមក គឺជា "ការគ្រប់គ្រងដោយឈឺឆ្អាល" ហើយឱ្យនិយមន័យថា បុគ្គលដែលប្រតិបត្តិការគ្រប់គ្រង គឺជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

ដើម្បីឱ្យសកម្មភាពមួយអាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល អ្នកគ្រប់គ្រងចាំបាច់ត្រូវមានឆន្ទៈ

គ្រប់គ្រងកិច្ចការ "ដើម្បីបុគ្គលដទៃ" ។ ឆន្ទៈនេះគឺហៅថា "ឆន្ទៈគ្រប់គ្រង" ។ ប្រសិនបើអ្នកគ្រប់គ្រងគ្មានឆន្ទៈគ្រប់គ្រងទេ សកម្មភាពគ្រប់គ្រងនោះមិនត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលទេ ហើយអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងនោះ ជាអាទិ៍ ទេ ។ ប៉ុន្តែ សកម្មភាពមួយក៏អាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ ប្រសិនបើអ្នកគ្រប់គ្រងមានទាំងឆន្ទៈគ្រប់គ្រង "ដើម្បីបុគ្គលដទៃ" និង "ដើម្បីសាមីខ្លួន" ។ ឧទាហរណ៍ ដូចជា ប្រសិនបើច្រាំងទន្លេទំនងជាត្រូវបាក់ដោយសារការកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេណាម្នាក់ ចាត់វិធានការជាបន្ទាន់ ដើម្បីទប់កុំឱ្យច្រាំងបាក់ ដើម្បីការពារមិនមែនតែផ្ទះខ្លួនឯងប៉ុណ្ណោះទេ គឺដើម្បីការពារផ្ទះអ្នកជិតខាងដែរ សកម្មភាពបែបនោះនឹងត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល ។

ពាក្យថា "ការគ្រប់គ្រង" ដែលប្រើនៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល គឺខុសគ្នាពីគោលគំនិតនៃ "ការគ្រប់គ្រង" ដែលត្រូវបានប្រើនៅក្នុងផ្នែកដទៃទៀតនៃក្រមរដ្ឋប្បវេណី ត្រង់ចំណុចថា ពាក្យ "គ្រប់គ្រង" ដែលត្រូវបានប្រើក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះ រាប់បញ្ចូលទាំងសកម្មភាពចាត់ចែងផងដែរ ។ ប៉ុន្តែ ការចាត់ចែងនេះត្រូវតែធ្វើឡើងតាមមធ្យោបាយសមស្របបំផុតដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។

(3) កថាខណ្ឌទី ២ ចែងអំពីករណីយកិច្ចជាមូលដ្ឋានរបស់អ្នកគ្រប់គ្រងថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល មានករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដើម្បីគ្រប់គ្រងកិច្ចការតាមវិធីដែលសមរម្យជាងគេដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ប្រសិនបើអ្នកគ្រប់គ្រងមិនបានបំពេញករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតទេ សកម្មភាពគ្រប់គ្រងនោះត្រូវចាត់ទុកថា ខុសច្បាប់ ហើយអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលកើតឡើងពីការខកខាននោះ ។

ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត មានន័យថា ជាការគ្រប់គ្រងកិច្ចការដោយមានការយកចិត្តទុកដាក់ខ្ពស់ ដែលអ្នកប្រកបដោយវិចារណញ្ញាណនឹងធ្វើ ក្នុងស្ថានភាពជាក់លាក់ណាមួយ ។

(4) ចំពោះបញ្ហាថា តើសកម្មភាពរបស់អ្នកគ្រប់គ្រងបម្រើ ឬ មិនបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន ជាគោលការណ៍ត្រូវវិនិច្ឆ័យដោយសាមីខ្លួនផ្ទាល់ ។ ហេតុដូច្នេះ ក្នុងករណីដែលអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងបាននូវឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវគ្រប់គ្រងកិច្ចការដោយយោងតាមឆន្ទៈរបស់សាមីខ្លួននោះ ។ កថាខណ្ឌទី ៣ បញ្ជាក់អំពីចំណុចនេះ ។ ក្នុងករណីដែលអ្នកគ្រប់គ្រងមិនអាចដឹងឆន្ទៈរបស់សាមីខ្លួនទេ ឆន្ទៈរបស់សាមីខ្លួននោះ ត្រូវបានវិនិច្ឆ័យដោយយោងតាមទស្សនៈទូទៅក្នុងសង្គម ដោយគិតពិចារណានូវលក្ខណៈនៃកិច្ចការ កាលៈទេសៈជាក់ស្តែងជុំវិញសកម្មភាពគ្រប់គ្រង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៧៧ មាត្រា ៦៧៩ និង មាត្រា ៦៨៧៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤១៩ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស, មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៧៣០.-** ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

(កំណត់)

ប្រសិនបើផលប្រយោជន៍តាមផ្លូវច្បាប់របស់អ្នកដទៃ ដែលមានដូចជា ជីវិត ឬ ទ្រព្យសម្បត្តិ ជាដើម ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ សកម្មភាពដើម្បីសង្គ្រោះផលប្រយោជន៍ស្របច្បាប់ទាំងអស់នោះ មិនមែនគ្រាន់តែគួរតែទទួលស្គាល់ថា ស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែ គួរតែត្រូវបានគាំទ្រយ៉ាងសកម្មផងដែរ ពីទស្សនៈនៃការជួយគ្នាទៅវិញទៅមក ។ ហេតុដូច្នេះ ចំពោះសកម្មភាពគ្រប់គ្រងក្នុងករណីដែលមានស្ថានភាពបន្ទាន់ មាត្រានេះបន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងតិចជាងការគ្រប់គ្រងដោយឈឺឆ្អាលក្នុងករណីធម្មតា ហើយចែងថា អ្នកគ្រប់គ្រងមិនមានការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅសាមីខ្លួនឡើយ ចំពោះរាល់ការខូចខាតទាំងឡាយណាដែលបង្កឡើងដោយសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់ លើកលែងតែអ្នកគ្រប់គ្រងនោះមានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ ។ម្យ៉ាងទៀត ស្ថានភាពបន្ទាន់ក៏ត្រូវគិតពិចារណាជាកត្តាសម្រាប់កាត់បន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៤ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ២ មាត្រា ៤២០ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស

**មាត្រា ៧៣១.-** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

(កំណត់)

(1) ជាទូទៅ នៅពេលណាដែលការគ្រប់គ្រងដោយឈឺឆ្អាលចាប់ផ្តើម សាមីខ្លួនច្រើនតែមិនដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ។ ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលនេះ គឺជាការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាងក៏ដោយ

ក៏វានៅតែជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃដែរ ហេតុដូច្នេះ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គួរតែសាមីខ្លួនចូលរួមនៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះឱ្យបានឆាប់តាំងពីដំបូងតាមដែលអាចធ្វើទៅបាន ។ ដោយសារមូលហេតុនេះ មាត្រានេះកំណត់អំពីករណីយកិច្ចរបស់អ្នកគ្រប់គ្រង ក្នុងការជូនដំណឹងអំពីការចាប់ផ្ដើមការគ្រប់គ្រងនោះ ទៅសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ប្រសិនបើមិនស្គាល់សាមីខ្លួនទេ អ្នកគ្រប់គ្រងមិនចាំបាច់ធ្វើការជូនដំណឹងទេ ដោយសារតែអ្នកគ្រប់គ្រងមិនអាចធ្វើការជូនដំណឹងទៅសាមីខ្លួនបានឡើយ ។

(2) ភាពយឺតយ៉ាវ ឬ មិនយឺតយ៉ាវនៃការជូនដំណឹង ត្រូវវិនិច្ឆ័យទៅតាមលក្ខណៈនៃការគ្រប់គ្រងកិច្ចការនោះ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ គឺជាកិច្ចការតែមួយដង អ្នកគ្រប់គ្រងហាក់ដូចជាមិនចាំបាច់ធ្វើការជូនដំណឹងទេ ។ ប៉ុន្តែ ដោយសារបញ្ញត្តិស្ដីពីអាណត្តិត្រូវយកមកអនុវត្តដូចគ្នាផងដែរ អ្នកគ្រប់គ្រងមានករណីយកិច្ចរាយការណ៍នៅចុងបញ្ចប់ អ្នកគ្រប់គ្រងត្រូវតែជូនដំណឹង (រាយការណ៍) ទៅសាមីខ្លួន ទោះបីជាកិច្ចការគ្រប់គ្រងជាកិច្ចការតែមួយដងក៏ដោយ ។

(3) ដោយសារការជូនដំណឹងដែលបានចែងនៅក្នុងមាត្រានេះ មានគោលបំណងបញ្ជាក់ថា តើសាមីខ្លួនយល់ព្រម ឬ មិនយល់ព្រមចំពោះ ការគ្រប់គ្រងកិច្ចការ អ្នកគ្រប់គ្រងត្រូវរង់ចាំការចង្អុលបង្ហាញពីសាមីខ្លួន លើកលែងតែក្នុងស្ថានភាពពិសេស ដែលការរង់ចាំនឹងបង្កនូវការខូចខាតដល់ផលប្រយោជន៍របស់សាមីខ្លួន ។ ប៉ុន្តែ រហូតទាល់តែមានការចង្អុលបង្ហាញពីសាមីខ្លួនទៅចំពោះអ្នកគ្រប់គ្រង អ្នកគ្រប់គ្រងនៅតែបន្តការគ្រប់គ្រងដែលស្របទៅនឹងឆន្ទៈដែលអាចយល់បានរបស់សាមីខ្លួន ឬ ប្រសិនបើមិនអាចប្រមាណយល់បានអំពីឆន្ទៈរបស់សាមីខ្លួនទេ អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងឱ្យបានស្របនឹងផលប្រយោជន៍របស់សាមីខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣២.-** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

(កំណត់)

(1) មាត្រានេះកំណត់ថា អ្នកគ្រប់គ្រងដែលបានចាប់ផ្ដើមការគ្រប់គ្រង ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលណាមួយ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ ជាកិច្ចការដែលត្រូវធ្វើតែមួយដង នោះនឹងមិនមានបញ្ហាអ្វីកើតឡើងទេ

ដោយសារការគ្រប់គ្រងនោះ ត្រូវចប់នៅពេលដែលអ្នកគ្រប់គ្រងបំពេញកិច្ចការគ្រប់គ្រងចប់សព្វគ្រប់ ។ ប៉ុន្តែ ប្រសិនបើកិច្ចការទាមទារឱ្យមានការគ្រប់គ្រងជាបន្ត ហើយអំឡុងពេលដែលត្រូវធ្វើការគ្រប់គ្រងនោះ មិនបានកំណត់ជាក់លាក់ទេនោះ បញ្ហានឹងកើតឡើងថា តើអ្នកគ្រប់គ្រងត្រូវបន្តគ្រប់គ្រងរហូតដល់ពេលណា ។ ដើម្បីដោះស្រាយបញ្ហានេះ មាត្រានេះចែងថា អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងរហូតដល់មានហេតុជាក់លាក់ណាមួយកើតឡើង ។

(2) អ្នកគ្រប់គ្រងមានករណីយកិច្ចបន្តធ្វើការគ្រប់គ្រងរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងដោយខ្លួនឯងបាន ។ ប្រសិនបើអ្នកគ្រប់គ្រងចាប់ផ្តើមធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហើយបោះបង់ចោលពាក់កណ្តាលទី អំពើរបៀបនេះនឹងបង្កឱ្យមានការខូចខាតមិនត្រឹមត្រូវដល់សាមីខ្លួនជាញឹកញាប់ ។ ដោយសារតែហេតុផលនេះហើយ ជាគោលការណ៍ អ្នកគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យបញ្ឈប់ការគ្រប់គ្រងដោយការសម្រេចចិត្តរបស់ខ្លួនឯងតែម្ខាងនោះទេ ។ ប៉ុន្តែ ប្រសិនបើមានភាពច្បាស់លាស់ថា ការគ្រប់គ្រងដោយឈឺឆ្អាលនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ធ្វើឱ្យខូចផលប្រយោជន៍របស់សាមីខ្លួន ការបន្តការគ្រប់គ្រងមិនត្រូវបានអនុញ្ញាត ដោយយោងតាមស្មារតីនៃគោលគំនិតដើមនៃការគ្រប់គ្រងដោយឈឺឆ្អាលដូចមានចែងក្នុង កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រា ៧២៩ ហេតុដូច្នេះ អ្នកគ្រប់គ្រងត្រូវបញ្ឈប់ការគ្រប់គ្រង ទោះបីជាសាមីខ្លួន ជាអាទិ៍ មិនទាន់បានប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងក៏ដោយ ។ វាក្យខណ្ឌទី ២ នៃមាត្រានេះ ធ្វើការបញ្ជាក់ឱ្យច្បាស់ឡើងវិញនូវគោលគំនិតនេះ ។

(3) មាត្រានេះមិនមានបញ្ញត្តិចែងថា តើការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់ដែរ ឬ យ៉ាងណានោះទេ នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ទោះបីជាមានលទ្ធភាពក្នុងការបកស្រាយថា សន្តតិជនរបស់អ្នកគ្រប់គ្រង ត្រូវទទួលសន្តតិកម្មនូវករណីយកិច្ចបន្តគ្រប់គ្រងកិច្ចការក៏ដោយ ក៏សន្តតិជននោះអាចនឹងមិនមានសមត្ថភាពគ្រប់គ្រងបានត្រឹមត្រូវដែរ ឧទាហរណ៍ដូចជាករណីដែលសន្តតិជនរស់នៅឆ្ងាយ ជាដើម ។ ដោយសារតែសុឆន្ទៈរបស់អ្នកគ្រប់គ្រង មានសារៈសំខាន់ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ហើយដោយសារតែមរណភាពរបស់អាណត្តិគាហក ក៏ជាមូលហេតុមួយនៃការបញ្ចប់អាណត្តិ (មាត្រា ៦៤៩) វាប្រហែលជាសមរម្យក្នុងការបកស្រាយថា ការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ប៉ុន្តែ បញ្ហានេះទុកឱ្យតុលាការសម្រេចថា តើត្រូវប្រកាន់យកការបកស្រាយមួយណានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃ ក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧៣៣.- ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា**

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

(កំណត់)

ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានធ្វើឡើងដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួនក៏ដោយ ក៏វាស្រដៀងគ្នានឹងកិច្ចសន្យាអាណត្តិដែរ ត្រង់ចំណុចថា តាមរយៈកិច្ចសន្យាអាណត្តិ អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការរបស់អាណត្តិទាយក ឯតាមការគ្រប់គ្រងដោយឈឺឆ្អាល អ្នកគ្រប់គ្រងធ្វើការចាត់ចែងកិច្ចការដោយឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ដូច្នេះ វាទំនងជាសមរម្យដែលអ្នកគ្រប់គ្រងត្រូវទទួលបន្ទុកនូវករណីយកិច្ច ដូចគ្នានឹងករណីយកិច្ចដែលអាណត្តិគាហកត្រូវទទួលបន្ទុក ។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក) ដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០១ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣៤.-** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

(កំណត់)

(1) អត្ថប្រយោជន៍ក្នុងការទទួលស្គាល់ការបង្កើតសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាល មាននៅត្រង់ចំណុចថា ប្រសិនបើសកម្មភាពគ្រប់គ្រងមួយរបស់អ្នកគ្រប់គ្រងត្រូវបានចាត់ទុកថាជាស្របច្បាប់ ករណីយកិច្ចមួយចំនួននឹងកើតឡើងចំពោះសាមីខ្លួន ដោយសារតែសកម្មភាពស្របច្បាប់របស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។ ក្នុងចំណោមករណីយកិច្ចដែលកើតឡើងចំពោះសាមីខ្លួន ករណីយកិច្ចមួយដែលទទួលស្គាល់បានដោយមិនមានមន្ទិល គឺករណីយកិច្ចសងនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង ។ បើនិយាយពីទស្សនៈនៃអ្នកគ្រប់គ្រងវិញ វាគឺជាសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយ ។

ដោយសារតែការគ្រប់គ្រងដោយឈឺឆ្អាលបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន យ៉ាងហោចណាស់ សាមីខ្លួនត្រូវទទួលបន្ទុកនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ។ វាសមហេតុសមផលដែលយើងគិតបែបដូច្នេះថា "ទីណាមានផលប្រយោជន៍ ទីនោះមានបន្ទុកនូវសោហ៊ុយ" ។ កថាខណ្ឌទី ១ កំណត់ច្បាស់លាស់អំពីបញ្ហានេះ ។

(2) ប្រសិនបើអ្នកគ្រប់គ្រងទទួលបន្ទុកនូវកាតព្វកិច្ច ក្នុងការប្រតិបត្តិនូវការគ្រប់គ្រងដោយឈឺឆ្អាល វាមានលក្ខណៈងាយស្រួលដែលអ្នកគ្រប់គ្រងអាចមិនត្រឹមតែអនុវត្តកាតព្វកិច្ច និង ទាមទារឱ្យសាមីខ្លួនសងសោហ៊ុយមកវិញ ដោយយោងតាមកថាខណ្ឌទី ១ ប៉ុន្តែ អាចទាមទារឱ្យសាមីខ្លួនអនុវត្តកាតព្វកិច្ចជំនួសអ្នកគ្រប់គ្រងដោយឈឺឆ្អាលដែរនោះ ។ ការអនុវត្តរបៀបនេះនឹងកាត់បន្ថយនូវហានិភ័យរបស់អ្នកគ្រប់គ្រងផងដែរ ។ ដោយគិតដល់បញ្ហានេះហើយ ទើបយើងបង្កើតឱ្យមានកថាខណ្ឌទី ២ ឡើង ។

(3) វាទាមទារឱ្យមានការពិតពិចារណាបន្ថែមដើម្បីកំណត់ថា ការខូចខាតដែលអ្នកគ្រប់គ្រងទទួលរង នៅពេលប្រតិបត្តិការគ្រប់គ្រងដោយឈឺឆ្អាល គួរត្រូវបានដាក់បញ្ចូលនៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬទេ ។ ដូចកថាខណ្ឌទី ៣ នៃមាត្រា ៦៤៦ ដែលពាក់ព័ន្ធនឹងអាណត្តិដែរ វាអាចត្រូវបានបកស្រាយថា អ្នកគ្រប់គ្រងអាចទាមទារនូវសំណងការខូចខាតពីសាមីខ្លួន ចំពោះការខូចខាតទាំងឡាយណាដែលអ្នកគ្រប់គ្រងទទួលរងដោយគ្មានកំហុស ។ ប៉ុន្តែ យើងក៏អាចគិតបានដែរថា អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនមានសិទ្ធិទាមទារសំណងការខូចខាតពីសាមីខ្លួនទេ ពីព្រោះអ្នកគ្រប់គ្រងដោយឈឺឆ្អាល ដែលធ្វើកិច្ចការ មិនមែនដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន មិនគួរត្រូវបានចាត់ចែងដូចគ្នានឹងអាណត្តិគាហកដែលធ្វើកិច្ចការ ដោយផ្អែកលើកិច្ចសន្យាអាណត្តិដែលធ្វើជាមួយសាមីខ្លួន (អាណត្តិទាយក) នោះទេ ។

ជាទូទៅ ដោយសារតែមានករណីច្រើនប្រភេទដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលទទួលរងនូវការខូចខាត នៅពេលអនុវត្តការគ្រប់គ្រងដោយឈឺឆ្អាល វាហាក់ដូចជាមានភាពសមរម្យដែលថា ការសម្រេចថា តើការខូចខាតត្រូវដាក់បញ្ចូល

ទៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬយ៉ាងណានោះ ត្រូវទុកឱ្យតុលាការវិនិច្ឆ័យ ដោយផ្អែកទៅតាមស្ថានភាពជាក់លាក់នីមួយៗ ។ ប្រសិនបើបុគ្គលណាម្នាក់បានជួយអ្នកដែលលង់ទឹក ហើយសម្លៀកបំពាក់របស់ខ្លួនប្រឡាក់កខ្វក់ ការខូចខាតនោះត្រូវបានបង្កឡើងជាធម្មតា នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឃើញផ្ទាល់ ហេតុដូច្នេះ ការខូចខាតនោះត្រូវរាប់បញ្ចូលទៅក្នុងសោហ៊ុយ ។ ប៉ុន្តែ ប្រសិនបើបុគ្គលនោះ ទៅប៉ះទង្គិចជាមួយនឹងឈើអណ្តែតទឹក ហើយមានរបួស ការខូចខាតនោះបានកើតឡើងដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះ ហេតុដូច្នេះ វានៅមានការជជែកដេញដោលគ្នាថា តើរបួសស្នាមដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះនោះ គួរដាក់បញ្ចូលក្នុងសោហ៊ុយដែរ ឬទេ ។ យើងអាចនិយាយបានថា បញ្ហាទាំងនេះនឹងកើតឡើងផងដែរនៅក្នុងករណីនៃអាណត្តិ ពីព្រោះថា ការពិនិត្យមើលស្រដៀងគ្នានេះនឹងត្រូវធ្វើឡើងនៅពេលធ្វើការវិនិច្ឆ័យថា តើអាណត្តិគាហកទទួលរងនូវការខូចខាត "ដើម្បីចាត់ចែងកិច្ចការអាណត្តិ" ឬទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨៣ និង មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៧៣៥.- សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឃើញផ្ទាល់

ក្នុងករណីដែលការគ្រប់គ្រងដោយឃើញផ្ទាល់នោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឃើញផ្ទាល់នោះរួចហើយ អ្នកគ្រប់គ្រងដោយឃើញផ្ទាល់ អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឃើញផ្ទាល់នោះបាន ។

( កំណត់)

(1) ចំពោះបញ្ហាថា តើត្រូវផ្តល់កម្រៃដល់ការគ្រប់គ្រងដោយឃើញផ្ទាល់ ឬយ៉ាងណា អាចមានមតិផ្សេងៗគ្នាបានដែរ ។ ប៉ុន្តែ ការគ្រប់គ្រងដោយឃើញផ្ទាល់ ត្រូវបានធ្វើឡើង តាមសុឆន្ទៈរបស់អ្នកគ្រប់គ្រង ដូចជា សាមគ្គីភាពរវាងគ្នា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង ជាអាទិ៍ ហើយក៏ត្រូវបានធ្វើឡើងដោយមិនផ្អែកលើឆន្ទៈរបស់សាមីខ្លួនទេ ហេតុដូច្នេះ ការគ្រប់គ្រងនោះ គួរតែត្រូវបានចាត់ទុកថាជាសកម្មភាពដោយឥតយកកម្រៃ ហើយសិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រង ជាគោលការណ៍ គួរតែត្រូវបានបដិសេធ ។

(2) ប៉ុន្តែ បើយោងទៅតាមយុត្តិសាស្ត្រ និង ទស្សនៈរួមរបស់ប្រទេសបារាំង និង ទស្សនៈរួមរបស់ប្រទេសអាល្លឺម៉ង់ និង ប្រទេសជប៉ុន ប្រសិនបើសកម្មភាពគ្រប់គ្រងដោយឃើញផ្ទាល់របស់អ្នកគ្រប់គ្រង ត្រូវបានដាក់បញ្ចូលក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង អ្នកគ្រប់គ្រងដោយឃើញផ្ទាល់ អាចទាមទារនូវកម្រៃដែលនឹងត្រូវបានបង់ចំពោះវិជ្ជាជីវៈ ឬ

អាជីវកម្មរបស់ខ្លួន ។ ដោយយោងទៅលើទស្សនៈនេះ មាត្រានេះចែងថា សាមីខ្លួនមានករណីយកិច្ចបង់កម្រៃដែលត្រូវបង់ជាធម្មតា ចំពោះការគ្រប់គ្រងដោយឥតអាណត្តិ ដែលប្រតិបត្តិដោយអ្នកគ្រប់គ្រង នៅក្រោយពេលដែលសាមីខ្លួនបានដឹងថា ការគ្រប់គ្រងដោយឥតអាណត្តិត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រងដែលប្រកបវិជ្ជាជីវៈ ឬ អាជីវកម្មគ្រប់គ្រង ។ នៅក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនេះ វាមិនមានបញ្ហាអ្វីកើតឡើងទេ ក្នុងការតម្រូវឱ្យសាមីខ្លួនមានករណីយកិច្ចបង់កម្រៃ ពីព្រោះសកម្មភាពគ្រប់គ្រង អាចត្រូវបានចាត់ទុកថា ត្រូវបានធ្វើឡើងដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន ។ ចំពោះបញ្ហាថា តើសាមីខ្លួនមានករណីយកិច្ចបង់កម្រៃ នៅមុនពេលខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឥតអាណត្តិប្រភេទនោះដែរ ឬយ៉ាងណា គួររង់ចាំឱ្យមានយុត្តិសាស្ត្រនាអនាគត ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨៣ និង មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ១៥ សេចក្តីចម្រើនដោយឥតហេតុ

**មាត្រា ៧៣៦.-** លក្ខខណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ

១-ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន ។

២-នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលខ្លួនទទួលបានដោយសារការផ្តល់តាវកាលិកនោះ ឱ្យទៅអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

( កំណត់)

(1) ការពិភាក្សាដំសកម្មស្តីពីសេចក្តីចម្រើនដោយឥតហេតុ កំពុងតែបន្តធ្វើឡើងនៅបណ្តាប្រទេសនីមួយៗ ។ ជាពិសេសមានប្រទេសជាច្រើន កំពុងតែចាប់ផ្តើមទទួលស្គាល់ថា វាពិតជាមានសារៈសំខាន់ក្នុងការធ្វើការចាត់ប្រភេទសេចក្តីចម្រើនដោយឥតហេតុ និង ធ្វើការពិចារណាដោយយោងទៅតាមការបែងចែកនោះ ។ នៅពេលប្រទេសណាមួយបង្កើតនូវវិធាន

នានាស្តីពីសេចក្តីចម្រើនដោយឥតហេតុ ប្រទេសនោះនឹងប្រឈមមុខជាមួយនឹងបញ្ហាស្តីពីរបៀបដែលត្រូវប្រកាន់យក គឺបញ្ហាថា ត្រូវអនុម័តនូវវិធានសម្រាប់ប្រភេទនៃសេចក្តីចម្រើនដោយឥតហេតុនីមួយៗ ឬ ត្រូវអនុម័តនូវវិធានទូទៅ ហើយដោយផ្អែកលើវិធានទូទៅនេះ បង្កើតនូវវិធានជាក់លាក់តាមយុត្តិសាស្ត្រ ។ យើងបានសម្រេចយកវិធីទីពីរនេះ សម្រាប់ក្រមរដ្ឋប្បវេណីកម្ពុជា ពីព្រោះទោះបីជាគេនិយាយថា វាចាំបាច់ដើម្បីធ្វើការបែងចែកប្រភេទសេចក្តីចម្រើនដោយឥតហេតុក៏ដោយ ក៏ទស្សនៈស្តីពីប្រភេទដែលត្រូវបង្កើតនោះខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដែរ ។ ហេតុផលមួយទៀតដែលយើងស្នាក់ស្ទើរក្នុងការសម្រេចយកវិធីទីមួយ គឺដោយសារតែក្រមរដ្ឋប្បវេណីនេះ មិនទទួលយកនូវរបបឯករាជ្យភាពនៃសកម្មភាពទាក់ទងនឹងសិទ្ធិប្រត្យក្ស និង ភាពគ្មានទំនាក់ទំនងគ្នារវាងមូលហេតុ និង លទ្ធផលនៃសកម្មភាពទាក់ទងនឹងសិទ្ធិប្រត្យក្សទេ ។

(2) ពីទស្សនៈនៃសមភាព កថាខណ្ឌទី ១ ចែងថា ប្រសិនបើបុគ្គលណាមួយទទួលបានផលប្រយោជន៍ ដោយគ្មានមូលហេតុគតិយុត្ត ក្នុងខណៈពេលដែលបុគ្គលម្ខាងទៀតទទួលរងនូវការបាត់បង់ផលប្រយោជន៍ដែលជាមូលហេតុនៃការទទួលប្រយោជន៍ដោយបុគ្គលម្ខាងទៀតនោះ អ្នកទទួលរងនូវការបាត់បង់ផលប្រយោជន៍នោះ មានសិទ្ធិទាមទារឱ្យសងមកវិញនូវផលប្រយោជន៍ពីអ្នកទទួលនោះ ។ បញ្ហាថា តើ "ផលប្រយោជន៍" បានកើតឡើងដែរ ឬយ៉ាងណា តើ "ការបាត់បង់ផលប្រយោជន៍" ត្រូវបានទទួលរងដែរ ឬយ៉ាងណា និង ថា តើមានទំនាក់ទំនងហេតុផលរវាង "ផលប្រយោជន៍" និង "ការបាត់បង់ផលប្រយោជន៍" ដែរ ឬយ៉ាងណា នឹងត្រូវបានវិនិច្ឆ័យដោយយោងទៅតាមស្ថានភាពជាក់លាក់នីមួយៗ ។

(3) ទំហំនៃ "ផលប្រយោជន៍" ដែលត្រូវសងទៅវិញដោយបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ត្រូវបានកម្រិតនៅក្នុងទំហំនៃ "ការបាត់បង់ផលប្រយោជន៍" ។ ជាញឹកញាប់ បុគ្គលដែលបានទទួលផលប្រយោជន៍ តែងតែបរិភោគផលប្រយោជន៍នោះ ។ ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវបានបង្គាប់ឱ្យសងផលប្រយោជន៍ក្រោយពេលបរិភោគ បុគ្គលដែលបានទទួលផលប្រយោជន៍អាចទទួលរងនូវការខូចខាតដោយមិនបានព្យាករទុកជាមុន ។ ហេតុដូច្នេះអ្វីដែលត្រូវសងទៅវិញនោះ ត្រូវបានកម្រិតត្រឹម "ផលប្រយោជន៍ដែលមាន" ។ ប៉ុន្តែ ដោយសារតែមិនសូវមានភាពចាំបាច់ច្រើនក្នុងការការពារបុគ្គលដែលបានទទួលផលប្រយោជន៍ដោយទុច្ចរិត ដូចបានចែងក្នុងមាត្រា ៧៣៧ មាត្រានេះត្រូវយកមកអនុវត្តតែចំពោះបុគ្គលណាដែលបានទទួលផលប្រយោជន៍ដោយសុចរិតប៉ុណ្ណោះ ។

(4) ចំពោះបញ្ហាថា តើផលប្រយោជន៍ "មាន" ឬ "គ្មាន" គឺអាស្រ័យទៅលើការវិនិច្ឆ័យរបស់តុលាការ ។ ប៉ុន្តែ ប្រសិនបើ "ផលប្រយោជន៍" ជាប្រាក់វិញ ការវិនិច្ឆ័យដែលសម្រេចថា "មាន" នឹងមានភាពទូលំទូលាយ ដោយសារលក្ខណៈនៃសិទ្ធិដែលមានតម្លៃ ឬ ភាពអរូបីនៃប្រាក់ ។ ឧទាហរណ៍ ប្រសិនបើបុគ្គលដែលបានទទួលប្រាក់ជាផលប្រយោជន៍ បានប្រើប្រាស់ប្រាក់នោះ សម្រាប់ចំណាយក្នុងជីវភាពរស់នៅ បុគ្គលនោះសន្សំប្រាក់ពីប្រាក់ដែលត្រូវចំណាយសម្រាប់ការផ្គត់ផ្គង់គ្រួសារ ហេតុដូច្នេះ "ផលប្រយោជន៍" នៅតែមានជាប្រាក់ដែលបានសន្សំទុក ។

(5) កថាខណ្ឌទី ២ ចែងថា វិធានស្តីពីសេចក្តីចម្រើនដោយឥតហេតុ ត្រូវយកមកអនុវត្ត ចំពោះករណីដែលកិច្ចសន្យាក្លាយជាមោឃៈ ឬ បាត់បង់អានុភាពដោយសារការលុបចោល ឬ ការរំលាយ ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើ

មានវិធានពិសេសចំពោះកិច្ចសន្យាគួរអនុវត្ត ការអនុវត្តវិធានពិសេសនោះត្រូវចាត់ទុកថា ស្របទៅតាមឆន្ទៈរបស់ភាគី និង នាំមកនូវលទ្ធផលដែលប្រកបដោយភាពត្រឹមត្រូវ ។ បញ្ហាថា តើករណីនីមួយៗស្ថិតក្នុងករណីបែបនេះ ឬ យ៉ាងណានោះ ត្រូវបានទុកឱ្យតុលាការធ្វើការវិនិច្ឆ័យ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៧៦ និង មាត្រា ១៣៧៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣៧.-** ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយគំនិតទុច្ចរិត

១-បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានកំណត់នៅក្នុងមាត្រា ៧៣៦ (ល័ក្ខខ័ណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ) ខាងលើនេះ ក្នុងករណីដែលបានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលដែលបានដឹង រហូតដល់ពេលសង ។

២-បើបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-បើបុគ្គលដែលត្រូវបានបាត់បង់ផលប្រយោជន៍ ទទួលការខូចខាត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតនោះ ។

( កំណត់)

(1) ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍បានដឹងថា ផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្តទេ បុគ្គលនោះអាចត្រូវបាននិយាយបានថា បានដឹងថាផលប្រយោជន៍នោះជារបស់បុគ្គលដទៃ ។ ហេតុដូច្នេះ កថាខណ្ឌទី ១ ចែងថា នៅក្នុងករណីបែបនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលខ្លួនបានដឹងពីការណ៍នោះ ជាមួយគ្នានឹងការប្រាក់ដែលបានមកពីផលប្រយោជន៍នោះ ។ ភាពត្រឹមត្រូវនៃការអនុវត្តបែបនេះ គឺច្បាស់លាស់ដូចបានពន្យល់អំពីមាត្រា ៧៤៧ ហើយ ។ ចូរកត់សម្គាល់ថា ទោះបីជាបុគ្គលដែលបានទទួលផលប្រយោជន៍នោះ

មិនបានដឹងអំពីការណ៍នោះពីដំបូង (សុចរិត) ក៏ដោយ ប្រសិនបើបុគ្គលនោះក្លាយទៅជាទុច្ចរិតវិញនៅពេលក្រោយ ក៏មាត្រានេះត្រូវយកមកអនុវត្តដែរ ។ ចំណុចនេះ ខុសគ្នាពីការអនុវត្តតាមក្រមរដ្ឋប្បវេណីជប៉ុន ។

(2) ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារការឆបោក គេអាចនិយាយបានថា ជនឆបោកនោះ បានដឹងថា ផលប្រយោជន៍ដែលខ្លួនទទួលបាន នឹងគ្មានមូលហេតុគតិយុត្ត ដោយសារការលុបចោលនាអនាគត ។ ក្នុងករណីនេះ ជនឆបោកអាចត្រូវបានចាត់ទុកថា បានដឹងថា ខ្លួនគ្មានមូលហេតុគតិយុត្តក្នុងការទទួលប្រយោជន៍ទេ ។ កថាខណ្ឌទី ២ បញ្ជាក់ច្បាស់លាស់អំពីបញ្ហានេះ ។ ការចាត់ចែងបែបនេះគួរធ្វើឡើង មិនគ្រាន់តែក្នុងករណីដែលបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនាប៉ុណ្ណោះទេ ព្រមទាំងករណីដែលបុគ្គលនោះមានកំហុសដែរ ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវយកមកអនុវត្ត មិនមែនតែចំពោះករណីដែលបុគ្គលបានទទួលប្រយោជន៍ដោយចេតនាប៉ុណ្ណោះទេ ព្រមទាំងចំពោះករណីដែលបុគ្គលបានទទួលផលប្រយោជន៍ដោយមានកំហុសផងដែរ ។

(3) កថាខណ្ឌទី ៣ ចែងថា ប្រសិនបើបុគ្គលដែលបង្កឱ្យមានការបាត់បង់ផលប្រយោជន៍ ក៏ទទួលរងនូវការខូចខាតដែរ បុគ្គលដែលបានទទួលផលប្រយោជន៍ដែលបានដឹង ឬ គួរអាចដឹងបានថា ផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្ត ត្រូវសងការខូចខាតនោះ ។ កថាខណ្ឌទី ៣ ទទួលស្គាល់នូវការទទួលខុសត្រូវរបស់អ្នកទទួលផលប្រយោជន៍ ចំពោះសំណងនៃការខូចខាត ក្រោមគោលការណ៍នៃការទទួលខុសត្រូវដោយកំហុស ។

ចំពោះការទទួលខុសត្រូវក្នុងការសំណងនៃការខូចខាតនេះ វានៅតែមានការជជែកដេញដោលគ្នាថា តើត្រូវទទួលស្គាល់ជាពិសេសតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ដើម្បីធានាឱ្យបាននូវភាពយុត្តិធម៌ ឬ គួរត្រូវទទួលស្គាល់តាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូល (ការកំណត់ក្នុងមាត្រានេះដើម្បីជាការបញ្ជាក់បន្ថែមចំពោះករណីនេះ) ។ ដោយសារតែបញ្ហានេះត្រូវដោះស្រាយទៅតាមការវិវត្តនៃវិធានស្តីពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល និង ការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច យើងមិនព្យាយាមស្វែងរកចម្លើយទេ ដោយទុកឱ្យតុលាការ និង ទ្រឹស្តីនីតិសាស្ត្រនាពេលអនាគតធ្វើការបកស្រាយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៧៨ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ៨១៩ និង កថាខណ្ឌទី ៤ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧៣៨.- ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន អាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលដឹងថា គ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបានឡើយ ។

## ផ្នែកទី៣
## ភាគព្វកិច្ច កើតអំពីសេចក្តីចំរើនដោយឥតហេតុ
## កថាខ័ណ្ឌទី១
## អំពី សងប្រាក់ ដែលគ្មានជំពាក់

**មាត្រា ៨១៩** ៖ ជនណាមិនបានជំពាក់គេទេ តែភ័ន្តច្រឡំថាខ្លួនជំពាក់គេ ហើយក៏បានសងទ្រព្យ ដែលខ្លួនមិនបានជំពាក់នោះទៅគេ ជននោះអាចប្តឹងទារយកវិញបាន ។

**មាត្រា ៨២០** ៖ ដែលនឹងប្តឹងទារវិញនោះ គឺប្តឹងឲ្យបង្វិលរបស់ ដែលលើកទៅឲ្យគេខុសនោះមកវិញក្តី នឹងប្តឹងឲ្យសងថ្លៃរបស់នោះក្តី នឹងប្តឹងឲ្យសងតម្លៃតាវកាលិកដែលខ្លួនបានបំពេញហើយនោះក្តី ។

**មាត្រា ៨២១** ៖ ជនណាបានសំណងនូវរបស់ ដែលគេមិនបានជំពាក់ខ្លួនសោះដោយសត្យសុចរិត ឥតចេតនាក្លែង ជននោះត្រូវបង្វិលរបស់ដែលគេប្រគល់ឲ្យនោះទៅគេវិញ បើរបស់នោះគង់នៅក្នុងដៃរបស់ខ្លួននៅឡើយ ។ ថាបើរបស់នោះមិននៅក្នុងដៃខ្លួនទេ ជននោះត្រូវសងថ្លៃលក់ឲ្យគេ ។



បើតាវកាលិកនោះជាការដែលគេបានធ្វើឲ្យជននោះត្រូវសងតម្លៃនៃការ ។

**មាត្រា៨២២** ៖ បើរបស់នោះបាត់ ឬ ខូចដោយខុសពីខ្លួនជននោះត្រូវទទួលសងគេ ។

**មាត្រា ៨២៣** ៖ ជនណាទទួលដោយចេតនាទុចរិត នូវសំណងដែលខ្លួនដឹងថាគេមិនបានជំពាក់ខ្លួនទេ ជននោះត្រូវបង្វិលរបស់ដែលគេប្រគល់ឲ្យនោះទៅគេវិញបើជាទទួលប្រាក់វិញត្រូវសងការគេទៀតដោយគិតមួយឆ្នាំ ៩% បើជាទទួលវត្ថុដែលបង្កើតផល ជននោះត្រូវសងផលនោះដល់គេផងមួយទៀតបើនឹងផ្តន្ទាទោសឲ្យសងជម្ងឺចិត្តគេទៀតផង ក៏បាន ។

**មាត្រា ៨២៤** ៖ បើរបស់នោះបាត់ ឬ ខូចខាតជននោះត្រូវទទួលសងគេទោះបាត់ ឬ ខូចខាតដោយករណីប្រធានស័ក្តិក៏ដោយ ។

## កថាខ័ណ្ឌទី២
## អំពី ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៨២៥** ៖ ជនណាឥតគេពឹងរក ហើយទទួលគ្រប់គ្រងនូវទ្រព្យសម្បត្តិនៃជនដទៃ ដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលគ្រប់គ្រង គ្រាតែដល់ម្ចាស់គេមកគ្រប់គ្រងខ្លួនគេវិញ ។ ជននោះត្រូវយកចិត្តទុកដាក់ចាត់ចែងការបីដូចជាឪពុកដ៏ប្រពៃនៃត្រកូលគឺថាទុកខ្លួនដូចជាម្ចាស់របស់ពិត១ និងយកចិត្តទុកដាក់នឹងផលប្រយោជន៍ទ្រព្យនោះផង ។

**មាត្រា ៨២៦** ៖ កម្មសិទ្ធិករ នៃបេតិកភ័ណ្ឌ ដែលគេបានគ្រប់គ្រងឲ្យដោយត្រឹមត្រូវនោះត្រូវសងទៅអ្នក ដែលគ្រប់គ្រងនោះនូវប្រាក់ដែលគេបានចេញ



ចាយវាយក្នុងការជាចាំបាច់ ឬ ក្នុងការមានប្រយោជន៍ទាំងប៉ុន្មាន១ទៅគេវិញមួយទៀតជននោះត្រូវគិតសោហ៊ុយនៃសេចក្ដីលំបាកក្នុងការថែរក្សានោះឲ្យគេផងទៀត ។

# ឧបសម្ព័ន្ធ


គំនូសដ្យាក្រាម
ប្រភពកាតព្វកិច្ច
កាតព្វកិច្ចកើតឡើងដោយឆន្ទៈ
កិច្ចសន្យា
សកម្មភាពឯកតោភាគី
កាតព្វកិច្ចកើតឡើងដោយច្បាប់
ការគ្រប់គ្រងដោយឈឺឆ្អាល
សេចក្តីចម្រើនដោយឥតហេតុ
អំពើអនីត្យានុកូល
បញ្ញត្តិនៃច្បាប់
មាត្រា៣០៩ នៃក្រមរដ្ឋប្បវេណី

# សេចក្តីផ្តើម

# ជំពូកទី១
# កាតព្វកិច្ចឧបសន្យា

# ជំពូកទី២
# ករណីយកិច្ច

# ជំពូកទី៣
# អានុភាព

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ឯកសារយោង